កំណាព្យ១ ជួបហើយគង់តែបែក

បទ ពាក្យត្រាំថ្មី

១. ធម្មជាតិកើតហើយលម្អរផែនដី ជាតិមនុស្សប្រុសស្រីកូនប្តីម៉ែឪ
បានជួបគ្នាហើយគង់តែព្រាត់ទៅ កុំជាសត្រូវត្រូវកើតជាមិត្ត ។

២. រស់ត្រឹមមួយជាតិញាតិពេញលោកា ត្រូវមានមេត្តាវាចាស្មាលស្និទ្ធ
មេត្តាកាយកម្មប្រចាំដួងចិត្ត ពោលតែពាក្យពិតឥតមានមុសា។

៣. ត្រកូលមន្ត្រីសេដ្ឋីក្នុងវាំង តាចឹកព្រមទាំងហួននោះណា
ថ្ងៃ បីមីនាកំណើចៅតា នាមហួនរតនាសូរ្យពេជ្រថ្លៃ ។

៤. បានបួសសាមណេរសមណៈភិក្ខុ ឧទ្ទិសជូនពុកញោមណុចចរណៃ
កុសលប៉ុន្មានបានជាកម្រៃ ដ្បិតបិតាក្ស័យត្មាបួសសងគុណ។

៥. សូមជូនកុសលផលជូនញោមនី បងណាតបងធីបងភាជាមុន
ព្រមទាំងក្មួយចៅសូមទទួលបុណ្យ ត្រេកអរជាទុនទ្រព្យបុណ្យកុសល។

៦. ១០០០រាត្រីបីរយប៉ែតថ្លាយ ថែមប្រាំបួនថ្ងៃបុត្រឆោមនិមល
បានលាមាតាប្រាថ្នាមគ្គផល និព្វានដំកល់ដាក់ក្នុងសណ្តាន។

៧. ជ្រុញ និង កាំបិតចិតបន្លែស្ល លាChef រូបល្អសកលថ្កើងថ្កាន
គណនេយ្យវិជ្ជាប្រាថ្នាលុយឡាន សង្ឃឹមត្រឹមស្មានមន្ត្រីពន្ធដា ។
៨. លាម្សៅនំប៉័ងម្ហូបFranceអង់គ្លេស លាម្ហូបពិសេសឆ្ងាញ់ៗពីសារ
លាបំណងពូជស្នងតំណែងតា បួសក្នុងសាសនាសិក្សាវិន័យ ។
៩. ព្រះត្រៃបិដកមរតកព្រះពុទ្ធ ព្រះតថាគតសាសនាជិនស្រី
វិសុទ្ធិមគ្គវត្តព្រៃឬស្សី មហាវនមហាព្រៃចេតិយគោតម ។
១០.បានខិតខំរៀនពុំរុញរា រៀនដោយសទ្ធារឹងប៉ឹងមុតមាំ
ទន្ទេញបិដកតាំងពីបឋម ដល់ថ្នាក់ឧត្តមនៅគីរីរម្យ ។
១១.បួសបានមួយខែទោះបីឈឺថ្កាត់ ឧបសគ្គវិបត្តិរុករានកាយខ្ញុំ
ក្រពះពោះវៀនឈឺធ្ងន់ធ្ងរធំ ប្រាំមួយខែមុំលេបថ្នាំបារាំង ។
១២.បរបសម្លាញ់លែងឆ្ងាញ់ហើយអ្នក ឆាន់ក្អួតឆាន់ខ្ជាក់ធ្លាក់ងៀតត្រីអាំង
ដើរមួយជំហានក្អួតចង្អោរខ្លាំង សាច់ឈាមស្លេកស្លាំងចូលពេទ្យរុស្សី។
១៣.មង្គលបូរីដីខេត្តភ្នំស្វាយ អរគុណអ្នកម្តាយញោមនីទាំងពីរ
បម្រើលោកកូនបើកភ្នែកមមី ឱ!អ្នកម្តាយនីញោមអាត្មាថ្លៃ ។

១៤.ឥឡូវសាច់ឈាមនាមអ្នកជម្ងឺ ទោះបីខ្លួនឈឺមិនផ្តាច់និស្ស័យ
ខំធ្វើបុណ្យទានជារៀងរាល់ថ្ងៃ កសាងបារមីនាមកូនកត្តញ្ញូ ។
១៥.ថ្វាយទានព្រះសង្ឃដោយបច្ច័យបួន លះអស់ពីខ្លួនគ្មានសល់តម្លៃ
បូជាកសាងព្រះរតនត្រ័យ ព្រះធម្មចេតិយព្រះពុទ្ធបដិមា ។
១៦.ព្រះពុទ្ធមង្គលសុមនោគោតម សុជាតបទុមបមុត្តរា
បិយទស្សីសិរីមតា ធាតុព្រះសាស្តាបូជាដោយពេជ្រ។
១៧.ជូនទានព្រះរស់ឈ្មោះបុណ្យសង្ឃទានអស់ដប់ពីរលានត្មាចាំពុំភ្លេច
បានស្តាប់ព្រះសង្ឃទេសនារំលេច អធិប្បាយពាក្យពេចន៍ព្រះពុទ្ធដីកា។
១៨.អរគុណញោមបងលះបង់ទ្រព្យា ខាតបង់ការងាគ្មានលេសពោលថា
បានធ្វើបុណ្យទានជូនដល់មាតា ដោយក្តីជ្រះថ្លាជាមហាកុសល ។
១៩.អរគុណលោកម្ចាស់គ្រប់រូបគ្រប់អង្គ តំណាងព្រះសង្ឃបានថ្វាយភោគផល
សព្វគ្រប់ប្រការជាឃ្លាំងដំកល់ នាំទានភោគដល់សព្វញាតិការ ។
២០.បុណ្យកឋិនទានមានត្រៃចីវរ តាអេវពើងថ្មគូលេនបព្វតា
ជ្រាប់ចាស់ដីស្អិតព្រមទាំងទេសនា វត្តមហាវនៈណា និង គល់ទទឹង ។

២១.និង បុណ្យផ្សេងៗទៀតច្រើនអនេក ថ្ងៃនេះថ្ងៃស្អែកបែកគ្នាថ្ងៃហ្នឹង
ឬ ថ្ងៃបន្ទាប់ខ្ញុំមិនទាន់ដឹង ចិត្តអន់ក្រោធខឹងនឹងខ្ញុំករុណា ។

២២.សូមអ្នកត្រេកអរនូវកុសលទាន បុណ្យទាំងប៉ុន្មានដោយក្តីជ្រះថ្លា
ជាសម្ពាយទ្រព្យគ្រប់រូបអាត្មា បានសូគ៌ទេវតាត្រើយសុខនិព្វាន ។

២៣.បុគ្គលខឹងក្រោធបានប្រយោជន៍អ្វី? អ្នកមានខន្តីទើបទប់ក្រោធបាន
រីអ្នកសប្បុរសទាំងប៉ុន្មាន តែងមានសណ្តានឈ្នះអសប្បុរស ។

២៤.រីជនកំណាញ់តែងចាញ់អ្នកឲ្យ រីអ្នកពោលហើយមិនពិតស្មំគ្រស្មោះ
តែងចាញ់សម្តីពោលពិតទាំងអស់ មិនពោលឡេះឡោះរក្សាសច្ចៈ។

២៥.ឈ្នះមនុស្សដោយយ៉ាងសាងអំពើល្អរស់នៅបន្តឆ្ងាយចាកអន្ទាក់
លក្ខណ៍គោលសាសនាព្រះពុទ្ធសមណៈពិតមានអមតៈបទព្រះនិព្វាន ។

២៦.ព្រះពុទ្ធសាសនាចារជាគម្ពីរ បិដកសំភីសង្ឃសិក្សារៀន
ស្វាធ្យាយបដិបត្តិតាមព្រះប្រធាន ឈប់នៅវិមានក្នុងផ្ទៃមាតា។

២៧.ជួបហើយគង់បែកព្រាត់ជាមិនខាន ញាតិមិត្តប៉ុន្មានគង់តែមរណា
គ្រែនេះសង្ឃឹមជាធម្មទេសនា គិតសង្ឃឹមថាជាគ្រែចុងក្រោយ។

២៨.ព្រះធម៌មិនមែនសំរាប់លេងសើច ទុកជាសំណើចចំអកឡកឡឺយ
ព្រះធម៌ទេសនាជាកោះឆ្លងត្រើយ ដល់និព្វានហើយទើបបានក្តីសុខ ។
២៩.ត្រេកអរក្នុងកាមមានសុខតិចណាស់រូបកាន់តែចាស់ផ្លាស់ប្តូរមាត់មុខ
ស្នេហ៍សុខក្នុងទុក្ខៗស្នេហ៍ក្នុងសុខ រងកម្មរងទុក្ខ តាមកម្មចាត់ចែង។
៣០.ពេលឈឺម្តងៗបានស្វែងកាត់គ្រោះកើតរឿងតប់ឈ្លោះថាកម្មតាក់តែង
ប្តីវៃហើមមុខថាដួលខ្លួនឯង ប្តីមានស្រីក្មេងទើបដឹងខ្លួនចាស់។
៣១.គំនួចវាយោផ្លាស់ប្តូររដូវ ការគិតយលត្រូវពិបាកយល់ណាស់
ដូចឧត្តរាស្រីស្ត្រីមេផ្ទះ សិរីមាឆ្នាស់ធះខ្លាញ់ដាក់នាង ។
៣២.Butter បីរក្តៅស្រីខ្លៅពារ: បានប្តីគេស្ម័គ្រធ្វើឯងកាច់រាង
កាច់ឫកផ្កាមាសខ្លាំងខាងរាំច្រៀង បានត្រូវកំផ្លៀងទើបបានស្លូតភ័យ ។
៣៣.បរិវារចោមជិតពិតជួយចាហ្វាយ ឧត្តរាឆោមឆាយមេត្តាខន្តី
ពោលពាក្យសច្ចៈដឹងគុណសិរី- មា បំរើប្តីខ្លួនបានធ្វើទាន។
៣៤.ឋានព្រហ្មទេវតាគង់តែចង្អៀត នាងបន្តទៀតថាក្នុងវិមាន
បើសិរីមាប្រាថ្នាបំពាន រាប់រយដងលានបំពានលើស្រី។

៣៥.ក៏មិនភ្ញញថាកម្មនេះធ្ងន់ឡើយ ដ្បិតនាងនេះហើយមានគុណឥតបី
បាននាងនេះហើយបម្រើជើងប្តី ខ្លួនមានសិរីបំពេញកុសល។
៣៦.បម្រើព្រះសង្ឃអង្គព្រះជិនស្រី ដ្បិតថាព្រះអរិយសោតាបត្តិផល
ធ្វើទានពុំស្តាយភោគទ្រព្យតម្កល់ គ្រាន់ជាសំណល់យកទៅពុំបាន។
៣៧.ឧបដ្ឋាកយិកាឧត្តរាឧត្តម បម្រើគោតមព្រះពុទ្ធថ្កើងថ្កាន
លះភាពជាមនុស្សស្រស់ស្រីកល្យាណបានកើតក្នុងឋានសួគ៌ជាន់ទីប្រាំ។
៣៨.មានវិការពណ៌សម្បុរមាស ធីតាឱភាសទូលពិត្រផ្តែផ្តាំ
ដល់ព្រះត្តេរដែលខ្លួនបានចាំ ពុទ្ធចំណាំជាសកទាគា ។
៣៩.ព្រះធម៌ចារចែងសម្តែងជាកាព្យ ឃ្លោងឃ្លាកំណាព្យរៀបរាប់ពណ៌នា
បែបបទសង្ខេបពុំបានពិស្តារ ដ្បិតពេលវេលាមានកាលកំណត់។
៤០.រឿងរ៉ាវពិស្តារគាថាពីរោះ មានតួអង្គឈ្មោះតាមលោកសន្មតិ។
អដ្ឋកថាបិដកប្រាកដ ចារចប់បែបបទឯវំធម្មោ។
៤១.បើឆ្គងខន្តីបារមីអ្នកកើត ថ្ងៃខួបកំណើតខ្ញុំជូនកាដូ
ព្រះធម្មទេសនាសារស័ព្ទផ្លាស់ប្តូរ ហួន រតនាសូរ្យពេជ្រសូមលា៕

^{0៤}។.0៣.២៥៦0 ត្រូវនឹងថ្ងៃ ពុធ ទី 0១ខែមីនា ឆ្នាំ២0១៧

និពន្ធ ភិក្ខុបញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ២ សម្រស់គីរីរម្យ ភ្នំវត្តមហាវ៉ន

មន ពាក្យត្រាំមី

១.	លើកហត្ថប្រណម្យបង្គំវន្ទា	ឆ្ពោះព្រះភគវាពុទ្ធាបានត្រាស់	
	ទ្រង់សាងបារមីសាមសិបឥតខ្ចះ	ព្រះសង្ឃល្អល្អះច្បាស់ក្នុងសិក្ខា	។
២.	សូមថ្វាយបង្គំព្រះរតនត្រ័យ	មិនអាចកាត់ថ្លៃខ្ញុំសូមនមស្ការ	
	ព្រះសង្ឃគីរីរម្យជាទីជ្រះថ្លា	មានការសិក្សាបដិបត្តិតាមធម៌	។
៣.	គោតមចេតិយខ្ពស់ផុតព្រៃស្រល់	ព្រះធាតុដំកល់រក្សាយ៉ាងល្អ	
	សួនច្បារស្មៅខ្ចីចំបីផ្ការស	ក្រហមនោះហ្នុ់!លំអរបូជា	។
៤.	ដើមអស្សត្ថព្រឹក្សលាស់ស្លឹកខៀវខ្ចី	ម្លប់ពោធ៏បារមីនៃព្រះភគវា	
	មានដើមកំណើតនៅឯឥណ្ឌា	និង ស្រីលង្ការបានប្រតិស្ឋាន	។
៥.	នៅគីរីរម្យភ្នំវត្តមហាវ៉ន	មានព្រះអរហន្តមុន្នីសូរ្យកាន្ត	
	ស្មឹងស្មាធ៏សមាធិក្រោមម្លប់កល្យាណជាទីសុខសាន្តមានពីរព្រះអង្គ		។
៦.	ក្នុងចេតិយមានព្រះអង្គប្រោសសត្ធ	ជាទីស្ងប់ស្ងាត់សម្រាប់ព្រះសង្ឃ	
	ធ្វើការបូជាតាំងចិត្តផូរផង់	ទិសដៅតម្រង់ឆ្ពោះកាន់និព្វាន	។

៧. ឧបដ្ឋានសាលាសែនជ្រះថ្លាក្រៃ នឹងព្រះជិនស្រីដូចគង់ធរមាន
ទីដែលបរិសទ្យតែងបំពេញទាន តាមទ្រព្យធនធានទានផ្ទើរនឹងសង្ឃ ។
៨. ឃើញព្រះបដិមាសែនជ្រះថ្លាពិត រចនាវិចិត្រពិសិដ្ឋគ្រប់អង្គ
មាននាមបញ្ញត្តិរលឹកពុទ្ធវង្ស និមន្តទ្រង់គង់បល្ល័ងបទុមា ។
៩. ម្លប់ពោធិព្រឹក្សអង្គព្រះជិនស្រី ម្លប់ពោធ៏បារមីនៃព្រះសាស្តា
អនេកច្រើនក្រៃសែនល្អអស្ចារ្យ បទុមុត្តរាត្រាស់ក្រោមដើមស្រល់ ។
១០. អង្គសុជាតៈមានដើមឫស្សី ម្លប់ពោធ៏បារមីសាងបុណ្យកុសល
មង្គលសុមនោអ្នកអើយកុំឆ្ងល់ នាគព្រឹក្សនោះដល់ជាពោធ៏ព្រឹក្សា ។
១១. អង្គបទុមត្រាស់នៅក្រោមដើមម្រុំ ទូលព្រះបង្គំខ្ញុំសូមវន្ទា
បិយទស្សីគួរសែនរម្យនា ដើមថ្កាន់នោះជាម្លប់ពោធ៏ត្រូវចាំ ។
១២. ព្រះពុទ្ធគោតមនាគមុចលិន្ទ ទ្រង់មានព្រះជន្មគឺមួយរយឆ្នាំ
ពស់ពែនភ្នែនព័ទ្ធត្រូវយើងចងចាំ មុចលិន្ទនាគគ្រាំនៅក្នុងស្រះទឹក ។
១៣. នេះជាសទ្ធាអ្នកដែនមានជ័យ ញាតិញោមប្រុសស្រីបីខេត្តគួរនឹក
ភ្នំពេញកំពតជាទីរលឹក នឹកដល់ថ្ងៃដឹកអារាធនាព្រះអង្គ ។
១៤. ជិះឡានបត់បែនកាត់ជ្រលងភ្នំ ឃើញគីរីរម្យភ្នំស្រស់ផូរផង់
តែផ្លូវលំបាកចិត្តឥតបង្អង់ តំរែតម្រង់សម្រេចគោលដៅ ។

១៥. ឥឡូវគីរីរម្យផ្លូវភ្នំចូលវត្ត
ឥឡូវស្រួលដើរធ្វើដំណើរទៅ
កំពុងអភិវឌ្ឍន៍ឈូសឆាយដាំស្មៅ
ដោយសារញាតិផៅបរិច្ចាគធនធាន ។

១៦. មានលោកម្ចាស់គ្រូជាទីជ្រះថ្លា
គណៈកម្មការឈ្លាសវៃរួមមាន
ព្រះចៅអធិការលោកជាប្រធាន
ញោមវុធករុណាទានប្រធានស្រី។ ។

១៧. ឥឡូវផ្ទះបាយសាងរួចស្ថាពរ
ម្លូបក្តៅត្រជាក់ដោយអនាម័យ
ជាទីត្រេកអរធ្វើម្លូបចំណី
ថ្វាយព្រះសង្ឃថ្លៃរាល់ថ្ងៃបរិបូណ៌ ។

១៨. សាលាបាលីសិក្សាបរិយត្តិ
រីកុដិព្រះសង្ឃនៅក្បែរជ្រោះអូរ
បណ្ណាល័យស្ងាត់ឯកសារហែរហូរ
ទោចយំលឺសូរពីរោះជាប់ចិត្ត ។

១៩. ព្រះសង្ឃធុតង្គគង់នៅព្រៃស្ងាត់
ភ្លើងទៀនផ្លុងៗបំរុងត្រិះគិត
សមាធិបដិបត្តិយប់ស្ងាត់ងងឹត
រស់អប់រំចិត្តប្រព្រឹត្តក្តីល្អ ។

២០. ថេរៈនវភិក្ខុសាមណេរ
សូមវត្តមហាវ៉ែនជាទីត្រេកអរ
ទាំងខ្ញុំទាំងគេរស់រៀនសូត្រធម៌
ទីស្ថានបវរសុខសាន្តមនោរម្យ ។

២១. រីខ្ញុំអាត្មាបញ្ចាហានៈ
ខុសឆ្គងខន្តីអាត្មាសូមសុំ
រតនាសូរ្យពេជ្រថ្លែងមិនសម
សម្រស់គីរីរម្យភ្នំវត្តមហាវ៉ែន ។

៣ ៗ ១១ .០៤ .២៥៦០

វត្តមហាវ៉ែន .អង្គារ .២៣ .មីនា .២០១៧

និពន្ធ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៣ ខ្ពត្តមគតិលោកប៉ូលឌុលប្រូល

បទ ពាក្យត្រាំបួន

១. គតិបណ្ឌិតពិតមួយដ៏ឧត្តម ជូនសង្គមកម្ពុជាក្រុងអង្គរ
គឺសាលាសណ្ឋាគារ និង ទេសចរណ៍ ដ៏បវរជាជំនូនជូនខេមរា ។

២. ជាចំណងការចងដៃកុលបុត្រខ្មែរ ជាមន្តស្នេហ៍ឲ្យកូនខ្មែរបានសិក្សា
មានអាជីពពិតប្រាកដរស់ថ្លៃថ្លា គឺប្រាថ្នាតែមួយគត់របស់លោក។

៣. ប៉ូលឌុលប្រ៊ូលម្ចាស់ទីក្រុងហ្វុងតែនប្លូ លោកគិតគូរពីកូនខ្មែរលោកលៃលក
ផ្តើមបង្កើតសាលារៀនមានជំរក ខ្មែរបានជ្រកបានរស់រៀនមានរស្មី។

៤. ដើម្បីបង្ហាញពីទឹកចិត្តស្មោះស ថ្លៃបវរក៏លោកបានចងមេត្រី
ហ្វុងតែនប្លូ និង សៀមរាប ក្រុងមួយថ្មីដែលមានន័យជាគ្រួសារ។

៥. ម្តៃប្រាំមួយខែកុម្ភៈពីរពាន់ពីរ ការពលីដ៏សំខាន់ដ៏អស្ចារ្យ
របស់លោកប៉ូលឌុលប្រ៊ូលដ៏ថ្លៃថ្លា ការប្តេជ្ញាការតស៊ូមួយដ៏ល្អ។

៦. ទោះជាផ្លូវសែនវែងឆ្ងាយលំបាកម្តេច លោកពុំភ្លេចការកសាងអគារបវរ
ឈ្មោះសាលាសណ្ឋាគារនិងទេសចរណ៍ ចិត្តស្មោះសដោយចាយពេលប្រាំពីរខែ។

៧. ដោយជិះកង់ពីទីក្រុងហ្វុងតែនប្លូ លោកតស៊ូមកសៀមរាបទឹកដីខ្មែរ
ជាគំនិតគិតទុកស្រេចឥតប្រួលប្រែ ដោយក្តីស្នេហ៍បើកសម្ភោធកិច្ចសិក្សា។

៨. ការពុះពារទោះវេទនាជួបឧបសគ្គ
ស៊ូជិះកង់ដោយលំបាកធ្វើសញ្ញា
៩. មានជីវិតត្រូវរៀនរស់រកការងារ
ទើបប្រាថ្នាលោកសម្រេចសមដូចចិត្ត
១០.ជាពិសេសគឺយុវជនទុនសង្គម
ចាប់ជំនាញមួយប្រាកដដែលខ្លួនស្នេហ៍
១១. មានខាងCOOK .PBI.RESTERANT
TOURISM ក៏មានដែរក្នុងកំណើត
១២.យើងខ្ញុំពិតជាកូនខ្មែរទាំងប្រុសស្រី
យើងប្តេជ្ញាខំសិក្សាសាងសង្គម

លោកពញ្ញាក់បញ្ជាក់ប្រាប់បុត្រខេមរា
ចង់ប្រាប់ថាមិនត្រូវចុះចាញ់ជីវិត។
ប្រើវេលាជាប្រយោជន៍សង្គមពិត
ដែលលោកគិតអភិវឌ្ឍន៍ធនធានខ្មែរ។
ជាផ្នែកធំត្រូវខំរៀនឲ្យពូកែ
ឥតប្រួលប្រែប្រាំមួយមុខលោកបង្កើត។
តាមចិត្តចង់FRON OF FICEក៏ល្អឆើត
បានកកើតនៅសៀមរាបឋានឧត្តម ។
ជូនពរជ័យសូមឲ្យលោកបានសុខុម
គឺពួកក្រុមសាងប្រយោជន៍រស់មានន័យ។

ឆ្នាំ ២០១០

និពន្ធ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៤ ខ្មែរចិត្ត

បទ ពាក្យត្រាំម៉ី

១.ឆ្នាំ២០០០ប្លាយសប្បាយណាស់ឬ? មនុស្សមានជម្ងឺឈឺសព្វបែបយ៉ាង
អ្នកឆ្កួតវិជ្ជាពូកែអួតអាង ដឹកនាំកសាងបែបភូតកុហក។
២.អ្នកឆ្កួតអំណាចខ្ញុំខ្លាចញ័រខ្លួន លបលួចបំពួនលក់កេរ្តិ៍មរតក
ខ្ញុំមិនសរសើរថាខ្ញុំអាក្រក់ ជីពជន្មចុងសក់ព្រោះខ្លាចលោកធំ។
៣.ថាបែបធិបតេយ្យបោះឆ្នោតសេរី ប្រជាប្រុសស្រីខ្មែរដ៏ឧត្តម
រើសអ្នកដឹកនាំអភិវឌ្ឍន៍សង្គម ជាប់ឆ្នោតហើយមុំត្រូវរត់ចោលស្រុក។
៤.ដូចគ្នារាល់លើកស្ទើររាល់អាណត្តិ ខ្មែរជួបវិបត្តិមិនសូវបានសុខ
យល់ញាតិឃ្លាតច្បាប់ចេះដឹងជាប់គុកព្រោះមានឪពុកគឺពុករលួយ។
៥.ដីខ្មែររួមតូចខូចចាតធម្មជាតិ វប្បធម៌ក៏ឃ្លាតតើអ្នកណាជួយ?
រក្សាសម្បត្តិដូនតាសែនព្រួយ បើខ្មែរតែមួយម្តេចមានលើក្រោម។

៦. សែនអាសូរពេកទឹកភ្នែកស្រក់ហូរ ខ្ញុំសែនអាសូរអង្គរឆើតឆោម
បាក់បែកសាមគ្គីស៊ីលើស៊ីក្រោម ពេលណាទើបល្មមសមចិត្តជនក្បត់។

៧. ក្បត់ចិត្តគំនិតស្មោះនឹងមាតុភូមិ ប្រាង្គថ្មទួញយំព្រហ្មសែនកំសត់
រៀនបានចេះដឹងប្រឹងរកផ្លូវរត់ ខ្មែរខ្មៅទុរគតក្នុងទ្វីលោកា។

៨. តែស្ករៗថ្មប្រាង្គដុះស្លែ ទេសចរណ៍ហូរហែរខ្មែរមានដុល្លា
ម្តេចខ្មែរនៅក្រក៏ព្រោះនរណា ឬក៏ដូនតាមានកេរ្តិ៍តិចពេក។

៩. រីវត្តអារាមតាមភូមិឃុំស្រុក អ្នកបួសជួបទុក្ខគួរឲ្យសង្វេគ
ទ្រុស្តធម៌វិន័យឆាន់សឹងឆាន់ដេក ព្រោះតែតម្រេកលោភលន់កសាង។

១០. សាងតែវិហារលោករងារពង ពេលខឹងម្តងៗចង់ចេញពីប្រាង្គ
មានឡានមានលុយលួចលុយក៏សាង បើគ្មានសំអាងមិនហ៊ានពោលឡើយ។

១១. បិដកជាប់គុកទុកតែក្នុងទូ ធម៌បរមគ្រូជាអ្នកអាចឆ្លើយ
កាត់ក្តីបុគ្គលអ្នកបួសនោះហើយ នេះជាចំលើយបរិស័ទចង់ស្តាប់។

១២. វត្តធម៌វិន័យមានការភ័យខ្លាច រស់ក្រោមអំណាចខ្លាចណាស់សូមប្រាប់
ពោលធម៌វិន័យគេមិនខ្វីស្តាប់ រស់ស្ងៀមដល់ស្លាប់បដិបត្តិតាមធម៌។

១៣. ចង់កសាងជាតិញាតិមានសាសនា អរហន្តសម្មាសម្ពុទ្ធបវរ
សីលប្រាំចាំច្បាស់បដិបត្តិដោយល្អ រលកលោកធម៌នឹងបានស្ងប់ស្ងាត់។

១៤. មិនដឹងថ្ងៃណាខ្មែរមានវាសនា រុងរឿងអស្ចារ្យដូចព្រះមហាក្សត្រ
សម័យអង្គរមានគុណសម្បត្តិ រ៉ែនពូជខត្តិយវង្សពិត។

១៥. សូមអធ្យាស្រ័យខន្តីសណ្តោស ដល់ខ្ញុំផងចុះដោយក្តីអាណិត
ចង់ឃើញញាតិញោមបានសុខផ្លូវចិត្តសាមគ្គីមូលមិត្តរួមកសាងជាតិ។

៣ៗ[៧] មាឃ រកា ព.ស ២៥៦១

អង្គារ ២៣ មករា ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសុរ្យពេជ្រ

កំណាព្យ ៥ រឿនរស់

បទ ឆ្កាឈូករីករហាច

១. រៀនរស់ត្រេកអរនឹងសម្បត្តិសង្ឃ រៀនរស់ស្លៀកស្បង់គ្រងចីវរសម
រៀនរស់ឲ្យត្រូវនូវភេទឧត្តម រៀនរស់អបរំតាមពុទ្ធឱវាទ។

២. រៀនរស់រៀនគិតរៀនធ្វើរៀនច្នៃ រៀនរស់ឲ្យច្នៃថ្នូរឧត្តមស្អាត
រៀនរស់ប្រោសសត្វត្រាច់ចរបិណ្ឌបាតរៀនរស់នៅស្អាតអនាម័យល្អ។

៣. រៀនរស់សន្តោសតាមព្រះអរិយ រៀនរស់ពោលស្តីគាថាព្រះធម៌
រៀនរស់ជួបជុំសាងមិត្តភាពល្អ រៀនរស់បវរដើរតាមជិនស្រី។

៤. រៀនរស់ឯកអង្គត្រង់ត្រូវផ្លូវមួយ រៀនរស់ឈប់ព្រួយសម្បត្តិលោកិយ
រៀនរស់កត្តញ្ញូបម្រើផែនដី រៀនរស់មានន័យស្គាល់ធាតុទាំងបួន។

៥. រៀនរស់ស្មោះត្រង់ពោលតែពាក្យពិតរៀនរស់ស្គាល់ចិត្តចេតសិកក្នុងខ្លួន
រៀនរស់កាត់បង់កិលេសគុំគួន រៀនរស់មាំមួនសុខភាពបវរ។

៦. រៀនរស់ប្រកបដោយធម៌សុចរិត រៀនរស់ប្រព្រឹត្តតាមឱវាទធម៌
រៀនរស់រៀនយល់ទុក្ខលំបាកក្រ រៀនរស់ដោយល្អមិនបៀតបៀនសត្វ។
៧. រៀនរស់រៀនសព្វសារពើរកិច្ចការ រៀនរស់សិក្សាព្រះធម៌បរិយត្តិ
រៀនរស់សាមគ្គីសិក្សាបដិបត្តិ រៀនរស់ស្ងប់ស្ងាត់គង់បានបដិវេធ។
៨. រៀនរស់ស្គាល់ជាតិហានៈសក្តិយស រៀនរស់រៀនរស់រស់នៅសង្កេត
រៀនរស់ពិនិត្យយល់ចិត្តដូចពេទ្យ រៀនរស់បដិវេធសន្តិបទស្ងប់។

២ ។ ១៣ មាឃ រកា ព.ស ២៥៦១

ច័ន្ទ ២៩ មករា ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៦ ទឹកចិត្តស្មើរនឹងទឹកភ្នែក

បទ ឆ្កាលូកវីក

១. ទឹកចិត្តអរហន្តអរហត្តទាំងឡាយ ទឹកចិត្តអ្នកម្តាយទឹកចិត្តឪពុក
ទឹកចិត្តលោកពិតចង់ឲ្យកូនសុខ ទឹកចិត្តទឹកមុខលោកស្រស់ម្លើះទេ។

២. ទឹកភ្នែកជ្រែកហូរអាសូរពេកពន់ ទឹកភ្នែកព្រះគុណធ្ងន់ធ្ងរគុណទ្វេ
ទឹកភ្នែកព្រះរស់របស់មាសមេ ទឹកភ្នែកឥតល្ហែហូរឥតស្បើយ។

៣. ទឹកហូរមិនហត់សង្កត់ថ្មដា ទឹកហូរប្រាប់ថារកកោះរកត្រើយ
ទឹកហូរកាត់ថ្ពាល់មាសម្តាយកូនអ្ហើយទឹកហូរនេះហើយស្មើរដោយទឹកភ្នែក។

៤. ទឹកចិត្តកត្តញ្ញូស៊ូលះបង់ប្រាណ ទឹកចិត្តសុខសាន្តខ្ងល់ខ្ងាយអនេក
ទឹកចិត្តម៉ែពុកទុក្ខសែនសង្វេគ ទឹកចិត្តទឹកភ្នែកកូនគួររំព្មក។

៥. ទឹកស្រក់តក់ៗទំលុះថ្ម ទឹកស្រក់តៗទាំងយប់ថ្ងៃព្រឹក
ទឹកស្រក់មិនដាច់កូនៗគួរនឹក ទឹកស្រក់សន្ធឹកក្លាយជាជ្រោះកម្ម។

៦. ទឹកពងទឹកថ្លុកអ្នកស្រុកផឹកបាន ទឹកពងលាងចានបានរាល់ខែឆ្នាំ
ទឹកពងម៉ែពុកដងជាប្រចាំ ទឹកពងទឹកភ្លាំប្រចាំវង្សកេរ។

៧. ទឹករសថ្លុកថ្លាវែកចកអោនផឹក ទឹករសប្រមឹកនឹកកាមមាសមេ
ទឹករសជំពាក់វដ្តៈខ្ញុំគេ ទឹករសជាតិស្នេហ៍កត្តញ្ញូត្រូវគិត។

៨. ទឹកចិត្តខន្តីអភ័យទោសា ទឹកចិត្តមាតាបិតាវមិត្រ
ទឹកចិត្តតែមួយព្រួយភ័យស្នេហ៍ស្និទ្ធ ទឹកចិត្តទឹកចិត្តស្ទើរដោយទឹកភ្នែក។

២ ៗ ១៣ មាឃ រកា ព.ស ២៥៦១

ច័ន្ទ ២៩ មករា ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៧ ចាំពេលមួយ

បទ ឆ្ការលូកវីក

១.ចាំមើលតែផ្លូវកូនពៅពន្លក	ចាំមើលម៉ែមកពីផ្សារវិលវៃ
ចាំមើលតែផ្លូវអ្នកម្តាយពិសី	ចាំមើលចំណីនំមាតាផ្ទើរ។
២.ចាំអើយសែនចាំៗជាប់ដួងចិត្ត	ចាំអើយស្នេហ៍ស្និទ្ធអ្នកធ្វើដំណើរ
ចាំអើយមាសសួនស្រស់ស្រីប្រសើរ	ចាំអើយប្រហើរម៉ែស្លឆ្ទុយឆ្ងាញ់។
៣.ពេលកូនមកបួសកូនរស់បែបសង្ឃ	ពេលកូនស្លៀកស្បង់ចីវរគួរក្នាញ់
ពេលកូនបិណ្ឌបាតគួរឲ្យស្រលាញ់	ពេលកូនចុះចាញ់ម៉ែជួយស្មារតី។
៤.ពេលដែលកន្លងផ្សងជួបជុំគ្នា	ពេលដែលកំព្រាម៉ែឃ្លាតចាកប្តី
ពេលដែលពុកស្លាប់ចាកចោលផែនដី	ពេលដែលគ្មានអ្វីទើបកូនស្រណោះ។
៥.មួយនឹកបិតាមួយនឹកមាតា	មួយនឹកស្នេហាដែលខ្លួនស្ម័គ្រស្មោះ
មួយនឹកបងប្អូនគ្រាក្រកាលនោះ	មួយនឹកស្រណោះកាលវ័យកុមារ។

៦.កូនលេងប្រទ្បែងតែងជាប់នឹងភ្លៅ កូនលេងនិត្យនៅលើភ្លៅប៉ា។
កូនលេងជាមួយអ្នកម៉ាក់ផងណា កូនលេងចរចារចងចិត្តចាំជាក់។
៧.ឥឡូវឯកាឯកោម្នាក់ឯង ឥឡូវចម្បែងត្មែងរកអ្នកស្ម័គ្រ
ឥឡូវចង់បានមានប៉ាមានម៉ាក់ ឥឡូវមិត្តភក្តិមានគូអស់ហើយ។
៨.ទើបដឹងរសជាតិទើបស្គាល់ស្នេហា ទើបដឹងអនិច្ចាសង្ខារសត្វអើយ
ទើបដឹងជាទុកមិនមែនខ្លួនឡើយ ទើបដឹងចម្លើយកើតចាស់ឈឺស្លាប់។

២ ។ ១៣ មាឃ រកា ព.ស ២៥៦១

ច័ន្ទ ២៩ មករា ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៨ អ្នកជាអ្វី?

បទ ផ្កាឈូករីក

១. មនុស្សឆ្លាតធ្វើការងារមានតម្លៃ មនុស្សឆ្លាតចេះច្នៃកាលពេលវេលា
មនុស្សឆ្លាតចេះធម៌រស់ផុតកម្មពៀរ មនុស្សឆ្លាតគ្រប់គ្នារស់នៅគ្មានខ្ពុំ។

២. អ្នកល្ងង់លង់កាមតាមភ្លក់តាមលិខ អ្នកល្ងង់ឥតគិតខ្វះការអប់រំ
អ្នកល្ងង់គំនិតចង់ធ្វើតែធំ អ្នកល្ងង់ជួបជុំបំផ្លាញតែទ្រព្យ។

៣. អ្នកឆោតល្ងីល្ងើលីលើខុសបទ អ្នកឆោតកំសត់ក្រីក្រទាល់ងាប់
អ្នកឆោតឆើតឆាយធ្វើតាមទម្លាប់ អ្នកឆោតឥតជាប់ពូជតម្លង់ពិត។

៤. អ្នកជាបណ្ឌិតតែងរួចទោសភ័យ អ្នកជាកវីសិក្សាពីចិត្ត
អ្នកជាមិនល្ងង់ឆោតគ្មានគំនិត អ្នកជាអ្វីពិតគង់ដឹងខ្លួនឯង។

២ ។ ១៣ មាឃ រកា ព.ស ២៥៦១

ច័ន្ទ ២៩ មករា ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៩ បួសមិនរៀនធម៌

បទ ឆ្ពាលូកវ៉ក

១. បួសមិនរៀនធម៌ញ័រផ្លោកញាក់ដៃ បួសព្រោះនិស្ស័យសង្សាបែកចិត្ត
បួសព្រោះខ្ជិលរៀនដ្បិតគ្មានគំនិត បួសជាបណ្ឌិតរៀនធម៌បដិបត្តិ។

២. អ្នកបួសខិលខូចអាប់អោនសាសនា អ្នកបួសជ្រះថ្លាសិក្សាបរិយត្តិ
អ្នកបួសប្រពៃរស់នៅស្ងប់ស្ងាត់ អ្នកបួសកំចាត់តណ្ហាទាំងឡាយ។

៣. កុំបួសត្រឹមស្បង់ត្រឹមគ្រងចីវរ កុំបួសភូតភរត្រឹមតែសប្បាយ
កុំបួសបោកញោមល្មមបួសតែកាយ កុំបួសក្អាកក្អាយដូចហីនភេទ។

៤. បព្វជិតសង្រួមពិតជាប្រពៃ បព្វជិតមានន័យបួសរៀនសង្កេត
បព្វជិតមានសីលរស់មិនធ្វើពេទ្យ បព្វជិតកើតអេដស៍គួរឲ្យសង្ស័យ។

៥.ព្រាហ្មណ៍តែងរស់នៅមិនសាងបាបកម្មព្រាហ្មណ៍រស់ដោយថ្នាំព្រហ្មវិហារថ្លៃ
ព្រាហ្មណ៍រក្សាចិត្តឲ្យល្អប្រពៃ ព្រាហ្មណ៍រស់ក្នុងព្រៃកាប់ឆ្ការកិលេស។

៦. សមណៈអ្នកបួសរស់ទ្រទ្រង់ធម៌ សមណៈបវរមានធម៌ពិសេស
សមណៈអ្នកបួសរស់មានចំណេះ សមណៈពាក្យនេះប្រើសម្រាប់សង្ឃ។

៧. ភិក្ខុអ្នកស្មូមល្មមរស់ដោយសុខ ភិក្ខុនិរទុក្ខបវរផ្លូវផង់
ភិក្ខុចេះដឹងទើបដើរផ្លូវត្រង់ ភិក្ខុដែលល្ងង់បួសសឹក។។

៨. សាមណេរបព្វជ្ជាសទ្ធាមុតមាំ សាមណេរស៊ូទ្រាំការឆាន់ការផឹក
សាមណេរនៅក្មេងត្រូវការរំឭក សាមណេរល្ងាចព្រឹកត្រូវធ្វើកិច្ចវត្ត។

៩. នេះរឿងអ្នកបួសរស់ក្នុងសាសនា នេះរឿងកិច្ចការចារជាប្រវត្តិ
នេះរឿងអ្នកបួសល្អ និង ភ្លាំងភ្លាត់ នេះរឿងមុខមាត់ក្នុងពុទ្ធសាសនា។

៥ ។[៩] មាឃ រកា ព.ស ២៥៦១

ព្រហស្បត្តិ៍ ២៥ មករា ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ១០ អស់ខ្លះ

បទ ពាក្យឆ្នាំថ

១. ថ្ងៃមិនទាន់រះនៅព្រឹកព្រហាម តែថ្ងៃរះភ្លាមឈ្មោះថាអរុណ
សូរិយារៀងរះគួរឲ្យគយគន់ សុភាពទន់ភ្លន់សត្វចេញរកស៊ី។
២. សត្វមានបញ្ញារស់រកដោយស្រួល សត្វដែលក្តុកក្តួលរកស៊ីវក់វី
សត្វដែលវង្វេងវឹកវរវរក់វី សត្វមាននាទីរស់រកធ្វើអ្វី?
៣. មនោវិញ្ញាណនិទានពីចិត្ត មនោជីវិតស្មែករកសេរី
កំណើតសត្វលោកជាប់វដ្តៈភ័យ ស្តាប់ព្រះជិនស្រីផុតភ័យកន្លង។
៤. បើប្រាថ្នាច្រើនចម្រើនតែទុក្ខ បើចង់បានសុខលះទុក្ខសៅហ្មង
បើមានផ្លូវដើរសម្រាប់ញាតិផង ធ្វើជាស្ពានឆ្លងចម្លងអរហន្ត។
៥. ដូចពោធិសត្វកាត់បង់តណ្ហា លាក្រុមគ្រួសារសម្បត្តិរាប់ពាន់
ឃើញភ័យវឹកវរវរស់រកអាសន្ន ឃើញព្រះភគវនទើបទ្រង់ប្រាថ្នា។
៦. សង្ឃឹមជាតិនេះបានបួសសងគុណ លះលាប្រពន្ធសង្គ្រោះមាតា
បិតាផងចុះដែលលោកមរណា ឧទ្ទិសផលាមហាកុសល។
៧. ហើយលោកត្រេកអរទទួលសាធុសូមលោកអស់ទុក្ខសោយសុខភោគផល
ភោគសម្បត្តិទិព្វនិមិត្តបានដល់ អស់ទុក្ខខ្ជាយខ្ជល់ដល់ព្រះនិព្វាន។

១ ។ ១៣ មាឃ រកា ព.ស ២៥៦១

អាទិត្យ ១៤ មករា ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ១១ សម្រស់

បទ ឈូករីករហាច់ពីរស្រទាប់

១. សម្រស់ព្រៃភ្នំជំរំអ្នកបួស សម្រស់ទឹកជ្រោះលម្អធម្មជាតិ
សម្រស់សាសនារក្សាផៅញាតិ សម្រស់ទាយាទអ្នកទ្រទ្រង់ធម៌។
២. សម្រស់ភិក្ខុបញ្ញាហានៈ សម្រស់សូរ្យពេជ្រពិតបវរ
សម្រស់សិក្សាស្នេហាគុណធម៌ សម្រស់ធ្វើល្អរៀនធម៌បរិយត្តិ។
៣. សម្រស់មាតុភូមិកម្ពុជាអង្គរ សម្រស់នរគមានភាពស្ងប់ស្ងាត់
សម្រស់ពលរដ្ឋសិក្សាបរិយត្តិ សម្រស់សព្វសត្វលម្អលោកា។
៤. សម្រស់សៀវភៅលម្អវិជ្ជា សម្រស់អគារស្អាតដោយរចនា
សម្រស់កូនសិស្សខិតខំសិក្សា សម្រស់សាលាល្បីដោយសិស្សគ្រូ។
៥. សម្រស់មាតាបិតាមានគុណ សម្រស់គិតគន់កូនត្រូវកត្តញ្ញូ
សម្រស់មួយនេះដែលលោកតស៊ូ សម្រស់គំរូប្រពៃណីខ្មែរ។
៦. សម្រស់កុលបុត្រស្លៀកពាក់សមរម្យសម្រស់សង្គមទឹកដីមាសស្នេហ៍
សម្រស់មនសិការខេមរាចិតថៃ សម្រស់ពាក្យម៉ែពាក្យពុកទូន្មាន។

៧. សម្រស់ក្បួនខ្នាតឱវាទជិនស្រី សម្រស់វិន័យធម៌ត្រូវសូត្ររៀន
សម្រស់សង្ឃសត្យកុំរៀនបៀតបៀនសម្រស់សីលទាននិងភាវនា។
៨. សម្រស់សង្ឃសត្យបដិបត្តិសង្ឃម សម្រស់ដល់ព្រមអង្គត្រៃសិក្ខា
សម្រស់បព្វជិតជីវិតឯកា សម្រស់លោកណាអស់ភពវដ្តៈ។
៩. សម្រស់ក្នុងលោកគគោកច្រើនក្រៃ សម្រស់តាមវ័យកើតចាស់មរណៈ
សម្រស់ស្រស់ស្អាតស្រើបស្រាលរាគៈសម្រស់អន្ទាក់កូនទេវបុត្រមារ។
១០.សម្រស់ៗ ភិក្ខុទាំងឡាយ សម្រស់សប្បាយរស់ដោយធម្មា
សម្រស់ស្រស់នេះមិនចាស់ជរា សម្រស់ពុំងារបួសហើយកុំស្តាយ។
១១.សម្រស់ធ្មេញសក់ក្រចកស្បែកឆ្អឹង សម្រស់ព្រលឹងពាលពៅឆោមឆាយ
សម្រស់ទាំងនេះគង់តែអន្តរាយ សម្រស់រូបកាយជរាគ្មានសល់។
១២.សម្រស់សព្វសត្វបដិបត្តិតាមធម៌ សម្រស់បវរអស់ទុក្ខកង្វល់
សម្រស់គុណជាតិគុណព្រះទសពលសម្រស់អស់ខ្វល់ប្រោសសត្វផុតទុក្ខ។

៦ ៗ ៩ មាឃ រកា ព.ស ២៥៦១

សុក្រ ៩ កុម្ភៈ ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ១២ កើតមក

បទ ឈូកវីករហាច់មួយស្រទាប់

១. កើតស្លាប់ៗសម្រាប់សង្សារ	កើតវដ្តអនិច្ចាទុក្ខឥតស្រាកស្រាន្ត
កើតឃ្លានខឹងស្អប់មិនចប់ភពឋាន	កើតបានប៉ុន្មានត្រឹមមួយរយឆ្នាំ។
២. កើតមករូបល្អក៏ជាប់ជំពាក់	កើតមកគេស្ម័គ្រស្មោះស្នេហ៍ចិត្តចាំ
កើតមកអាក្រក់កវីសូមផ្តាំ	កើតមកយកកម្មបៀតបៀនសព្វសត្វ។
៣. កើតមកប្រឹងរស់ទាំងគ្មានសម្បទា	កើតមកវេទនាជាគុណវិបត្តិ
កើតមកចង្រៃគ្មានគុណសម្បត្តិ	កើតមកស្ងបស្ងាត់គ្មានយសបរិវារ។
៤. កើតមកដើម្បីទទួលទុក្ខទោស	កើតមកដូចខុសប្លែកមនុស្សធម្មតា
កើតមកខ្វង់គថ្លង់ពិការ	កើតមកសោកាជោគដោយទឹកភ្នែក។
៥. កើតមករស់នៅដូចជាសត្វធាតុ	កើតមកគ្រប់ជាតិគួរឲ្យសង្វេគ
កើតមកបានរស់ត្រឹមបាយមួយវែក	កើតមកអនេកជាតិរាប់មិនអស់។
៦. កើតមកជាមនុស្សរស់ដូចជាប្រេត	កើតមកដើមហេតុតាមកម្មខ្លួនសោះ
កើតមកខ្វះខាតគួរសែនស្រណោះ	កើតមកក្រៀមក្រោះក្រំក្រៀមឯកា។
៧. កើតមកជាមនុស្សរស់ដូចជាយក្ស	កើតមកទោសៈរាគៈមោហា

កើតមកវង្វេងសម្បត្តិកាយា កើតមកឫស្យាមិនរក្សាទ្វារ។

៨. កើតមកជាមនុស្សរស់ដូចនរក កើតមកលាមកប្រព្រឹត្តពាលា
កើតមកសន្សំចងកម្មចងពៀរ កើតមកវេទនារងទុក្ខជានិច្ច។

៩. កើតមកជាមនុស្សរស់ដូចតិរិច្ឆាន កើតមកសាមាន្យបានខាងកំទេច
កើតមកបំពានហ៊ានធ្វើបែបភ្លេច កើតមកធ្វើកិច្ចដែលសង្គមខ្ពើម។

១០.កើតមកមិនស្គាល់កូនចៅប្រពន្ធ កើតមកទោសធ្ងន់កាមគុណចាប់ផ្តើម
កើតមកជួរជាតិគួរខ្ពើមរអើម កើតមកឆ្លាតឆ្មើមរំលោភកូនឯង។

១១.កើតមកជាមនុស្សរស់ដូចជាមនុស្ស កើតមកមានយសរស់ចេះខ្លាចក្រែង
កើតមកបាបបុណ្យនឹងតាមចាត់ចែងកើតមកប្រឹងប្រែងតាក់តែងកុសល។

១២.កើតមកមួយជាតិធាតុត្រឹមមួយចាន កើតមកកុំស្មានបានចេះយល់ដឹង
កើតមកមិនរស់រៀនសូរៀនឆ្ងល់ កើតមកខ្វល់ខ្វាយតែនឹងកាមគុណ។

១៣.កើតមកមកកើតកើតហើយកើតទៀតកើតមកចង្អៀតមករស់ទម្ងន់
កើតមកបង្កើតរកកូនប្រពន្ធ កើតមកខ្វះបុណ្យទុក្ខវេទនាណាស់។

៦ ។ ៩ មាឃ រកា ព.ស ២៥៦១

សុក្រ ៩ កុម្ភៈ ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ១៣ ទុក្ខ

បទ ចាប់តំណ

១. ទុក្ខក្រៀមក្រំក្រំក្រៀមចិត្តចិត្តស្រពោន
ទុក្ខក្រកូនកូនក្រដឹងដឹងចិត្តឪ
ទុក្ខពេកពន់ពន្ធអាកក៏ចាំផ្លូវ
ទុក្ខជាប់នៅនៅតាមជាប់ជាប់ចិត្តកាម។

២. ទុក្ខអើយទុក្ខទុកជាប់ប្រាណប្រាណសៅហ្មង
ទុក្ខអូនបងបងប្អូនយើងយើងតែងតាម
ទុក្ខអើយទុក្ខទុក្ខសោកស្តាយស្តាយម្តែសាម
ទុក្ខជិតស្នាមស្នាមរងកម្មកម្មរងទុក្ខ។

៣. ទុក្ខថ្ងៃនេះនេះថ្ងៃបុណ្យបុណ្យបូជា
ទុក្ខភគវាលាពួកយើងយើងចាំទុក
ទុក្ខខែមាឃមាឃថ្ងៃសោកសោកជួបសុខ
ទុក្ខជួបទុក្ខទុក្ខជ្បិតខ្ញុំខ្ញុំតណ្ហា។

៤. ទុក្ខព្រោះកម្មកម្មកាយចិត្តចិត្តជាប់ជួន
ទុក្ខព្រោះខ្លួនខ្លួនមានកាមកាមសញ្ញា
ទុក្ខខ្លោចផ្សារផ្សារអួលក្តៅក្តៅម្ល៉េះណា
ទុក្ខបុគ្រាគ្រាតែអស់អស់កិលេស។

៥. ទុក្ខរយឆ្នាំឆ្នាំម្តែប្លាយប្លាយចេញបួស
ទុក្ខពេកហួសហួសថ្លាថ្លែងថ្លែងច្រើនម្ល៉ះ
ទុក្ខព្រោះព្រៃព្រៃស្តុកក្រាស់ក្រាស់កិលេស
ទុក្ខដូច្នេះនេះកាមភពភពស្លាប់កើត។

៦. ទុក្ខអើយទុក្ខទុកបុណ្យខ្ញុំខ្ញុំឯណា?
ទុក្ខសោកាការកើតចាស់ចាស់ជើងឆើត
ទុក្ខឈឺច្រើនច្រើនឈឺចាប់ចាប់កំណើត
ទុក្ខការកើតកើតចាស់ស្លាប់ស្លាប់ឥតន័យ។

៧. ទុក្ខច្រើនក្រៃក្រៃក្រាស់កាមកាមតណ្ហា
ទុក្ខនេះណាណាអ្នកអើយអើយពិសី
ទុក្ខរាល់រូបរូបជួបទុក្ខទុក្ខប្រុសស្រី
ទុក្ខភិតភ័យភ័យរាល់រូបរូបរាល់អ្នក។

៨. ទុក្ខបាត់សោកសោកបាត់ទុក្ខទុកភគវន
ទុក្ខអរហន្តលោកអស់ទុក្ខទុក្ខរាគៈ
ទុក្ខសាស្តាស្តារបាបកម្មកម្មលោកអ្នក
ទុក្ខអស់លក្ខណ៍លាក់ពួកមារមារវដ្តៈ។

៤ ។[១៥] មាឃ រកា ព.ស ២៥៦១
ពុធ ៣១ មករា ២០១៨
និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យរឿង ១៤ ភិក្ខុកំលោះ

បទ ពាក្យត្រាំបី

១. ភិក្ខុកំលោះងាយនឹងរងគ្រោះ ភិក្ខុអាប់យសព្រោះរឿងស្នេហា
ភិក្ខុកំលោះក្នុងពុទ្ធសាសនា សើចឈ្លោះចរចាធីតាចៅស្រី។

២. ក្រមុំញេមញ៉ុមក្រមុំកញ្ញា ចៅវិសាខាធីតាប្រពៃ
ឆ្លុះមើលផ្ទៃទឹកញញឹមប្រិមប្រិយ សើចមិនពោលស្តីស្រីស្ងើចរូបឯង។

៣. ភិក្ខុកំលោះនៅមិនស្ងៀមសោះ ចង់តែញ៉ោះញ៉ោះលេងសើចកំប្លែង
ភិក្ខុកំលោះធ្វើសើចម្នាក់ឯង កន្តោចកន្តែងមើលនាងក្រមុំ។

៤. នែ!អ្នកនាងកញ្ញាឃើញលឺលោកម្ចាស់សើចលឺហាស!ហាស!នាងខ្មាស់នាងយំ
សើចអីលោកម្ចាស់មកសើចដាក់ខ្ញុំ នាងស្រីក្រមុំជេរស្តីលោកថា។

៥. នែ!លោកដាច់ក្បាលអ្នកមានក្បាលដាច់លោកខឹងប្រកាច់តបពោលដីកា
អ្នកណាក្បាលដាច់អ្នកនាងកញ្ញា ជីដូនជីតាអ្នកឯងក្បាលដាច់។

៦. ស្រីស្រស់ខឹងណាស់ទៅប្រាប់ម្ចាស់យាយទឹកភ្នែកឡំលាយប្រាប់យាយរួចស្រេច
ភិក្ខុកំលោះគេចោទក្បាលដាច់ យាយចៅសម្រេចសម្រុះសម្រួល។

៧. ឯលោកកំលោះមិនអស់ចិត្តឡើយ ខឹងធ្វើកន្តើយក្តៅឆេវរំជួល
ប្តឹងដល់ព្រះអង្គហើយលោកក្រាបទូលចិត្តក្តៅក្តុកក្តួលយាយកាន់ជើងចៅ។

៨. ព្រះអង្គដឹងចិត្តភិក្ខុនោះណា ព្រះពុទ្ធដីកាថាភិក្ខុត្រូវ
ភិក្ខុកំលោះឈប់មុខក្រម៉ូវ ទ្រង់ត្រាស់សំដៅនាងវិសាខា។

៩. ម្តេចក៏ចៅស្រីយាយពោលដូច្នេះ ទ្រងព្រះតម្រេះទ្រង់សួរហេតុការណ៍
ចៅស្រីក្រមុំឧបាសិកា ចោទបុត្រសាស្តាថាជនក្បាលដាច់។

១០.ឧបាសិការៀបរាប់សេចក្តី ពិតព្រះជិនស្រីរួចរាល់ជាស្រេច
អំពីពាក្យចៅពោលថាក្បាលដាច់ ដ្បិតភិក្ខុប្តេជ្ញាកាត់នខា។

១១.កោរសក់ពុកមាត់កាតជាយចីវរ រស់ទ្រទ្រង់ធម៌តាមត្រៃសិក្ខា
ភិក្ខុសង្ឃមិនមានទោសា មិនមានស្នេហាធីតានោះទេ។

១២.ព្រះពុទ្ធគាំទ្រសាទរសាធុ ភិក្ខុនិរទុក្ខចូរអ្នករិះរេ
ភិក្ខុកំលោះរិះគិតគន់ទ្វេរ ក្រមុំមាសមេពោលត្រូវមែនហើយ។

១៣.ខ្លួនពិតក្បាលដាច់ស្រេចដូចស្រីថា កើតវិបស្សនាអនិច្ចារកត្រើយ
ទុក្ខំអនត្តារស់មិនយូរឡើយ ចប់ទេសនាហើយសម្រេចសោតា។

១៤.រតនាចារចែងក៏នៅកំលោះ សូរ្យទុកឈ្មោះរស់ដូចសូរិយា
ដូចកុយរមាសរស់នៅឯកា កុំឈ្លោះកញ្ញាចារជាប់ប្រវត្តិ។

៦ ៗ ៩ មាឃ រកា ព.ស ២៥៦១

សុក្រ ៩ កុម្ភៈ ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យរឿងទី ១៥ ព្រះអានន្ទ

បទ ពាក្យស្រាំបី

១. អង្គព្រះអានន្ទបន្ទន់ឥរិយា គួរឲ្យជ្រះថ្លាពេកពន់កន្លង
គោរពថេរៈជាក់ច្បាស់ឥតឆ្គង ជាប់ទោសបីដងថាជាអាបត្តិ។

២. បឋមសង្គាយនាទីមួយពិត ប្រជុំល្អល្អិតឃ្លាំងធម៌បរិយត្តិ
មុខបាឋចាំស្ទាត់មិនបាត់ រក្សាស្ងប់ស្ងាត់គ្មានចារគម្ពីរ។

៣. កាលព្រះសាស្តាបរិនិព្វាន បីខែណាទានកស្សបស្តីទី
ប្រាំរយអង្គឯករចនាសំភី អានន្ទឧបាលីឆ្លើយយ៉ាងពីរោះ។

៤. ព្រះអភិធម្មអត្ថន័យជ្រាលជ្រៅ កស្សបសួរទៅឥតទាក់អ្វីសោះ
បញ្ញាអានន្ទក្នុងកាលគ្រានោះ តែត្រូជាប់ទោសមានបីប្រការ។

៥. ទីមួយទោសនោះមានរឿងប្រាកដ ពិម្ពារកំសត់អោបព្រះសាស្តា
ត្រង់ព្រះបាទាញីញក់កេសា អានន្ទរក្សាត្រូវមានទោសពៃ។

៦. ទីពីរអានន្ទឲ្យមាតុគ្រាម ដែលមានព្រះនាមនាងគោតមី

យំនៅក្លោងទ្វារដល់ពេលរាត្រី ឯទោសទីបីមិនអារាធនា ។

៧. អង្គព្រះសាស្តាគង់អស់មួយកប្ប ព្រះថេរៈប្រាប់ទោសទាំងបីគ្រា
អានន្ទតូចតន់ពិនិត្យធម្មា ទាំងបីវេលាឥតមានទោសពិត។

៨. តែព្រះអានន្ទជនប្រដៅងាយ អានន្ទរីករាយធ្វើតាមគាប់ចិត្ត
តាមព្រះថេរៈយ៉ាងល្អពិសិដ្ឋ នេះជាគំនិតប្អូនគោរពបង។

៩. ការស្តាប់ធ្វើតាមជាច្បាប់ទម្លាប់ ការស្តាប់បង្គាប់គំនាប់រៀមច្បង
ការស្តាប់ឱវាទឃើញទោសឆ្ងាំឆ្ងង ឃើញទោសតបផងនាំឲ្យចម្រើន។

៥ ។[1] បុស្ស រកា ព.ស ២៥៦១
ព្រហស្បត្តិ៍ ១៥ កុម្ភៈ ២០១៨
និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យរឿងខ្លី ១៦ កូនល្ងង់

បទ ពាក្យត្រាំមី

១. កាលពីបុរាណបានដឹងប្រវត្តិ មនុស្សល្ងង់កាប់ភ្លាត់កាប់មូសសត្វ
បែកក្បាលឪពុកជាពីរកំណាត់ ក្សិណក្ស័យស្លាប់បាត់ទោសធ្លាក់នរក។

២. បរមពោធិសត្វបានឃើញហេតុការណ៍ឪប្រើបុត្រាប្រហារមូសនក
មូសនេះរំខានការងារធ្វើជក់ ឯកូនគំរក់ដេញមូសឲ្យឪ។

៣. ទៅយកពូថៅមុខមុតសស្លាច កាប់មូសគួរខ្លាចឈាមសាចកាប់ត្រូវ
មូសទុំលើក្បាលពុកលែងតាំងនៅ កាប់បានយ៉ាងជ្រៅស្លាប់ឪទៀតផង។

៤. ស៊ូមានសត្រូវអ្នកប្រាជ្ញបណ្ឌិត ស៊ូកុំនៅជិតពាលល្ងង់សៅហ្មង
នាំទុក្ខដល់ប្រាណខានជួបប្អូនបង រឿងនេះចងក្រងជាសក្ខីភាព។

៥ ៗ[1] បុស្ស រកា ព.ស ២៥៦១

ព្រហស្បត្តិ៍ ១៥ កុម្ភៈ ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យរឿងខ្លី ១៧ ក្អែកឃ្លានសាច់អាំង

បទ បថ្យាវត្ត

១. កាលពីព្រេងនាយបានលឺមកថា ក្អែកខ្មៅនោះណាឃ្លានស៊ីសាច់អាំង
បៃបស្តាយអឺរ៉ុបកាណាដាបារាំង ខ្មែរចិនកន្លាំងឲ្យឆ្ងាញ់មាត់ម្តង។

២. ធ្វើជាលួងលោមសេកសោមពោធិ សុចិបុលិគិតសួរសាសង
សុំសេករស់នៅជាមួយសេកផង សុំធ្វើជាបងគោរពបូជា។

៣. ជួយរកចំណីជួយរកអាហារ ជួយយកអាសារសេកស្រស់ពុំងារ
ពោលពាក្យពីរោះបានរស់ជុំគ្នា ពុតត្បុតមាយាចង់ស៊ីសាច់សោះ។

៤. សេកតបទៅក្អែកតាមអធ្យាស្រ័យ សេកមានហឫទ័យអាណិតស្រណោះ
ដល់ក្អែកក៏នាំដោយក្តីសង្រ្គោះ ពោលពាក្យពីរោះទូន្មានក្អែកថា។

៥. ចូរកុំប្រមាទរស់ដោយស្មារតី ស្វែងរកចំណីតាមអង្គអាត្មា
អ្នកកុំខ្ជិលឡើយប្រឹតប្រឹងឧស្សាហ៍ស្វែងរកអាហារតាមអធ្យាស្រ័យ។

៦. ក្អែកជាសត្វខ្ជិលខិលខូចមាយា រកស៊ីជុំគ្នាបានពីរបីថ្ងៃ
ក្អែកជាទេវទត្តជាសត្វចង្រៃ ហេតុតែនិស្ស័យពុតដេកទល់ភ្លឺ។

៧. ថ្ងៃនេះសេកដាស់ឲ្យចេញរកឆី ទៅរកចំណីធ្វើពុតជាឈឺ
ដេកថ្ងូរក្តៅខ្លួនឲ្យសត្វសេកលឺ សេកដឹងជម្ងឺក្អែកឃ្លានសាច់អាំង។

៨. ចុងភៅផ្ទះបាយរបស់សេដ្ឋី ធ្វើម្ហូបចំណីទុកដាក់គ្របឆ្នាំង

ក្អែកបានឱកាសលួចពាំសាច់អាំង ដុំធំទុកតាំងលួចលេបចឹកឆី។
៩. ចុងភៅបាត់សាច់ប្រកាសដើរក ឃើញក្អែកលួចមកទុកធ្វើចំណី
ថាអញសព្វថ្ងៃរស់ដោយសេដ្ឋី យី!ក្អែកអប្រិយថ្លើមធំពាសមេឃ។
១០. បិទទ្វារចាប់ក្អែកបោចរោមលាបប្រេងប្រឡាក់ប៊ីចេងអំបិលច្រើនពេក
ក្អែកដេកកំសត់គួរឲ្យសង្វេគ មិនស្តាប់ពាក្យសេកទឹកភ្នែកសោកា។
១១. បុគ្គលកាលបើមានអ្នកទូន្មាន មិនស្តាប់មិនរៀនរៀបចំឥរិយា
ពាក្យពិតពីរោះមានន័យខ្លឹមសារ ត្រូវស្លាប់មរណាដូចក្អែកមិនខាន។

៥ ។[1] បុស្ស រកា ព.ស ២៥៦១

ព្រហស្បត្តិ៍ ១៥ កុម្ភៈ ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យរឿងខ្លី ១៨ ស្វាអ្នកថែសួន

បទ ពាក្យស្រាំ៥

១.ថ្ងៃបុណ្យគេលេងសប្បាយរីករាយ កាលពីព្រេងនាយអ្នកថែសួនច្បារ
ចង់ទៅកំសាន្តបែទុកចិត្តស្វា ចង់ទៅទស្សនាសិល្បៈតន្ត្រី។
២.ទៅសួរមេស្វាមេហ្វូងទាំងឡាយ អញទៅសប្បាយមើលស្វាយផងវី!
ដ្បិតថាសួននេះផ្លែផ្កាត្រួយខ្ចី ធ្វើជាចំណីឯងឆីរាល់ថ្ងៃ។
៣.មេស្វាស្តាប់ហើយឆ្លើយឆ្លងយ៉ាងស្រួលរួចក៏បបួលហ្វូងដោយប្រពៃ
យកចាំងស្បែកឈើដែលលោកម្ចាស់ថ្លែនាំផូនផ្ចាល់ដៃមុនទៅបុណ្យទាន។
៤.ស្វាគិតគ្នាថាពួកយើងទាំងឡាយ ដងទឹកស្រោចស្វាយដំណាំដែលមាន
ត្រូវស្តាប់តាមយើងជាមេប្រធាន ទឹកដងប៉ុន្មានយើងដងហត់ណាស់។
៥.ទឹករបស់ថ្លៃសំចៃចេះគិត ត្រូវដកមើលពិតឬសណាស្អែកស្អុះ
ឬសវែងមើមច្រើនត្រូវស្រោចឲ្យក្រាស់បើមានតិចខ្លះស្រោចតិចបានហើយ។
៦.ដកស្រោចរួចដាំសែនសង្វេគសត្វ ម្តេចក៏បដិបត្តិមិនយល់សោះឡើយ
ព្រះពោធិសត្វឃើញដូច្នោះហើយ បណ្ឌិតឃើញត្រើយទើបធ្វើប្រយោជន៍។
៧.ចង់សាងកុសលតែឥតប្រាជ្ញា ចង់ធ្វើកិច្ចការល្ងង់ខ្លៅនាំខ្លាច
រុក្ខជាតិក្នុងសួនត្រូវងាប់ហិនហោច ស្វាឃើញប្រយោជន៍តែមិនយល់ការ។

៥ ។[1] បុស្ស រកា ព.ស ២៥៦១
ព្រហស្បត្តិ៍ ១៥ កុម្ភៈ ២០១៨
និពន្ធ ភិក្ខុ បញ្ញាហ៊ានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យរឿងខ្លី ១៩ បង្ហួយពាក់មាស

បទ ពាក្យត្រាំបី

១. សម័យអតីតព្រះបាទព្រហ្មទត្ត រឿងរ៉ាវប្រវត្តិក្នុងពុទ្ធសាសនា
បង្ហួយពាក់មាសនៅក្នុងសួនច្បារ ថ្ងៃមួយចេស្តាត្រាស់សួរមហោសថ។
២. អនុជប្អូនតន់គន់មើលបង្ហួយ រួបរួមជាមួយបងច្រើនបំផុត
កាលមុនបង្ហួយនេះចេះអោនលុត បង្គំលំអុតអោនអង្គក្បាលចុះ។
៣. ថ្ងៃនេះបង្ហួយហាក់ធ្វើព្រងើយ ធ្វើឬកកោងឈ្លើយអូនគន់មើលនោះ
មហោសថលំអុតអោនអង្គក្រាបចុះ ហេតុភេទដូចច្នោះបពិត្រក្សត្រា។
៤. ម្សិលមិញថ្ងៃសីលនៅក្នុងនរគ សេនាដើរកសាច់ជាអាហារ
មិនបានសោះឡើយទើបនាយសេនាយកមាសនោះណាពាក់ឲ្យបង្ហួយ។
៥. បង្ហួយបានមាសតាំងខ្លួនដូចស្តេច ធ្លាប់បានស៊ីសាច់មិនបាច់ភ័យព្រួយ
ត្រឹមបានមាសពាក់ធ្វើឯងលេខមួយ មិនពឹងគេជួយក៏មិនខ្វះឆី។
៦. អង្គព្រះរាជាបញ្ជាសេនា ដកហូតមាសក្តាវាចាក្សត្រិយ
បង្ហួយបានមាសមានះអប្រិយ ធ្វើឬកចក្រីដូចអញផងតើ!
៧. បង្ហួយអត់លិខុជីវិតបិះក្ស័យ មហោសថឆ្លាតវៃយាងស្តេចដំណើរ
បង្ហួយអស់អួតឆ្ពួតឬកគ្រាន់បើ អ្នកដែលប្រសើរចេះបន្ទាបខ្លួន។

៥ ។[1] បុស្ស រកា ព.ស ២៥៦១

ព្រហស្បត្តិ៍ ១៥ កុម្ភ: ២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ២០ ម្លប់ពោធិបារមី

បទ ជាកំនង់ព្រះពុទ្ធសាសនា

១. ព្រះមានព្រះភាគទ្រង់ត្រាស់ថា	មានតែចិន្តាសុខស្ងប់តែមួយ
ជាបរមសុខភាពជំនួយ	ឥតមានទុក្ខព្រួយរស់សោយសុខា។
២. ព្រះធម៌ជួយបំភ្លឺផ្លូវពិត	ព្រះសង្ឃពិសិដ្ឋពិតទ្រង់រក្សា
ព្រះអង្គទ្រង់មានត្រៃសិក្ខា	មនុស្សនិងទេព្តាសាធុសាទរ។
៣. ថ្ងៃនេះមានភ័ព្វជោគលាភល្អ	ត្រេកអរស្តាប់ធម៌កាត់ថ្លៃមិនបាន
បូជាបដិបត្តិថ្កើងថ្កាន	ចំពោះទីស្ថាននៃព្រះចេតិយ។
៤. ម្លប់ពោធិព្រឹក្សព្រះជិនស្រី	ម្លប់ពោធិ៍បារមីនៃព្រះសាស្តា
អនេកច្រើនក្រៃល្អអស្ចារ្យ	បទុមុត្តរាត្រាស់ក្រោមដើមស្រល់។
៥. មង្គលសុមនោអ្នកកុំឆ្ងល់	នាគព្រឹក្សនោះដល់ជាពោធិព្រឹក្ស
អង្គសុជាតៈគួរចាប់ភ្លឹក	ម្លប់ពោធិ៍គួរនឹកដើមឫស្សីធំ។
៦. អង្គបទុមត្រាស់ក្រោមដើមម្រុំ	ទូលព្រះបង្គំខ្ញុំសូមវន្ទា
បិយទស្សីគួររម្យនា	ទ្រង់បាត្រលីលាត្រាស់ក្រោមដើមថ្ងាន់។
៧. ព្រះពុទ្ធគោតមនាគមុច្ចលិន្ទ	ទ្រង់មានព្រះជន្មគឺមួយរយឆ្នាំ
ពស់ពែនភ្នែនព័ទ្ធត្រូវយើងចាំ	មុច្ចលិន្ទនាគត្រាំនៅក្នុងស្រះទឹក។
៨. ម្លប់ពោធិ៍សាស្តាអស្សត្ថព្រឹក្ស	មានដើមមានស្លឹកល្អល្អះប្រពៃ
បានសូធ្យប្រវត្តិព្រះជិនស្រី	ម្លប់ពោធិ៍បារមីទាំងប្រាំពីរអង្គ។

៩. ធ្វើឲ្យចិត្តយើងខ្ញុំជូរផង់ ដោយគុណព្រះសង្ឃសង្ឃសាវ័កល្អ
លើកបទលើកបែបបង្ហាញធម៌ បានរៀបរាប់ពណ៌នាគុណព្រះពុទ្ធ។

១ ។ ^{10} ភទ្របទ វក ព.ស ២៥៦០

អាទិត្យ .១១. កញ្ញា .២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ២១ សរសើរធម៌

បទ ពាក្យគ្រាំមី

១. សាច់ធម៌ព្រះគុណម្ចាស់ពីរោះណាស់រៀហាប្តូរផ្លាស់គួរទីស្នេហា
ពីអារម្មណ៍ពិតគួរទីជ្រះថ្លា អធិប្បាយទេសនាប្រសប់ពណ៌នា។

២. សាច់ធម៌ពីរោះព្រោះអ្នកសម្តែង ផ្កាល្អចាត់ចែងតាមពណ៌គន្ធា
រីឯអ្នកស្តាប់ជាប់ចិត្តធម្មា សូមអនុមោទនាព្រះធម៌ថ្លៃ។

៥ ។ ^{8} អស្សុជ. វក ព.ស ២៥៦០

ព្រហស្បត្តិ៍. ១១ . សីហា .២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ២២ បាក់គ្មានសល់

បទ បច្ចាវត្ត

១. រូបមានអារម្មណ៍ពិតរបស់កាយ រូបកូនរូបម្តាយកើតចាស់ដូច
រូបធ្លាប់ក្មេងខ្ចីស្រស់ៗសោភា តែងគង់ជរាចាស់ឈឺបាក់ធ្មេញ។

២. ពីមុនញញឹមសើចស្រស់ស្អាត ឆ្លើយចាសឆ្លើយបាទធ្មេញល្អក៏ពេញ
ស្រាប់តែឥឡូវត្រូវមិនហ៊ានស្ទេញ ចង់ឆ្លើយតបវិញខ្លាញក្រែងខ្មាស់ចៅ។

៣. ពេលសើចម្តងៗឃើញដូចខ្លោងទ្វារ សាលាវិហារដែលយើងធ្លាប់ទៅ
ខ្លោងទ្វារមហាវ៉ែនមើលឃើញយ៉ាងជ្រៅដូចធ្មេញម៉ែឪបានបាក់គ្មានគ្មានសល់។

២ ។[៥] អស្សុជ. វក ព.ស ២៥៦០
ច័ន្ទ. ០៨ . សីហា .២០១៨
និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ២៣

ម្លប់ស្រល់

បទ ពាក្យត្រាំបី

១. ផ្ទៃមេឃស្រលះផ្លាស់ពណ៌ស្រទន់	ជ្រាលជ្រេយប់យន់ទន់ទេសូរិយា
ខ្ញុំសូរ្យពេជ្ររំលេចអក្ខរា	ម្លប់ស្រល់ព្រឹក្សាមាននរណាគង់?
២. ឱ!គីរីរម្យខ្ញុំសូមស្នេហ៍ស្និទ្ធ	ត្រេកអរពេញចិត្តនូវព្រះពុទ្ធវង្ស
បទុមុត្តរៈនាមពុទ្ធពូជពង្ស	ព្រះអង្គធ្លាប់គង់ត្រាស់ជាព្រះពុទ្ធ។
៣. កៅសិបពាន់ឆ្នាំទ្រង់ចេញចាកផ្ទះ	ប្រាសាទល្អល្អះទ្រង់លះចាកផុត
វិមានស្រីស្នេហ៍មានត្រឹមបីគត់	ឱ!ព្រះរាជបុត្រព្រះនាមឧត្តរា។
៤. ព្រមទាំងមហេសីស្រីស្អាតដាច់គេ	ចិត្តឥតងាករេនឹងការបព្វជ្ជ
វសុលទត្តាស្រីស្រឹង្គា	ស្វាមីសូមលាដោយអស់អាល័យ។
៥. កើតចាស់ឈឺស្លាប់កើតរាល់រូបខ្លួន	និមិត្តទាំងបួនអង្រួនហឬទ័យ
ព្រះអង្គព្យាយាមត្រឹមប្រាំពីរថ្ងៃ	ហេតុតែវិស័យពន្លកព្រះពុទ្ធ។
៦. ត្រូវព្រហ្មអារាធនាព្រះនាយក	សត្វដែលលង់លក់ក្នុងភ័យតក់ស្លុត
ត្រូវការស្តាប់ធម៌រកទីរំលត់	ព្រះតថាគតសម្តែងធម្មចក្រ។
៧. ឧទ្យានមិថិលាល្អប្រពៃ	សាវ័កជិនស្រីនាមសុជាតៈ
និងនាមទេវិលអគ្គសាវ័ក	នាមសុមនៈឧបដ្ឋាកព្រះអង្គ។
៨. ភិក្ខុនីជាអគ្គសាវិកា	ឈ្មោះអមិតាអសមាទ្រង់
បានបំពេញហើយទានក្នុងពុទ្ធវង្ស	ឧបាសកផូរផង់ផ្គត់ផ្គង់សាស្តា។
៩. ឈ្មោះអមិតៈតិស្សនោះឯង	រីស្រីខ្នះខ្នែងឧបដ្ឋាកយិកា

ឈ្មោះហត្ថាមួយនិងសុចិត្តា មានចិត្តជ្រះថ្លាក្នុងទានបារមី។
១០.ព្រះមហាមុន្នីទ្រង់មានកំពស់ ព្រះអង្គមានយសព្រមទាំងសិរី
ហត្ថក្រពុំពិតស្មើហាប្រាំបី លក្ខណៈជិនសាមសិបពីរពិត។
១១.ព្រះជន្មាយុមានកំណត់ មួយសែនឆ្នាំគត់រង្សីរុងរឬទ្ធិ
សាសនារុងរឿងសព្វសត្វជីវិត ជនច្រើនពិសិដ្ឋឆ្លងចាកសង្សា។
១២.ព្រះពុទ្ធជិនស្រីបទុមុត្តរៈ នន្ទារាមៈព្រះស្តូបសាស្តា
សាងហើយរួចស្រេចដល់ទីបូជា ព្រះអង្គធម្មាទ្រង់ចូលនិព្វាន។
១៣.ចំណែករីខ្ញុំព្រះករុណា ភិក្ខុបញ្ញាឋានៈបានរៀន
សិក្សាជ្រះថ្លាឃើញឧបដ្ឋាន ខានស្អែកឡើងឡានិមន្តព្រះសង្ឃ។
១៤.ធ្វើបុណ្យរាប់បាត្រដល់គុណករុណា ធ្វើជូនមាតាមានគុណទ្រទ្រង់
គុណរាប់មិនបានប្រមាណត្រូវត្រង់ អារាធនាព្រះអង្គបដិមា។
១៥.ប្រាំពីរព្រះអង្គសាងយ៉ាងវិចិត្រ មាននាមរូបពិតដោយកាយវិការ
ទ្រង់បាត្រស្អាងស្អាតមានពីរអង្គារ ព្រះបទុមាបិយទស្សី។
១៦.ព្រះពុទ្ធពីរអង្គទ្រង់មានលក្ខណៈ គង់លើវិជិរៈបល័ង្គសិរី
ព្រះពុទ្ធមង្គលច្រើនសែនរស្មី សាសនាជិនស្រីសត្វច្រើនឆ្លងត្រើយ។
១៧.គឺអង្គសម្ពុទ្ធបទុមុត្តរៈ អង្គសុជាតៈសុមនោនោះហើយ
ពីរព្រះអង្គាប្រោសសត្វដល់ត្រើយ លក្ខណៈនេះអ្ហើយគួរឲ្យជ្រះថ្លា។
១៨.ព្រះពុទ្ធគោតមតាំងនូវធម្មា មុច្ចលិន្ទនាគាបល័ង្គសាស្តា
ធ្វើរួចរាល់ស្រេចខ្ញុំអារាធនា ទុកជាទ្រព្យាក្នុងវត្តមហាវ័ន។
១៩.សទ្ធាញ្ញោយីម និង ខ្ញុំករុណា បានឃើញសាស្តាព្រះអង្គភគវ័ន្ត

បែកប្រេះសីស:ថាកសាងឲ្យទាន់ ទើបចង់និមន្តកសាងឲ្យល្អ។
២០.ទើបខ្ញុំព្រះករុណាចាត់ចែងសារស័ព្ទរៀបរាប់ប្រាយប្រាប់ដល់បដិមាករ
ទ្រង់ទ្រាយលក្ខណៈសាងអំពីថ្ម សាងបានបវរដូចចិត្តត្រូវការ។
២១.ឱ!គីរីរម្យភ្នំសាលព្រឹក្ស ទឹកជ្រោះសន្ធឹកហូរផ្ងប់ថ្មដា
ថ្ងៃពេញបរមីអាសាឡ្ហបូជា ឧបដ្ឋានសាលាខ្ញុំរលឹកដល់។
២២.រាត្រីត្រជាក់ធ្លាក់ចុះស្រិចៗ ខ្ញុំសូរ្យពេជ្រនឹកដល់ម្លប់ស្រល់
ចិត្តស្កាប់ធម្មារៀបឃ្លាដំកល់ ម្លប់ពោធិ៍បានផ្តល់នូវទីត្រាស់ដឹង។
២៣.បានឃើញចេតិយនៃពុទ្ធភូមិ ដើមថ្ងាន់ដើមម្រុំឬស្សីធំហ្នឹង
អស្សត្ថព្រឹក្សដើមស្រល់ដើមខ្ឌឹង គួរគាប់សម្លឹងសង្វេគពេកពន់។
២៤.ឱ!ម្លប់ពុទ្ធភូមិទាំងឡាយច្រើនណាស់សត្វលោកប្រែផ្លាស់រាល់រូបជីពជន្ម
ពន្លកព្រះពុទ្ធច្រើនអនេកគុណ ដោយបំពេញបុណ្យកសាងបារមី។
២៥.សូមបុណ្យទាំងឡាយខ្ញុំព្រះករុណា ទានសីលភាវនាមេត្តាខន្តី
សូមសត្វទាំងឡាយរស់សុខសិរី សូមលោកម្ចាស់ថ្លៃអនុមោទនា។
២៦.សូមញាតិទាំងឡាយរួចចាកទុក្ខ សូមជួបក្តីសុខគ្រប់ពេលវេលា
ខិតខំធ្វើបុណ្យរួចរំដោះពៀរ រំលត់សង្ខារអវសាន្តអើយ។
២៧.សូមលោកអត់ទោសអត់អធ្យាស្រ័យដល់រតនត្រ័យញាតិទាំងឡាយហើយ
សូមជាតិបណ្ឌិតដែលនាំដល់ត្រើយ ដឹកនាំខ្ញុំហើយដល់ព្រះនិព្វាន។

២ ។[៥] អស្សុជ.វក ព.ស ២៥៦០
ច័ន្ទ. ០៨ . សីហា .២០១៧
និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ២៤ ថ្ងៃអាវាធនា

បទ ពាក្យត្រាំមី

១. ពេលក្បាលរាត្រីគិតគូរគន់គិត តើការប្រព្រឹត្តរបស់អាត្មា
សម្រេចដូចម្តេចការយាងបដិមា កសាងរចនារួចស្រេចថ្មីៗ។

២. លុះស្អែកព្រលឹមញញឹមរួចស្រេច គិតថាប្តូរផ្តាច់យាងព្រះជិនស្រី
បានគងប្រថាប់ក្នុងវត្តមហាព្រៃ ស្រល់ស្រោងត្រួយខ្ចីគួរទីជ្រះថ្លា។

៣. ១០០០គីឡូដីមែនពិត តែកាយ និង ចិត្តឥតមានត្អូញថា
ខ្ញុំឈឺហត់នឿយខ្លួនមានរោគា តែខ្ញុំអាត្មាអាហារលែងចង់។

៤. ហេតុតែអំណាចគុណព្រះពុទ្ធថ្លៃ ផ្សាភ្ជាប់និស្ស័យជាមួយព្រះអង្គ
ទាំងប្រាំពីរពិតចិត្តគិតដល់សង្ឃ ដែលលោកទ្រទ្រង់នូវធម៌វិន័យ។

៣ ។^{៦} អស្សុជ.វក ព.ស ២៥៦០
អង្គារ. ០៩ . សីហា .២០១៧
និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ២៥

ឆៅ!ឆៅ!

បទ ពាក្យត្រាំមី

១. ដាំបាយម្តេចឆៅយើងខ្លៅម្តេចឆោត រីត្រចៀកប៉ោតម្តេចស្តាប់មិនលឺ
មនុស្សគ្រុនរងារម្តេចថាមិនឈឺ ជនមានជម្ងឺម្តេចចូលក្លឹបបារ។
២. ព្រះសង្ឃនៅវត្តម្តេចបែកសាមគ្គី តាជីយាយជីម្តេចភ្លេចធម៌អាថ៌
លុយម្តេចមិនស្មោះនៅនឹងនរណា សូម្បីអាត្មាម្តេចក្បត់ខ្លួនឯង។
៣. កោរសក់រាល់សីលជ្រុះតែកេសា កិលេសតណ្ហាទោសាសម្ងៃង
មោហៈលោភលន់គ្មានចេះកោតក្រែងថាកម្មចាត់ចែងតាមសម្ពាយបុណ្យ។
៤. បួសឆាន់បាយវត្តមិនមែនបាយវាំង បាយខ្លោចបាយក្តាំងឆាន់ទៅព្រះគុណ
បាយចុងអង្ករសម្លរខ្ទះទុន មានរឿងពីមុនសម័យពុទ្ធកាល។
៥. ព្រះធម៌វិន័យសិរីធ្លាក់ចុះ លឺល្បីតែឈ្មោះពីរោះស្មិទ្ធស្មាល
បណ្ឌិតឯកល្បីហេតុអ្វីបណ្តាល ភាពស្រស់ត្រកាលឲ្យក្លាយអាប់អួរ។
៦. រស់រាល់ព្រឹកល្ងាចបាយបិណ្ឌបាយបាតទោះស្អាតមិនស្អាតគួរឬមិនគួរ
ប្រហុកអំបិលខឆាមីសួរ ដ្បិតយើងជាតួភិក្ខុសាមណេរ។
៧. មិនគ្រហស្ថមានម្ហូបកម្មង់ តាមតែចិត្តចង់តាមមីនុយទេ
ដ្បិតជាតិបព្វជិតរស់ដោយសារគេ ឈុតមួយកំប្លេប៉ុណ្ណឹងបានហើយ។

៨. កុំឲ្យអ្នកផងពិបានចិញ្ចឹម ព្រះភ័ក្ត្រញញឹមសង្ឃឹមរកត្រើយ
និព្វានបរមំសុខំនោះអើយ ដែលជាចម្លើយអស់ភពកំណើត។
៩. ឲ្យសមជាបុត្រព្រះពុទ្ធគោតម ជាបុត្តឧត្តមស្វែងឈប់ការកើត
ក្នុងផ្ទៃមាតាគភ៌តាំងកំណើត ស្តាប់ទៅថាឆើតថាកូនមាសម្តាយ។
១០.កុំតាំងខ្លួនថាកូនឆ្កែឪពុក មានទ្រុងមានគុកចិញ្ចឹមដាក់បាយ
ត្រូវតាំងខ្លួនថាជាកូនមាសម្តាយ បុត្រថ្លៃឆោមឆាយកូនមាសឪពុក។

៣ ៗ[៦] អស្សុជ.វក ព.ស ២៥៦០

អង្គារ. ០៩ . សីហា .២០១៧

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យរឿងទី ២៦ នាងឲត្តរមាតុប្រេត

បទ ពាក្យត្រាំបី

១. ស្រីប្រេតដែលមានសម្បុរអាក្រក់	បិទបាំងដោយសក់សែនវែងអន្លាយ
អង្គុយទៀបឆ្នេរទន្លេរំសាយ	សក់វែងទាំងឡាយសំយ៉ុងចុះដី។
២. គ្រាដែលកង្ខារេវត្តត្ថេរ	សឹងពេលថ្ងៃជាក់ភ្លាក់ព្រោះប្រេតស្រី
ពោលយំរៀបរាប់ទុក្ខសោកសេចក្តី	ទួញសោកពោលស្តីក្តីទុក្ខវេទនា។
៣. ចាប់តាំងខ្ញុំស្លាប់៥៥ឆ្នាំ	ជីវិតរងកម្មក្បែរឆ្នេរគង្គារ
មិនបានបរិភោគធឹកទឹកមួយគ្រា	ទើបសូមវន្ទាសុំទឹកថេរៈ។
៤. រីព្រះថេរៈជាក់តបវិញថា	ទឹកគង្គាថ្លាហូរចុះត្រជាក់
មកពីហេមវន្តម្តេចអ្នកមិនស្ម័គ្រ	ត្រងទឹកហូរធ្លាក់ម្តេចសុំអាត្មា។
៥. បពិត្រលោកម្ចាស់ដ៏ចម្រើនអើយ	ទឹកកាន់យកហើយដែលខ្ញុំករុណា
ប្រែក្លាយជាឈាមភ្លាមទើបកន្និដ្ឋា	មិនអាចពិសារទើបសុំលោកម្ចាស់។
៦. ចុះកម្មអាក្រក់នាងបានធ្វើអ្វី	កាយវាចាស្តីចិត្តដូចម្តេចខ្លះ
ទើបទឹកគង្គាប្រែឈាមប្តូរផ្លាស់	ដល់នាងជាក់ច្បាស់កម្មដូចម្តេចដែរ។

៧. បុត្តរបស់ខ្ញុំមានឈ្មោះឧត្តរៈ មានសទ្ធាជាក់មិនស្តាប់ពាក្យម៉ែ
ជាឧបាសកធ្វើទានហូរហែរ ចំណែកខ្ញុំបែជាហាមឃាត់បុត្ត។
៨. ខ្ញុំត្រូវកំណាញ្ញបៀតបៀនក៏ដេរ ថាមិនឲ្យទេសមណៈនោះសុទ្ធ
បច្ច័យទាំងបួនដល់ទីបំផុត ដល់អ្នកជាបុត្តចូរកើតជាឈាម។
៩. ចីវរបិណ្ឌបាតសេនាសនៈ គិលានភេសជ្ជៈបានជេរគំរាម
ពេលកើតបរលោកឲ្យប្រែឈាម ទើបទឹកប្រែភ្លាមឈាមមហាគង្គា។
១០.កម្មកាចតាមពិតដ្បិតចិត្តកំណាញ់ គឺមានតែអញហួងហែងទ្រព្យា
ពេលស្លាប់ទើបដឹងរងទុក្ខវេទនា កូនបានសួគ៌ាមាតាកើតប្រេត។
១១.មិនដែលបានក្រេបបរិភោគបានម្តង ទើបពោលសាសងពីកម្មដើមហេតុ
សុំទឹកសមណៈបានផឹកក្រេបឆ្អែត បានមួយចំអែតបំបាត់ស្រេកឃ្លាន។
១២.ដូច្នេះបរិសទ្យបដិបត្តិឲ្យល្អ រស់ទ្រទ្រង់ធម៌រាប់បាតធ្វើទាន
បុណ្យនាំក្តីសុខយសសក្តិធនធាន សទ្ធាត្រូវមានជាអរិយទ្រព្យ។

៦ ។[1] .ធល្ពុន. រកា ព.ស ២៥៦១

សុក្រ . ០២. មីនា.២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យរឿងខ្លី ២៧ មេណ្ឌកសេដ្ឋី

បទ ពាក្យឆ្នាំមី

១. ឆាតកភ័យទុរ្ភិក្សជន ជួបទុកទារុណមួយជម្ពូរទ្វីប
ព្រះបច្ចេកពុទ្ធជាដួងប្រទីប បានបំភ្លឺទ្វីបដោយទានសេដ្ឋី។

២. អង្គរពីរនាឡ្បិយកមកដាំបាយ សម្បត្តិទាំងឡាយគ្មានតម្លៃអ្វី
បើក្រពះឃ្លានបាយទឹកចំណី ឆាតកភ័យប្រល័យលោកា។

៣. សេដ្ឋីហេវហត់អស់កំលាំងណាស់ ហើយមានប្រសាសន៍ទៅភរិយា
តើយើងថ្ងៃនេះបានអ្វីពុំងារ ធ្វើជាអាហារក្បាជីវិត?

៤. ចន្ទបទុមកល្យាណស្រស់ស្រី ពោលប្រាប់សេដ្ឋីដោយត្រង់ការពិត
សល់ត្រឹមពីរនាឡ្បិរះរកខំខិត រ៉ែងស្ទើចិត្រពីជញ្ជាំងដី។

៥. បពិត្រលោកម្ចាស់ត្រូវធ្វើដូចម្តេច បើអង្គរតិចបរបរបានធី
បានបរភោគត្រឹមបានពីរបី បើដាំបាយធីត្រឹមបានមួយគ្រា។

៦. មេណ្ឌកសេដ្ឋីពោលយ៉ាងស្រទន់ តបទៅប្រពន្ធឧត្តមភរិយា
ដាំបាយទៅចុះណាស្រស់ពុំងារ បំបាត់វេទនាពូជជាសេដ្ឋី។

៧. ចន្ទបទុមពុំនៅកន្តើយ ធ្វើតាមប្តីហើយឆ្លើយចាសលោកប្តី
ដាំបាយដោះដួសលើកជូនលោកប្តី តែគាប់ជូនអីព្រះបច្ចេកពុទ្ធ។
៨. ទើបតែនិមន្តចេញពីនិវេធ រូតរះស្រស់ស្រូតឃើញភាពទុរគត
ពិចារណ៍ត្រិះរិះរហ័សបំផុត សទ្ធាមោះមុតបានដល់នរណា។
៩. ហេតុកម្មបច្ច័យនិស្ស័យអតីត កំលាំងបុណ្យពិតភ័ព្វព្រេងវាសនា
មេណ្ឌាសេដ្ឋីនិងក្រុមគ្រួសារ បានថ្វាយអាហារដល់ព្រះថេរៈ។
១០.មិនមានបែងចែកចំណែកពីរបី បើកទ្វារទាំងបីដោយសុច្ចរិតជាក់
លះលាកំណាញ់សូមអញ្ជាគៈ អ្នកទាំងប្រាំនាក់ធ្វើដោយជ្រះថ្លា។
១១.រៀបរាប់ពោលផ្សងបំណងតាមចិត្ត ផលទាននោះពិតបានតាមប្រាថ្នា
ធន្ធញ្ជ័យ និង នាងសុមនា បុណ្ណៈទាសាបានដូចបំណង។
១២.ការលះកំណាញ់ត្រឹមបាយ២នាឡិ នេះជាដំណាលកាលព្រះពុទ្ធផង
ព្រះបច្ចេកពុទ្ធបាននាំចម្លង ថ្វាយ៥០០ដងដល់អង្គទាំងឡាយ។
១៣.ធ្វើឲ្យសោមនស្សដល់អ្នកម្ចាស់ទាន មេណ្ឌាកប្រធានកើតជាចាហ្វាយ
លុះបានធ្វើទានសព្វសត្វសប្បាយ ដោយផលខ្លួនថ្វាយអាហារចុងក្រោយ។

១៤.ចិញ្ចឹមជីវិតមួយជម្ករទ្វីប ទានជាប្រទីបកុំគាប់បណ្តោយ

បើឃើញគេអត់យើងត្រូវចេះឲ្យ ផលសុខសេពសោយដល់សន្តិបទ។

៧ៗ[10] .បុស្ស. រកា ព.ស ២៥៦១

សៅរ៍. ២៤ . កុម្ភៈ.២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

អំណាញរឿងទ្នី ២៨ នាងរុច្ចា

បទ ពាក្យត្រាំបី

១. កាលដែលអង្គព្រះបាទអង្គតិ មិច្ឆាទិដ្ឋិមិនយល់សាច់ការ
យល់តែខាងបាបនាំភ័យទុក្ខា កាលនោះធីតារុច្ចាឆ្លាតវៃ។

២. បានរំលឹកជាតិពិត្រប្រាប់ហេតុផល ដោះស្រាយចំងល់កម្មសត្វលោកិយ
រំលឹកជាតិខ្លួនភពទាំងប្រាំបី ឲ្យអង្គចក្រីសណ្តាប់ត្រិះគិត។

៣. កាលព្រះទសពលកស្សបទ្រង់ញាណខ្លួនជាអ្នកមានកូនសេដ្ឋីពិត
រក្សាសីលទានប្រាំបីវិចិត្រ តែកម្មអតីតតែងតាមឲ្យផល។

៤. ហេតុកម្លាំបាបធ្ងន់ធ្ងរពេកពន់ ដ្បិតកម្លាំងបុណ្យពូជជាកុសល
ទោសដាច់កាមេនាំក្តីកង្ងល់ ទើបមានលទ្ធផលធ្លាក់ក្នុងអវចី។

៥. អស់មួយចន្លោះព្រះពុទ្ធទ្រង់ញាណ កស្សបប្រធានសព្វសត្វលោកិយ
រួចពីនរកឋានកម្មអប្រិយ ធីតាពិសីរៀបរាប់ទៀតថា។

៦. នាងត្រូវកើតតិរច្ឆានសោយសោក ត្រូវដាច់ពងទោកពពែ និង ស្វា
ត្រូវកើតជាខ្ទើយរស់រងទុក្ខា ៥០០ជាតិណាទើបបានក្លាយស្រី។

៧. ស្រី៥០០ជាតិពេញដោយអភ័ព្វ ជួបគូរមិនគាប់ស្មោះស្ម័គ្រភក្តី
ជួបការធិតក្បត់ដូចកាលសេដ្ឋី ខ្លួនដើរលេងស្រីជាល្បែងកំសាន្ត។
៨. ស្គាល់ភាពវេទនានិទ្ទាឆ្វេងស្តាំ ទឹកភ្នែកប្រចាំថ្ពាល់ស្រីកល្យាណ
ភាពស្អប់កប់ជ្រៅនៅក្នុងសន្តាន បានកម្មប៉ុន្មានធូរថយអស់ខ្លះ។
៩. អស់កម្មកំណើតកើតទេពធីតា តាវតឹង្សវង្សាក្រងផ្កាល្អល្អះ
សប្បាយភ្លេចខ្លួនច្យុតិរហ័ស ឥឡូវជាក់ច្បាស់នាមនាងរុច្ចា។
១០.បពិត្របិតាធំលើផែនដី សូមអង្គចក្រីទ្រង់ពិចារណា
ការសម្លាប់សត្វវិបត្តិខ្លោចផ្សារ មិនបានសុខាដូចមហាអាមាត្យ។
១១.ពោលពិតព្រះអង្គជារឿងទោសធ្ងន់ មិនមែនបានបុណ្យជារឿងប្រមាទ
មើលសព្វសត្វបាណាតិបាត ហាមឃាត់ដាច់ខាតកុំសម្លាប់សត្វ។
១២.ដូចជាបុត្រីពេញវ័យក្រមុំ តាវតឹង្សភពខ្ពុំតិចតួចពេកក្តាត់
១៦ឆ្នាំបុត្រចាំបដិបត្តិ សីលទានបរិយត្តិនាំសត្វលោកិយ។
១៣.រុច្ចាធីតាវាចាពីរោះ នៅគ្រាកាលនោះអង្គតិចក្រី
ស្តាប់ពាក្យវាចារបស់បុត្រី ភ្ញាក់ខ្លួនសារថ្មីសាងបុណ្យកុសល។

១៤.រុច្ចាធីតាបានជាអានន្ទ ដែលបំពេញបុណ្យខំសាងមគ្គផល
២០០០០ឆ្នាំគត់ញាតិមិត្តកុំឆ្ងល់ ម្តេចតួកុសលក្របានផលម្ល៉ះ។
១៥.ដ្បិតទោសកាមេមាំមានកម្លាំង មិនអាចប្រឆាំងបាបកម្មចាក់ស្រេះ
ចង់បានក្តីសុខត្រូវរកចំណេះ បុណ្យល្អវិសេសទើបរួចវដ្តៈ។

៥ៗ[៨] .បុស្ស. រកា ព.ស ២៥៦១

ព្រហស្បត្តិ៍. ២២ . កុម្ភៈ.២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ២៩ សម្តី

បទ ពាក្យត្រាំមួន

១. សម្តីផ្កាពោលពីរោះឈ្មោះក្រអូប
គេចង់ស្រូបចង់នៅក្បែរថែរក្សា
គេចង់ស្តាប់អ្នករៀបរាប់ប្រាប់កថា
មានខ្លឹមសារជាធម៌អាថ៌ច្បាប់បាលី។

២. វាចាពោលពាក្យផ្អែមល្ហែមប្រៀបទឹកឃ្មុំ
ចាសបាទខ្ញុំករុណាទានមានវិន័យ
ស្គាល់ខុសត្រូវយល់ហេតុផលសួគ៌សិរី
សុខសួស្តីពោលស្រទន់ពីរោះស្តាប់។

៣. ពាក្យគូថៈប្រឡាក់អាចម៍ប្រកាច់ជេរ
ពីរោះទេសម្តីពាលពោលថ្លែងប្រាប់
ពោលចាក់ដោតបោកបញ្ឆោតគួរសណ្តាប់

ចេញឲ្យឆាប់ប្រយ័ត្នឈ្លោះទាស់ទែងគ្នា។

៤. វចីកម្មកើតកុសលមានខ្លឹមសារ

ពោលកថាវត្ថុដប់ក្នុងធម្មា

ពីសន្តោសការព្យាយាមផុតកម្មពៀរ

ដល់វេលាវិមុត្តិចាកភពវដ្ដៈ។

៥. វចីកម្មអកុសលផ្តល់ទោសច្រើន

មិនចម្រើនក្នុងវិន័យព្រះអរិយៈ

គេមិនក្រែបសេពរស់ស្តាប់ពាក្យអប្បលក្ខណ៍

ពាក្យប្រឡាក់ដោយលាមកជាប់ភពជាតិ។

៥ៗ[1] .បុស្ស.រកា ព.ស ២៥៦១

ព្រហស្បត្តិ៍. ១៥ . កុម្ភៈ.២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៣០ កុំអាងខ្លួនមាន

បទ ផ្កាឈូករីករោចរាំស្រនាប់

១. កុំអួតកុំអាងកុំសាងបាបកម្ម កុំភ្លេចបណ្តាំកុំចាំខាងខុស
កុំអាងខ្លួនមានហ៊ានស្តីបន្ទោស កុំឃើញញាតិនោះស្មើសាច់ដ៏ទៃ។
២. កុំអាងផ្លែផ្កាដុតឫសថែគល់ កុំអាងខ្លួនយល់ដឹងច្បាស់សេចក្តី
កុំអាងខ្លួនឯកមានកប់សេដ្ឋី កុំអាងអញថ្វីធ្វើជនផ្តាច់ការ។
៣. កុំអាងអំនួតអួតខ្លួនឯងល្អ កុំឃើញញាតិក្រខឹងដងផ្លែផ្កា
កុំយកសាច់ឯងបញ្ចុកមាត់ខ្លា កុំភ្លីហ៊ឺហាភ្លេចប្អូនភ្លេចបង។
៤. កុំកោងព្រហើនភ្លើតភ្លើនភ្លេចខ្លួន កុំខឹងគុំគួនត្រកួនបោះទង
កុំវាឆ្លងបឹងខឹងឈប់សាសង កុំៗស្នេហ៍ស្នងឈោមខាប់ជាងទឹក។
៥. កុំអាងទ្រព្យធនភ្លេចគុណញាតិមិត្ត កុំទៅស្នេហ៍ស្និទ្ធភ្លេចមិត្តដែលនឹក
កុំភ្លេចម៉ែឪគាត់នៅរឮក កុំភ្លេចបាយទឹកជូនគាត់ពិសារ។
៦. កុំរស់មួយថ្ងៃព្រៃផ្សៃសាងបាប កុំព្រួសកុំសាបលើខ្នងគ្រួសារ
កុំកេងប្រវ័ញ្ចចំរាញ់ដុល្លា កុំខ្លាំងអស្ចារ្យសម្លាប់ឈោមឯង។
៧. កុំរស់ប្រមាទប្រមាថញាតិមិត្ត កុំអាងមានពិតមានៈឥតក្រែង

កុំនាំសាច់ខ្លួនរងទុក្ខចម្បែង កុំខំប្រឹងប្រែងឆ្ពិះឆ្ងៀលបន្លា។
៨. កុំអាងទោសៈប្រឡាក់ឈាមស្រស់ កុំមិនស្រណោះត្រកូលគ្រួសារ
កុំពូជតែមួយក្តិចត្រួយវឌ្ឍនា កុំលយអស្ចារ្យប្រហារហួសច្បាប់។

៥ៗ[៨] .បុស្ស. រកា ព.ស ២៥៦១

ព្រហស្បត្តិ៍. ២២ . កុម្ភៈ.២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

ខ្ញុំខ្លាចខ្លួនឯង

បទពាក្យជ្រាំបី

១.ខ្ញុំខ្លាចខ្លួនឯងមាននូវតណ្ហា ខ្ញុំខ្លាចស្រីស្រាប្រាថ្នាលួងលោម
ខ្ញុំខ្លាចខ្លួនឯងទទួលយល់ព្រម ខ្ញុំខ្លាចល្មមដល់វ័យជរា។
២.ខ្ញុំខ្លាចខ្លួនឯងមិនព្រមចូលបួស ខ្ញុំខ្លាចហួសសាងកម្មចងពៀរ
ខ្ញុំខ្លាចចំណងបុត្ត និង ភរិយា ខ្ញុំខ្លាចកូនមារមកប្រលោមស្នេហ៍។

៧ៗ១០ .មាឃ. រកា ព.ស ២៥៦១

សៅរ៍. ១០. កុម្ភៈ.២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យរឿង ៣១ ទេវតាកំហូច

បទ ពាក្យស្រាំបី

១. កាលសម័យមួយផ្លាស់ប្តូរអំណាច សក្កទេវរាជវេស្សវ័នក្សត្រា
បានឡើងតំណែងប្រមុខទេវតា ចែកភូមិរុក្ខាទេវតារស់នៅ។
២. ជីវិតទេវតាក្លៀវក្លាអ៊ូអរ ជ្រើសរើសភូមិករដើមឈើក្បែរផ្លូវ
ខ្លះនៅភ្នំខ្ពស់ជ្រោះជ្រងសែនជ្រៅ ខ្លះត្រូវតំរូវទីប្រជុំជន។
៣. ទេវតាក្អាកក្អាយសប្បាយសេពសោយជំនូនអំណោយតាមមនុស្សដឹងគុណ
ទេវតាកំហូចមិនសំបូរបុណ្យ ខឹងមនុស្សរិះគន់អាងឫទ្ធិបៀតបៀន។
៤. ទេវតាខ្លះកាចអំណាចមហិមា មិនធ្វើការងារជួញដូរគ្រឿងញៀន
ចុះអប់រំគេកុំជក់អាភៀន កិច្ចការបង្រៀនធ្វើដូចស្អាតស្អំ។
៥. ទេវតាខ្លះទៀតបានស្រីបានស្រា ធឹកស៊ីសង្ហាអាងយសសក្តិធំ
ប្រពន្ធស្រីញីរកតែក្រមុំ នេះជាសង្គមរុក្ខទេវតា។
៦. ការងារបញ្ជីមិនខ្វីរវល់ ទេវតាខ្វាយខ្វល់នឹងទេពធីតា
ស្តេចទេពជាធំប្រជុំកាលណា បង្ហាញភក្ត្រាយកតែមុខមាត់។
៧. បើកតែប្រាក់ខែវែៗដាច់ឆ្នាំ ទេវតានូវចាំបើកលុយទៀងទាត់
មិនចូលបម្រើប្រជាពលរដ្ឋ លាក់បាំងប្រវត្តិតែងច្បាប់ពិន័យ។

៨. ទេវតាដែលខូចកំហូចពេកពន់ ឆ្លៀតមកទារពន្ធមនុស្សលោកប្រុសស្រី
ទារពែរសំណែនសែនពេញទឹកដី ទេវតាក្នុងព្រៃស្តាប់បញ្ជាមេ។
៩. ទេវតាដែលខូចច្រើនរស់ក្នុងស្រុក ច្រើនតែធ្វើទុក្ខបុកម្នីញឥតល្ហែ
ចង់បានលាភជ័យបណ្តើរស្រីស្នេហ៍ មកលេងហូរហែរដើរមើលអង្គរ។
១០.ទេវតាដែលល្អថែរក្សាព្រៃ រស់មានវិន័យក្នុងព្រៃគុណធម៌
រស់នៅជួបជុំធ្វើអំពើល្អ រស់នៅបវរព្រៃភ្នំធំស្ងាត់។
១១.ថ្លែងអង្គទេវតាក្សត្រាមហារាជ អ្នកមានអំណាចគ្រប់គ្រងសព្វសត្វ
រុក្ខទេវតាត្រូវតែបដិបត្តិ តាមអង្គមហាក្សត្របរមពោធិ។
១២.ទូន្មានទេវតាតូចធំទាំងឡាយ អ្នកកុំរស់ឆ្ងាយរួបរួមទិដ្ឋិ
មូលមិត្តជួបជុំតាំងសមាធិ ទេវតាពលិប្រជុំព្រឹក្សព្រៃ។
១៣.ចំណែកទេវតាជាអង្គទេវទត្ត ចេះតែភ្លាំងភ្លាត់ខុសទេពដទៃ
ទៅរស់ម្នាក់ឯងឈើធំត្រឈៃ ពាក្យពោលស្រដីមិនស្តាប់នរណា។
១៤.ដល់ទីបំផុតថ្ងៃមួយព្យុះធំ បក់ដួលរលំឈើធំរុក្ខា
ទេវតាទេវទត្តព្រាត់នូវគ្រឹហា ទួញយំសោកាសែនសមមុខហើយ។

៧ៗ[10] .បុស្ស. រកា ព.ស ២៥៦១

សៅរ៍. ១០ . កុម្ភៈ.២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៣២ តណ្ហា

បទ ឈូករីករហង់ពីរស្រទាប់

១. តណ្ហានៅមានស្រែកឥតឈប់ តណ្ហាឥតគ្រប់សម្រាប់ប្រាថ្នា
តណ្ហាចាក់ស្រេះក្នុងដួងចិន្តា តណ្ហាអ្នកណាអ្នកនោះរងកម្ម។
២. តណ្ហាកើតឡើងតាមតែចំណង់ តណ្ហាស្មោះត្រង់កាមគុណចំណាំ
តណ្ហាខាងក្រៅត្រូវការប្រចាំ តណ្ហាសាំញ៉ាំចង់ហួសប្រមាណ។
៣. តណ្ហាខាងក្នុងតណ្ហាខាងក្រៅ តណ្ហាតែងហៅប្រាថ្នាចង់បាន
តណ្ហាច្រើនក្រៃនិស្ស័យកល្យាណ តណ្ហាលុយឡានគ្រឿងអលង្កា។
៤. តណ្ហាលើសលប់លោភលន់ពន់ពេកតណ្ហាពុះជ្រែកទឹកភ្នែកសោកា
តណ្ហាលយឆាយឆ្ងាយពីធម៌អាថ៌ តណ្ហាឫស្យាប្រហារសត្វលោក។
៥. តណ្ហាគ្មានរើសអ្នកក្រ ឬ មាន តណ្ហាស្រែកឃ្លានគ្មានចេះលៃលក
តណ្ហាចាក់ស្រេះក្នុងក្រៅគគោក តណ្ហាស្មោគគ្រោកគួរខ្ពើមរអើម។

៧ៗ[10] .បុស្ស. រកា ព.ស ២៥៦១

សៅរ៍. ១០ . កុម្ភៈ.២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៣៣ ខឹងណាស់

បទលូកវីកវមាង់មួយស្រទាប់

១.	ខឹងណាស់ចិត្តក្តៅរាប់ពាន់លានសែន	ខឹងខ្លាំងមែនទែនខុសខាតទទេ
	ខឹងនឹងមនុស្សបោកកុហកវៀចវេ	ខឹងមនុស្សបោកគេទាំងឈាមត្រជាក់។
២.	ខឹងក្រោធទោសៈដូចប្រឡាក់ដី	ខឹងមនុស្សអប្រិយ៍ស្រដីរាក់ទាក់
	ខឹងមនុស្សទាបតឿខំជឿខំស្ម័គ្រខឹង	មនុស្សអប្បលក្ខណ៍អន់អាប់ប្រាជ្ញា។
៣.	ខឹងមិនគួរសេពរួមរស់មេត្រី	ខឹងមិនចង់ស្តីរៀបរាប់ចរចា
	ខឹងមិនចង់ឆ្លើយផ្តោះផ្តងស្នេហា	ខឹងមិនចង់ថានិយាយរាប់អាន។
៤.	ខឹងខ្លួនឯងពិតផ្ញើចិត្តសង្ឃឹម	ខឹងខ្លួនញញឹមត្រឹមពាក្យថាស្មាន
	ខឹងខ្លួនកល្យាណចាញ់បោកភុំជាន	ខឹងខ្លួនកល្យាណរស់ក្រោមមនុស្សពាល។
៥.	ខឹងខ្មាស់ខ្លួនឯងថាជាបណ្ឌិត	ខឹងគេខូចចិត្តបណ្ឌិតតិះដៀល
	ខឹងគេខាតបង់មិនខុសជនពាល	ខឹងបាត់មួយរៀលខាតបង់មួយពាន់។
៦.	ខឹងនឹងកិលេសគ្រោតគ្រាតសៅហ្មង	ខឹងពេកកន្លងចង់តែជេរមាន់
	ខឹងហួសនិស្ស័យគួរឲ្យធុញទ្រាន់	ខឹងគេលូកលាន់ជិះជាន់សង្កត់។
៧.	ខឹងមហាអំណាចខឹងកាចឬស្យា	ខឹងនឹងតណ្ហាមិនចេះទ្រាំអត់
	ខឹងអ្វីខ្លាំងម្លេ៉ះមិនចេះអត់ធ្មត់	ខឹងដល់ទុរគតចុតិសង្ខា។
៨.	ខឹងគុំគួនស្អប់បញ្ចប់ត្រឹមខឹង	ខឹងអ្នកខ្ញុំដឹងខឹងមិនធម្មតា
	ខឹងជឿទុកចិត្តនឹងពាក្យអាចារ្យ	ខឹងត្រង់វាចាដូចសេះមាត់ពីរ។

៧។[១២] .បុស្ស. រកា ព.ស ២៥៦១

សៅរ៍. ១២ .មករា.២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៣៤

ផលទាន

បទ ពាក្យត្រាំបី

១.កុសលផលទានមានដោយសទ្ធា កុសលបូជាកើតឡើងដោយស្តាប់
ឱវាទសប្បុរសស្រស់ស្រាយស្ទាហាប់ ពាក្យពោលត្រូវត្រាប់សុចរិតទ្ធារបី។
២.នរណាដែលដឹងមិនហ៊ានប្រមាទ សិក្សាសំអាតកិលេសអប្រិយ
នាំបុណ្យកុសលជាលាភសិរី នាំសុខសួស្តីជោគជ័យកិច្ចការ។
៣.វាចាសប្បុរសស្តាប់ហើយត្រេកអរ វាចាជាធម៌តាមព្រះសាស្តា
ជាពុទ្ធឱវាទពិរោះពិសា ស្តាប់កើតបញ្ញាមានអរិយទ្រព្យ។
៤.បុណ្យជាកុសលដល់នូវក្តីសុខ បុណ្យនាំរួចទុក្ខទោសកម្មអភ័ព្ធ
អ្នកមិនប្រមាទបដិបត្តិគួរគាប់ មានកិច្ចទំលាប់ជាប់ចុះវិន័យ។

១កើត . ជេស្ឋ .ចរ .ព.ស ២៥៦១

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

១.រស់កុំតវ៉ាជាមួយជនពាល រស់គេតិះដៀលមកពីមិនល្អ
រស់នៅខ្ទះទ្រព្យមកពីក្រីក្រ រស់ខ្ទះបុណ្យល្អខ្ទះសីលខ្ទះទាន ។
២.អត់ទ្រព្យអត់កូនអត់ប្រពន្ធប្តី អត់ចៅប្រុសស្រីយាយតាក៏គ្មាន
ព្រាត់ប្រាស់បងប្អូនកូនចៅអត់ឃ្លាន មិនបានរស់រៀនមានការលិតលង់ ។

កំណាព្យ ៣៥

ផ្លូវត្រង់

បទ ឆ្កាឈូករីក

ផ្លូវបែកជាពីរជាបីជាបួន ផ្លូវដើរដោយខ្លួនត្រាច់ចរប្រាសសត្វ
ផ្លូវទាំងប្រាំបីត្រឹមត្រូវបដិបត្តិ ផ្លូវរៀនបរិយត្តិប្រាំបីមុនប្លាយ ។
អ្នកបួសរស់នៅរកផ្លូវអរហន្ត អ្នកបួសមិនទាន់អរហត្តឃ្លាតឆ្ងាយ
អ្នកបួសរស់ដោយបច្ច័យទាំងឡាយ អ្នកបួសសប្បាយរស់តាមធម្មា ។
សុខភាពផ្លូវចិត្តគំនិតបវរ សុខភាពកាយល្អគ្រួសារធូរធារ
សុខភាពបរិបូរណ៍សង្រួមវាចា សុខភាពស្រស់ថ្លាផ្លូវវាចាស្ងប់។
ជីវិតសត្វលោកច្រើនរស់ដោយកាម ជីវិតញៀនញ៉ាំមតាមមិនចេះគ្រប់
ជីវិតលក់លង់ល្ងង់ក្នុងកាមភព ជីវិតបញ្ចប់ផ្លូវដល់និព្វាន ។
សូមសត្វទាំងឡាយសប្បាយតាមធម៌ សូមសត្វបវរកុំធ្វើបំពាន
សូមសត្វមានយសប្រឹងរស់ខំរៀន សូមសត្វអ្នកមានឥន្ទ្រិយសង្រួម។
ពេញចិត្តផ្លូវដែលនាំឆ្ពោះផុតទុក្ខ ពេញចិត្តផ្លូវមុខទុកផ្លូវក្រោយល្មម
ពេញចិត្តផ្លូវឯកត្រង់ត្រូវដល់ព្រម ពេញចិត្តសង្រួមក្នុងភេទបព្វជិត ។

១៣ កើត មាឃ រកា ព.ស ២៥៦១
២៨ មករា ២០១៨
និពន្ធ ភិក្ខុ បញ្ញាបាភោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៣៦ ឈឺកាយ

បទ ឆ្ការលូកវីក

១.ឈឺកាយតែសប្បាយចិត្ត	ឈឺកាយតែស្និទ្ធស្នេហា
ឈឺកាយតែមានខ្លឹមសារ	ឈឺកាយតែថាបានសុខ ។
២.ឈប់ស្នេហ៍ហើយនាំឈឺប្រាណ	ឈប់ស្នេហ៍ហើយនាំផុតទុក្ខ
ឈប់ស្នេហ៍ហើយនាំអាប់មុខ	ឈប់ស្នេហ៍បានសុខក្នុងលោកា ។
៣.ភារៈភាវៈភិក្ខុ	ភារៈនិរទុក្ខផុតសោក
ភារៈនិរទុក្ខផុតរោគ	ភារៈគគោកខន្ធប្រាំ ។
៤.ដោះស្រាយស្រុះស្រួលមូលមិត្ត	ដោះស្រាយស្របចិត្តចង់ចាំ
ដោះស្រាយវិយោគរងកម្ម	ដោះស្រាយរាល់ឆ្នាំខែថ្ងៃ ។
៥.ព្រឹកព្រៀងរៀងរះតេជោ	ព្រឹកព្រៀងអាសូរប្រុសស្រី
ព្រឹកព្រៀងសូរិយាថ្មី	ព្រឹកព្រៀងរកឆីអាហារ ។
៦.ថ្ងៃត្រង់ជួបជុំជជែក	ថ្ងៃត្រង់វែកញែកបញ្ហា
ថ្ងៃត្រង់សួរឆ្លើយកិច្ចការ	ថ្ងៃត្រង់គ្រួសារមិត្តភក្តិ ។
៧.ល្ងាចល្ងិតល្ងង់ល្ងើលក់លង់	ល្ងាចល្ងិតពិតល្ងង់រួមរ័ក្ស
ល្ងាចល្ងិតមើលមិនយល់ភក្តិ	ល្ងាចល្ងិតរាក់ទាក់តណ្ហៈ។
៨.មនុស្សលោកកាមសុគតិ	មនុស្សលោកពុទ្ធិពុទ្ធៈ
មនុស្សលោកជាងរិយៈ	មនុស្សលោកជ័យជាក់ត្រឹមត្រូវ។

១២ កើត មាឃ រកា ព.ស ២៥៦១

២៨ មករា ២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៣៧ កុំចង់សប្បាយ

បទ ពាក្យឆ្នាំមី

១. នៅក្មេងលេងមិនឈប់ប្រឡាក់ដី　　នៅក្មេងធ្វើអ្វីខ្លីគំនិតពិត
　　នៅក្មេងវង្វេងក្នុងការប្រព្រឹត្ត　　បើចាស់ជួយគិតជីវិតប្រសើរ។
២. រស់នៅកំសត់អត់ទ្រព្យធនធាន　　រស់នៅអត់ឃ្លានមានកិច្ចដំណើរ
　　ឆ្ពោះរងទុក្ខទោសទាំងដេកឈរដើរ　　រស់នៅប្រសើរមិនបៀតបៀនសត្វ ។
៣. គួរគាប់គំនិតគិតកាលវេលា　　រស់នៅជុំគ្នាមិនពោលពាក្យសត្យ
　　គិតតែមុសាមិនប្រុងប្រយ័ត្ន　　មិនរៀនលះកាត់បង់វដ្តសង្សារ ។
៤. ពេលបានជួបជុំបន្តុំក្អាកក្អាយ　　ចិត្តចង់សប្បាយលយឆាយសង្ហារ
　　ឬករាងកាលីបហំហួនអស្ចារ្យ　　តែគ្មានដុល្លានៅក្នុងហាប៉ៅ។
៥. ជីវិតសត្វលោកមានមួយដូចគ្នា　　សត្វខ្លះគ្រាំគ្រាវេទនាសោកសៅ
　　តណ្ហាចាក់ស្រេះទាំងក្នុងទាំងក្រៅ　　ដ្បិតយើងនៅខ្លៅទោសអវិជ្ជា ។
៦. កុំចង់សប្បាយខ្វះការអប់រំ　　កុំចង់ធ្វើធំតំណែងមុខងារ
　　ជនដែលបំពេញកុសលគ្រប់គ្រា　　សព្វកាលវេលាធម្មៈសប្បាយ ។

៤ រោច អាសាធ ចរ ព.ស ២៥៦២ ត្រូវនឹង ៣១ កក្កដា ២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៣៨ ឧត្តមដួងចិត្ត

បទ ឈូកវីករហាច់ត្រួតពីរស្រឌាប់

១. ឧត្តមដួងចិត្តឧត្តមស្នេហា	ឧត្តមចិន្តាឧត្តមសោមនស្ស
ឧត្តមបុណ្យទានឧត្តមសប្បុរស	ឧត្តមចិត្តស្មោះឧត្តមកុសល។
២. ឧត្តមមាសស្នេហ៍ឧត្តមមាសមេ	ឧត្តមម្លើះទេឧត្តមមគ្គផល
ឧត្តមភាវនាឧត្តមអស់ខ្ទល់	ឧត្តមនិមន្តឧត្តមវៃស្របុណ្យ។
៣. ឧត្តមខ្ទុំអើយឧត្តមភេទពិត	ឧត្តមដួងចិត្តឧត្តមដឹងគុណ
ឧត្តមសាសនាឧត្តមពោលសុន្ទរ៍	ឧត្តមពុទ្ធគុណឧត្តមរតនៈ។
៤. ឧត្តមដួងចន្ទឧត្តមសូរិយា	ឧត្តមសិក្សាឧត្តមសូរិយៈ
ឧត្តមវេលាឧត្តមវលក្ខណ៍	ឧត្តមភ្លឺជាក់ឧត្តមយប់ថ្ងៃ ។
៥. ឧត្តមសមសក្តិឧត្តមសុរិយុទ្ធ	ឧត្តមវិមុត្តិឧត្តមប្រពៃ
ឧត្តមក្រិត្យក្រមឧត្តមវិន័យ	ឧត្តមជិនស្រីឧត្តមខ្ពង់ខ្ពស់។
៦. ឧត្តមមាលាឧត្តមភួងពាន់	ឧត្តមគ្រប់គ្រាន់ឧត្តមទ្រង់យស
ឧត្តមទ្រង់គ្រឿងឧត្តមកេរ្តឺ៍ឈ្មោះ	ឧត្តមរួមរស់ឧត្តមគតិ។

៧. ឧត្តមឧត្តមឧត្តមឧត្តម ឧត្តមសង្គមឧត្តមសមាធិ
ឧត្តមត្រឹមត្រូវឧត្តមសតិ ឧត្តមចិលិឧត្តមគិតកត់។
៨. ឧត្តមប្រពៃឧត្តមប្រសើរ ឧត្តមដំណើរឧត្តមសន្ទុះ
ឧត្តមរុងរឿងឧត្តមមិនខ្សត់ ឧត្តមប្រាកដឧត្តមថ្កើងថ្កាន។

៦[1] ៦.ចែត្រ .រកា .ព.ស ២៥៦១

សុក្រ ទី ០៦ មេសា ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៣៩ ព្រះចេតិយខ្សាច់

បទ លើកឧប់ព្រះពុទ្ធសាសនា

១.	ព្រះមានព្រះភាគទ្រង់ត្រាស់ថា	មានតែចិន្តាសុខស្ងប់តែមួយ
	ជាបរមសុខភាពជំនួយ	ឥតមានទុក្ខព្រួយរស់សោយសុខា។
២.	ថ្ងៃនេះជួបជុំស្តាប់ធម៌ទេសនា	ជាតិខ្មែរខេមរាបានចូលឆ្នាំថ្មី
	ពួកយើងបានកសាងចេតិយ	ខ្សាច់សប្រពៃសូធ្យអធិដ្ឋាន។
៣.	ព្រះចូឡាមណីចេតិយថ្កើងថ្កាន	តាវតឹង្សទីស្ថានបរមសិរី
	ជំកល់កេសាព្រះជិនស្រី	ចង្កូមកែវថ្លៃខាងលើខាងស្តាំ។
៤.	ចូរយើងបរិស័ទ្យសិក្សាចងចាំ	ពាក្យពេចន៍ទ្រងផ្តាំកុំរស់ប្រមាទ
	សីលទានភាវនាប្រឹងឱហាត	ខិតខំសំអាតកំចាត់កិលេស ។
៥.	ចេតិយខ្សាច់សល្អល្អះអ្វីម្លើះ	រចនាវិសេសជាបទុមា
	បូជាផ្តាស្រស់ស្មោះទាំងចិន្តា	ដោយក្តីជ្រះថ្លាចេញពីកាយចិត្ត ។
៦.	និគ្រោធវ័នវត្តប្រពៃពិត	សមណនិសិត្សសិក្សាវិន័យ

បដិបត្តិបូជាជ្រះថ្លាពេកក្រៃ បរិស័ទ្យប្រុសស្រីត្រេកអរសាទរ។

៧. សាធុសាធុក្រោមឱវាទល្អ រស់ក្រោមម្លប់ធម៌ត្រេកអរគ្រប់គ្រា

សាងសុខកុសលផលបូជា សូមអនុមោទនាសាធុសាធុ។

៧ ។ ១៤ .ចែត្រ .រកា .ព.ស ២៥៦១

សៅរ៍ ទី ១៤ មេសា ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៤០ អក្ខរាសាក្សី

បទ ពាក្យត្រាំម៉ី

១. ខ្ញុំចាំអ្នកភ្លេចខ្ញុំភ្លេចកត់ត្រា ខ្ញុំយកអក្ខរាធ្វើជាសាក្សី
ខ្ញុំគ្មានគំនិតគិតប៉ងអប្រិយ ខ្ញុំធ្វើដើម្បីត្រឹមកុសលទាន។

២. ជីវិតតែមួយរស់ដោយបាយបាត្រ ទោះស្អាតមិនស្អាតមិនត្រែកតាមឃ្លាន
សន្តោសតាមអត់អំណត់តាមមាន រក្សាសីលទានតាមពុទ្ធឱវាទ។

៣. អ្នកដឹងទើបដឹងទើបយល់សេចក្តី អ្នកដែលយល់ន័យអ្នកបរិសុទ្ធស្អាត
រស់ក្រោមម្លប់ធម៌អ្នកកុំប្រមាទ បណ្ឌិតដែលឆ្លាតទើបរួចផុតទុក្ខ។

៤. ចិត្តត្រូវរឹងមាំចិត្តត្រូវស្វាហាប់ ចិត្តត្រូវចិត្តប្រាប់លះបង់យកសុខ
ឱវាទបាតិមោក្ខយកជាប្រមុខ ត្រូវចងចាំទុកដាក់សន្តាន ។

៥. កុសលសុច្ចរឹតពិតសាងដោយងាយមិនត្រូវទន់ជ្រាយត្រូវធ្វើឲ្យបាន
កាលណាខន្ធប្រាំអន្ទោលតាមប្រាណបើចង់ថ្កើងថ្កានមានតែសីលទាន ។

១ . ឧសភា . ២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៤១ លាហើយសង្សារ

បទ ពាក្យត្រាំបី

១. យោជន៍ឆ្ងាយសម្រាប់អ្នកដែលដើរផ្លូវយប់យន់យូរជ្រៅដ្បិតដេកមិនលក់
សង្សារវែងឆ្ងាយដល់ជនលាមក បាបធ្លាក់នរកដ្បិតគ្មានសីលទាន។

២. បើមិនរៀនធម៌អង្គព្រះជិនស្រី មិនមានវិន័យធម៌ព្រះធរមាន
ព្រះពុទ្ធឱវាទយកជាប្រធាន ទើបសត្វរស់រានគ្មានជាប់ជំពាក់។

៣. បើស្រលាញ់ខ្លាំងទុក្ខខ្លាំងអនន្ត មានប្តីប្រពន្ធអត់ធន់ស្មោះស្ម័គ្រ
កុំហ៊ានតាមចង់ក្បត់ផិតលួចលាក់ សង្សារវដ្ត:វែងឆ្ងាយប្រាកដ។

៤. មានះអាងអួតអំនួតអាគម ទោស:ខឹងគុំគំនុំស្បែស្បថ
លោភលន់ហួសហេតុព្រំដែនកំណត់ច្បាស់ជាកំសត់សង្វេគក្រៃលែង។

៥. មេត្តាទន់ភ្លន់សព្វសត្វទាំងឡាយ នាំសត្វសប្បាយរីករាយហួសថ្លែង
ករុណាមានពិតជីវិតគម្តែង សព្វទីកន្លែងត្រូវឧបេក្ខា។

៦. ឃើញគេមានបានត្រូវចេះត្រេកអរ នេះគឺជាធម៌ឈ្មោះមុទិតា

កំណើតកើតហើយមានសត្វសង្ខារ គួរឲ្យអនិច្ចាធម្មជាតិមិនទៀង។

៧. សង្វៃគសត្វលោកសង្វៃគខ្លួនឯង កម្មលោកចាត់ចែងតាមរាល់រូបរាង
កុំខឹងមេឃក្តៅកុំខឹងមេឃភ្លៀង ស្រណោះរៃច្រៀងវក់ជាប់សម្លេង។

៨. កើតម្សិលសោះស្រណោះទារក ដេកយំងុយងោកនេះហៅកូនក្មេង
ដល់ធំពេញវ័យក៏ចេះរត់លេង ថ្ងៃមួយសម្លេងខ្លងខែកចូលដល់។

៩. ឱ!សង្សារវដ្តលាហើយលាទៀត លាអស់ជៅញាតិលាឆោមនិមល
លាអស់ធម្មជាតិកើតស្លាប់វិលវល់ លាហើយឈប់ឆ្ងល់វដ្តៈសង្សារ។

៤ ។[99]ចែត្រ.ព.ស.២៥៦២

ពុធ . ២៥. មេសា .២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៤២ អាសូរបងស្រី

បទ ពាក្យត្រាំថ

១. សម្រក់ទឹកភ្នែកអាសូរជីវិត នឹកឃើញអាណិតជីវិតបងស្រី
ខិតខំធ្វើការបម្រើជើងប្តី កម្មលោកចង្រៃចង្អៀតអ្វីម្ល៉េះ។

២. អាណិតបងស្រីគ្មានសេចក្តីសុខ រស់នៅជួបទុក្ខវិបត្តិចាក់ស្រេះ
មិនបានរៀនខ្ពស់មានប្រាជ្ញតម្រេះ ហើយមានចំណេះដូចពួកប្អូនៗ។

៣. គ្រួសារលំបាកតោកយ៉ាងទុរគត បងស្រីអត់ធ្មត់ចិញ្ចឹមកូនៗ
ប្រុសព្រានទាំងឡាយឃ្លាតឆ្ងាយសោះសូន្យបងចិញ្ចឹមកូនទាំងខ្លួនកូនខ្ចី។

៤. ឱស!ឱ!មិត្តអើយឃើញហើយសង្វេគ ស្តាប់ហើយទឹកភ្នែកប្អូនធ្លាក់ដល់ដី
បងជាម្តាយពិតស្មិទ្ធស្មាលថ្នមបី ទឹកចិត្តបងស្រីរកថ្លែងមិនអស់។

៤ ។[99]ចែត្រ.ព.ស.២៥៦២

ពុធ . ២៥. មេសា .២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៤៣ កុំខ្វល់.....

បទ ពាក្យឆ្នាំមី

១.	កុំខ្វល់ច្រើនពេកកុំឆ្ងល់រឿងឆោត	កុំត្រចៀកប៉ោតកុំមិនដឹងខ្យល់
	កុំវង្វេងល្ងង់កុំលង់អំពល់	កុំវក់វិលវល់វិលក្នុងវដ្ដៈ។
២.	ទុក្ខច្រើនក្រៃក្រាស់ទុក្ខណាស់រាគៈ	ទុក្ខជ្បិតទោសៈទុក្ខមោហៈក្រៃ
	ទុក្ខអវិជ្ជាទុក្ខគ្មានលោះថ្ងៃ	ទុក្ខព្រោះកាឡៃទុក្ខព្រោះតណ្ហា។
៣.	ចង់មិនប្រណីចង់តាមប្រាថ្នា	ចង់មានបញ្ហាចង់លោភលន់អ្វី
	ចង់បានទោះស្លាប់ចង់ដឹងលោកិយ	ចង់បានរូបថ្លៃចង់ចាប់ស្តាប់ស្ងួន។

៤ ។[99]ចែត្រ.ព.ស.២៥៦២

ពុធ . ២៥. មេសា .២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៤៤ តពស្នេហា

បទ ពាក្យឆ្មាំមី

១. ស្នេហាយុវវ័យស្នេហាមានមែន កើតទុក្ខច្រើនសែនច្រណែនឬស្យា
ស្រលាញ់និងស្អប់បញ្ចប់សង្ខារ មានតួអក្ខរាចារជាសាក្សី ។

២. ស្រលាញ់ខ្លាំងណាស់ទុក្ខក៏ខ្លាំងដែរ ឱ!ភក្តីស្នេហ៍ប្រួលប្រែសារថ្មី
ដុល្លពង្វក់លក់ទឹកលក់ដី ព្រោះតែរូបស្រីឲ្យថ្លៃខូចចិត្ត ។

៣. ស្នេហ៍ប៊ុនធឿនពិតផ្តាច់ជីវិតស្រី វិធាវីក្ស័យផ្តាស្រពោនស្ងិត
តភាគស្នេហាវាសនាចៅចិត្រ ឃុន នារីស្និទ្ធស្នេហ៍ជ្រែកវណ្ណៈ ។

៤. ស្នេហានេនទុំ ទុំមុនស្រគាល នំធំជាងនាឡិនាងទាវស្មោះស្ម័គ្រ
ស៊ូក្សិណក្ស័យកាយស្លាប់ទាំងពីរនាក់គូរស្នេហ៍អមតៈចារជាដំណាល។

៥. ស្រលាញ់មិនខុសមានទោសបំពាន តណ្ហាស្រែកឃ្លានរាប់ភពកេរកាល
ស្លាប់កើតៗស្លាប់នៅមិនរាងចាល កើតឋានកណ្តាលក្នុងភពស្នេហា។

៥ ។[៥].បុស្ស .ព.ស.២៥៦៣ ចន្ទ . ៣០. ធ្នូ .២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៤៥ ស្នេហ៍ពីររសជាតិ

បទ ពាក្យត្រាំបី

១.	អំបិលរសប្រៃនិស្ស័យសមុទ្រ	ស្ករផ្អែបំផុតនិស្ស័យអំពៅ
	ដូងចិត្តស្នេហាកប់ទុកយ៉ាងជ្រៅ	ស្នេហាតាំងនៅដោយក្តីស្រលាញ់។
២.	បេះដូងបរិសុទ្ធមានតែក្នុងទ្រូង	រសផ្អែមទឹកដូងផឹកដោយក្នក់ក្នាញ់
	តួឯកតួក្បត់មានឈ្នះមានចាញ់	ព្រួញស្នេហ៍ត្រូវបាញ់ត្រូវត្រង់តួឯក។
៣.	កើតមកក្នុងលោកតែមានគូគ្រង	ស្នេហាអូនបងមានអ្វីចម្លែក
	មនុស្សមានបេះដូងតែងរងទឹកភ្នែក	ក្តីស្នេហ៍រំលែកបែងចែកចុងដើម។
៤.	អំបៅផ្អែមគល់ទល់សាបក្បែរចុង	នួននាងឆោមយ៉ង់លង់ក្នុងដង្ហើម
	ច្រណែនឈ្នានីសក៏តាំងចាប់ផ្តើម	នាងចុងនាងដើមពុះចែកស្វាមី។
៥.	ល្បិចកលលាក់ពុតក្នុងវិញ្ញាណកម្ម	ពាក្យថារង់ចាំពិបាកលើសអ្វី
	តម្រាសាច់កម្មចាំស្នេហ៍ភក្តី	ទឹកចិត្តពិជ័យសង្ត្រាមឈឺចាប់។
៦.	មណីតារារង្សី	រង់ចាំស្វាមីពិជ័យលុះស្លាប់

សុវណ្ណមាលាជាអ្នកសម្លាប់ អ្នកដែលឈឺចាប់គឺជារូបខ្ញុំ។

៧. ឧត្តមភរិយាជាអ្នករងទុក្ខ ជាប់ទោសជាប់គុកនៅក្នុងវាំងធំ
អ្នកដែលបានសុខសុវណ្ណមាសមុំ បងនៅជុំរំទ័ពមិនដឹងសោះ។

៨. ក្រោយពីសង្គ្រាមឈាមជោគធរណី ពានយសនារីជាពានក្រៀមក្រោះ
ពានរង្វាន់នេះអស់ភក្តីស្មោះ ឲ្យនាងរងគ្រោះបាត់ឈ្មោះក្នុងលោក។

៩. សល់ត្រឹមតែធាតុចង្អៀតលោកា បាត់ស្រស់កន្ទិដ្ឋាតារជ័យជោគ
ងងឹតវាំងច័ន្ទលាក់ពួនល្បិចឈ្លក គេបានលៃលកដាមដានស្នេហ៍ចាស់។

១០. ស្លេះចប់សង្ខេបដោយអាថ៌កំបាំង សល់ស្នូររគាំងទុកប្រវត្តិសាស្ត្រ
លាក់ទុកក្នុងចិត្តងងឹតខ្លាំងណាស់ ជាតិនេះចាំច្បាស់លៃងក្បត់ចិត្តស្រី។

០១ ។[12] ផល្គុន .ព.ស.២៥៦២

អាទិត្យ . ១៧. មីនា .២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៤៦ ស្រមោលស្នេហ៍

បទ ចាប់ខទ(៧ បទ)

១. ស្រមោលស្នេហ៍ តែស្រម៉ៃ ថ្លៃរៀមនឹក
រៀមរលឹក នឹកសង្សារ ណាណាស់ស្រី
ស្រមោលស្នេហ៍ ថៃថួនអ្នក លក្ខណ៍កវី
រៀមរីងរ៉ៃ ថ្លៃសោយសោក ជោគជ័យកម្ម។

២. សរមភូមិ ខ្ញុំស្រម៉ៃ ថ្លៃសង្វេគ
ដោយទឹកភ្នែក ជ្រែកដោយឈាម រៀមចងចាំ
សង្គ្រាមជាតិ ញាតិទឹកភ្នែក ស្រែកសួរផ្តាំ
ពាក្យបណ្តាំ ចាំបណ្តាក់ ជាក់បណ្ឌិត។

៣. បណ្ឌិតដឹង ប្រឹងរំដោះ ស្មោះស្ម័គ្រស្នេហ៍
ស្នេហ៍ថិតថៃ ស្នេហ៍ទឹកដី នៃញាតិមិត្ត
មិត្តមាតុភូមិ ខ្ញុំខេមរា ចារជាប់ចិត្ត

ចិត្តគំនិត គិតរឿងជាតិ ញាតិគ្រួសារ។

៤. សារបេះដូង ទ្រូងធរណី ទីរក្សា

សារចរចារ ថាលើសលប់ ឈប់ស្នេហា

ហាពោលស្លាក ខ្ជាក់វាស្លែង តែងបញ្ហា

ហាពោលថា ថ្លាថ្លែងទៅ ត្រូវទ្រូងឯង។

៥. បងជាប្តី ប្តីជីវិត ពិតស្មោះស្ម័គ្រ

បងជាអ្នក ជាក់ជាជន ពុនរ៉ែកសែង

បងជាប្តី ប្តីមានឈ្មោះ យសតំណែង

បងជាំក់ស្តែង តែងជោគជ័យ ស្រីជួយបង។

៦. បងជាប្តី ប្តីតែម្នាក់ លាក់អូនទុក

បងជាពុក ទុកប្អូនស្រី ប្តីនួនល្អង

បងជាមិត្ត មិត្តភុំធាន ប្រាណស្នេហ៍ស្នង

បងជាបង បងប្រពន្ធ ពុនមួយជាតិ។

៧. ប្តីប្រឹងប្រែង តែងធ្វើការ ណាសុចរិត

ប្តីប្រឹងពិត ចិត្តស៊ូទ្រាំ នាំផៅញាតិ

ប្តីប្រឹងព្រោះ រស់កិត្តិយស រស់រសជាតិ

ប្តីប្រឹងទៀត ឃ្លាតមិនបាន ប្រាណជាតិខ្មែរ ។

៨. ធ្វើមេទ័ព ភ័ព្វសំណាង សាងដោយអូន

ធ្វើមេប្អូនកូនយើងល្អ សរចិតថៃ

ធ្វើមេក្បួន ជួនផ្លាស់ក្បាច់ ស្រេចប្រួលប្រែ

ធ្វើមេស្នេហ៍ ដៃរដៃលស្មោះ ព្រោះទឹកដី ។

៩. ដីដែលដាំ ដាំចិត្តស្មោះ ស្មោះទឹកដី

ស្រីស្រស់ស្រី ស្រីស្រស់ស្អាត ស្អាតស្រស់ស្រី

ព្រៃស្នេហ៍ស្និទ្ធ ស្និទ្ធស្នេហ៍ស្នង ស្នងស្នេហ៍ព្រៃ

ក្តីស្នេហ៍ស្រី ស្រីគ្រប់លក្ខណ៍ លក្ខណ៍ភក្តី ។

១០. ក្តីស្នេហា ហាពោលពិត ពិតគ្រប់ក្តី

អ្វីដែលប្តី ប្តីពោលហើយ ហើយពោលអ្វី

ស្រីមានន័យ ន័យសួស្តី ស្តីសួគ៌ស្រី

ភ័យច្បាំងអ្វី អ្វីដែលអូន អូនភិយភ័យ ។

១១. អូនអើយអូន កូនអើយអន សនសួនសួន

សួនសុំសួន សួន សុខសប់ សប់សុខស្រី

ស្រីសរសើរ សើររកឿង រឿងរង្សី

ស្រីស្តាប់ស្តី ស្តីថ្លាថ្លែង ថ្លែងប្រាប់ប្តី ។

១២. ប្តីបមបី បីមាសមិត្ត មិត្តស្នេហ៍ស្នង

ស្នងស្នេហ៍ស្និទ្ធ ស្និទ្ធស្ម័គ្រស្មោះ ស្មោះស្វាមី

មីអរអា អាពោលពាក្យ ពាក្យនោះនៃ

នៃស្រស់ស្រី ស្រីនួននាង នាងពុំពោល ។

១៣. បានយោគយល់ យល់នួននាង នាងល្អល្អះ

នឹកនាងណាស់ ណាស់សែនសល់ សល់ស្រមោល

ប្តីនឹកនាង នាងនឹមនួន នួនតែកតោល

បងចុះចោល ចោលចេញចាក ចាកឆោមឆាយ។

១៤. រង់ចាំចិត្ត ចិត្តរ៉ារៀម រៀមរ៉ាប់រង

បងចាំចង ចងចាំចិត្ត ចិត្តស្រស់ស្រាយ

រាល់ទុក្ខទោស ទោសបងបាន បានឆើតឆាយ

សែនឆ្ងល់ឆ្ងាយ ឆ្ងាយអូនអើយ អើយនឹមនួន ។

០២ ។០៩ ភទ្របទ.ព.ស.២៥៦៣

សៅរ៍. ២៤. សីហា.២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យនេះ ប្រជុំជើងកាព្យពាក្យ៩ ក្នុងប្រធានបទតែមួយដែលកើតចេញពីបទជាប់ទង មាន៧បែប ក្នុងទម្រង់ថ្មី

- បទជាប់ទង
- បទជាប់ស្នេហ៍
- បទឈូករីកជាប់ទង
- បទឈូករីកឆ្លាស់ទង
- បទក្របចក្រវាឡជាប់ស្នេហ៍
- បទក្រងជាប់ស្នេហ៍
- បទក្រងជាប់ទង ។

កំណាព្យ ៤៧ ស្រមោលស្នេហ៍

បទ ពាក្យទ្រាំមិ

១. បេះដូងរងកម្មបញ្ចាំចិត្តស្នេហ៍ បេះដូងកូនម៉ែស្នេហ៍ស្មោះភក្តី
ស្រលាញ់មាតុភូមិស្មោះស្ម័គ្រទឹកដី អាណាចក្រល្បីអង្គរអច្ឆរា។

២. អប្សរលំអរដួងចិត្តមេទ័ព មន្តស្នេហ៍មានភ័ព្វជាប់ពាក្យសច្ចា
ផ្លែអារក្រោះលីផ្តាក់លើស្មា ជិះលើគុជសាប្រហារសត្រូវ។

៣. ស្តេចជ្វាលោភលន់វាទទីអំណាច មេទ័ពមិនខ្លាចអំណាចពាលខ្លៅ
ក្នុងភ្លើងសង្គ្រាមសន្ធោសន្ធៅ កប់ដោយផ្សែងខ្មៅព្យុះកម្មកំណាច។

៤. សុរិយង្គពេជ្រឯកដាវដែកមុខពេជ្រ ក្លាហានជានិច្ចកំទេចមិនខ្លាច
កាត់ក្បាលស្តេចជ្វាឈាមចេញបាញ់ឆ្ងាច ឈាមស្រោចបាចសាចស្រោចលើផែនដី។

៥. អយុធ្យាអើយដែនដីភូមិករ ស្នាមស្នេហ៍ដ៏ល្អកម្រមានស្រី
នាមនាងមណីតារាវត្តី ស្នេហ៍ស្មោះភក្តីជួយប្តីអស់ខ្វល់។

៦. វត្តអារាមសាងតំណាងសប្បុរស យើងបានរួមរស់កសាងមគ្គផល
ប្រាង្គព្រះវិហារយើងបានដំកល់ រួមសាងកុសលជួសជុលបដិមា។

៧. ធ្វើបុណ្យរាប់បាត្រតាមឱវាទព្រះ ព្រះពុទ្ធតេជៈឈ្នះស្តេចក្រុងមារ
រំលួសអកុសលផលចំណងពៀរ សង្គ្រាមពានពារលើអាយុសត្វ។

៨. អំណាចស្តេចចក្រសូរ្យរ៉ែន ព្រះរាមអាត្ម័នជាអង្គមហាក្សត្រ
ពង្រីកទឹកដីហើយទ្រង់បដិបត្តិ ទសពិធពិតសត្យសច្ចៈយុត្តិធម៌។

៩. កាលជ័យជំនះឈ្នះស្តេចក្រុងជ្វា សុវណ្ណមាលាជាស្រីបវរ
ទ្រង់ព្រះរាជទានធ្វើស្រីកំដរ ទ្រព្យធនហែរហូរនគរខាងលិច។

១០. លុះកាលជាតិជ្វាបង់បាត់មហាក្សត្រ ជាតិមានវិបត្តិវឹកវរជានិច្ច
ទឹកដីហិនហោចគ្រោះកាចត្រូវខ្ទេច តែក្រុមកកលល្បិចលាក់ខ្លួនក្នុងខ្មែរ។

១១. កាលនោះមេទ័ពឯកសេនាបតី សុរចក្រីរ៉ែនមណីវង្សខែ
សយុសយង្គភុជ្ជងភូសៃ មានរឹទ្ធពូកែថែដែនពាយ័ព្យ។

១២. សុវណ្ណវង្សរាជមនោមាល័យ ជាមេទ័ពល្បីថែដីដែលជាប់
ព្រំដែនចម្ប៉ារហូតតភ្ជាប់ កាន់ច្បាប់ទម្លាប់នៅភាគបូព៌ា។

១៣. សុវណ្ណភូមិនេះសំបូរដំរី រោងជាងរោងជ័យព្រៃព្រឹក្សរម្យនា
ទឹកជ្រោះទន្លេសមុទ្រមហិមា ក្នុងដែនកម្ពុជារាជាណាចក្រ ។

១៤. ចក្រភពអង្គរត្រូវផ្សព្វផ្សាយកេរ វប្បធម៌មាសមេមាសស្នេហ៍ស្មោះស្ម័គ្រ
គុនដាវលំពែងសីលមន្តអមតៈ សិល្បៈទស្សនៈទ្រព្យមេឃអង្គុយ។

១៥. បញ្ញវ័នជុំជិតពិតស្មោះបម្រើ ជាតិសាសន៍ប្រសើរលើគំនរលុយ
ចាយមាសដូរបាយក្អាកក្អាយឈ្ងុប់ឈ្ងួយ ដើរដេកងោកងុយម្ហូបឈ្ងុយបាយឆ្ងាញ់។

១៦. ប្រជាកសិកររកស៊ីតាមធម៌ សុចរិតបវរភារតស្រលាញ់
រួបរួមសាមគ្គីគួរក្នុកក្នាញ់ សង្គ្រាមមិនចាញ់ពូជខ្មាំងសត្រូវ ។

១៧. ខ្មាំងបរាជ័យក្នុងដៃក្លាហាន ពូជពាលសាមាន្យចោលប្រាណឆ្អឹងនៅ
ហ៊ានក្បត់ជាតិខ្លួនជាប់ទោសឃោឃៅ កាត់ក្បាលកាត់ភ្លៅបំបែកសាកសព។

១៨. រីតុលាការយុត្តិធម៌តាមច្បាប់ ត្រូវទោសចងចាប់សម្លាប់មិនឈប់
វិន័យម៉ត់ចត់អនុវត្តសព្វគ្រប់ រាជាជាម្លប់អំណាចក្រោមមេឃ។

០៦ ។[09.] ចែត្រ.ព.ស.២៥៦២

សុក្រ .០៥ .មេសា .២០១៩

និពន្ធ ភិក្ខុ បញ្ញាហ៊ានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៤៨ ម៉ែ!!!

បទ ពាក្យស្រាំបី

១. អរហំរីខ្ញុំករុណាព្រះគុណ សូមបំពេញបុណ្យគុណព្រះត្រៃរ័ត្ន
ប្រណមវន្ទាជាក់ជាប្រាកដ សូមលើកបែបបទកំណត់ពាក្យម៉ែ។

២. សូមរំឭកគុណបុណ្យគ្រូអាចារ្យ នឹកគុណអក្ខរាភាសាជាតិខ្មែរ
កំណើតកូនប្រុសពូជពង្សអ្នកស្រែ ថ្នមថ្នាក់បិតថែម៉ែបង្កើតពៅ ។

៣. នាមហួន រតនាសូរ្យពេជ្រ ចាប់ចាររំលេចពាក្យពេចន៍ពោលទៅ
ពីព្រះគុណម៉ែឲ្យបានត្រឹមត្រូវ កូនកំព្រាឪតាំងពីកុមារ ។

៤. ម៉ែជាព្រះរស់ពពោះកូនថ្លៃ ចិញ្ចឹមរាល់ថ្ងៃនិស្ស័យថ្លៃថ្លា
ម៉ែឲ្យកូនរៀនបានចូលសិក្សា ម៉ែជាអាចារ្យទេវតាក្នុងផ្ទះ ។

៥. ម៉ែជាព្រះព្រហ្មមានព្រហ្មវិហារ ករុណាមេត្តាដោយបុណ្យតេជៈ
ម៉ែជាសម្លាញ់មិត្តនៅក្នុងផ្ទះ ម៉ែគឺជាព្រះអរហន្តបុត្តថ្លៃ ។

៦. ម៉ែមានមន្តស្នេហ៍ល្អល្អះលើសស្រី ម៉ែថ្នមបបមបីប្រុសស្រីចរណៃ
ជាកូនជាចៅម៉ែឲ្យតម្លៃ គុណម៉ែក្រាស់ក្រៃកាត់ថ្លៃមិនបាន។

៧. ម៉ែមានសម្បត្តិចរិយាវិជ្ជ ម៉ែមានទ្រព្យចែកកូនកល្យាណ
ចង់ឲ្យកូនសុខផុតទុក្ខគ្រប់ប្រាណ មានលុយផ្ទះឡានហាន:សក្តិយស។

៨. ម៉ែពោលពាក្យពេចន៍រំលេចពាក្យល្អ ឲ្យស្គាល់ខ្មៅសធម៌អាថ៌ពិរោះ
ម៉ែបង្រៀនកូនឲ្យស្គាល់ទាបខ្ពស់ ស្អប់ខ្ពើមពាក្យឈ្លោះរកសន្តិបទ។

៩. ម៉ែតែងលាក់បាំងក្តីទុកលំបាក គ្រួសារតោកយ៉ាកលំបាកប្រាកដ
ម៉ែលើកទឹកចិត្តឲ្យកូនស៊ូអត់ ខន្តីអត់ធ្មត់ស្វែងរកវិជ្ជ។

១០. ម៉ែបានចំណីអ្វីមិនដែលលាក់ ស្នេហ៍កូនស្មោះជាក់ស្តែគ្រស៊ូពុះពារ
រកស៊ីចិញ្ចឹមដល់កូនគ្រប់គ្នា ទោះក្តៅរងារម៉ែឥតពោលស្តី។

១១. ម៉ែព្រោះតែកូនពេលខ្លះសាងបាប វាយត្រីបោចចាបឆ្អាបខ្លួនក្លិនត្រី
ក៏ព្រោះតែកូនបានហូបបានឆី ម៉ែធ្វើអ្វីៗចង់ឲ្យកូនសុខ។

១២. គុណម៉ែដប់ពីរធរណីមិនស្មើ ម៉ែពិតប្រសើរដំណើរផុតទុក្ខ
កូនបួសសងគុណជូនដល់ម៉ែពុក សូមឲ្យលោកសុខលុះអវសាន្តអើយ។

៥ ។[11]អាសាធ ជូត .ព.ស.២៥៦២
ព្រហស្បតិ៍.០២ .កក្កដា.២០២០
និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៤៩ វិសាខបូជា

បទ ពាក្យឆ្នាំមី

១. វិសាខបូជាជាថ្ងៃកំណើត ដែលអាត្មាកើតសេចក្តីរញ្ជក
អតីតកន្លងចងចិត្តដែលនឹក ទៅតាំងពីព្រឹកលើភ្នំបាខែង។

២. ឱ!ខេត្តសៀមរាបវិសុទ្ធិមគ្គ នឹកមិត្តភក្តិម្នាក់ដែលជាមិត្តឆ្មែង
កាលនៅគ្រហស្ថស្មោះស្ម័គ្រគម្តែង នឹងស្តីថ្លាថ្លែងដំណើរយាត្រា។

៣. កាលនោះរតនាសូរ្យពេជ្រ នឹកឃើញជានិច្ចដោយក្តីជ្រះថ្លា
ឃើញព្រៃឬស្សីដីច្រែនហិចតា សូប់ស្ងាត់ម្ល៉ះណាដោយធម៌អប់រំ។

៤. មនុស្សច្រើនអ៊ូអរស្តាប់ធម៌ស្ងាត់ឈឹង អ្នកដឹងទើបដឹងនៅក្នុងសង្គម
សង្ឃបុត្តជិនស្រីរស់យ៉ាងសុខុម ទើបបានរូបខ្ញុំសង្វេគសង្ខារ។

៥. សុំព្រះអង្គគ្រូនាមសានសប្បាយ បំបួសរូបកាយដោយក្តីជ្រះថ្លា
គុណព្រះឧបជ្ឈាយ៍ចៅអធិការ សាមណេររតនាសូរ្យពេជ្រពិត។

៦. ខិតខំរៀនសូត្រព្រះពុទ្ធវចនៈ រៀនលះវដ្តៈរស់ដោយសុច្ចរិត
អប់រំបន្ទំដុសខាត់ជីវិត មួយវស្សាស្មើទ្រាំខែកន្លង។

កំណាព្យ ៥០ ដំបូលលិចទឹក

បទ ពាក្យត្រាំបី

១. ដំបូលលិចទឹកនឹកដល់ឱវាទ ជាបទជាខ្នាតទូន្មានយ៉ាងល្អ
ជនមានរាគៈរស់នៅកំដរ ស្បែកសាច់ធ្មេញសរូបក្លិនសំឡេង។

២. មិនយល់សោះឡើយចំលើយលោភៈ យសសក្តិវណ្ណៈទឹកភ្នែកកូនក្មេង
លោភចង់តែបានតែធ្វើលេងៗ ពោលផ្សេងចិត្តផ្សេងកុហកបោកប្រាស់។

៣. បើចង់បានពិតតែចិត្តនៅពាល ជនតែងតិះដៀលពួកជនឥតខ្មាស់
សាងតែបាបកម្មវង្វេងខ្លាំងណាស់ កម្មកាចក្រៃក្រាស់នរកអវចី។

៤. មិនយល់សត្វលោកខំប្រឹងខ្លាំងម្ល៉ៈ តណ្ហាចាក់ស្រេះមិនដែលចេះភ័យ
ដឹងតែសប្បាយនឹងល្បែងស្រាស្រី នឹងម្ហូបចំណីវង្វេងសតិ។

៥. ធម្មតាធម្មជាតិជាប់ចិត្តស្រលាញ់ ក្និកក្នក់ក្និកខ្នាញ់លះសមាធិ
ពិភពលោកនេះសត្វតែងច្យុតិ តម្រាលិខិលិខិតកត់ត្រា។

៦. ដោយសារតែអញៗធំជាងគេ អញល្អម្ល៉ៈទេគួរឲ្យស្នេហា
គួរឲ្យស្នេហ៍ស្និទ្ធពេញចិត្តចរចារ លុះក្នុងបរាភវសូត្រសព្វ។

៧. មិនមានមង្គលអំពល់ទោម្នេញ វិនាសចាកចេញពីទ្រព្យកំណប់
សត្វលោកប្រាថ្នាមិនដែលចេះចប់ រឿងដុតរឿងកប់ចេះតែភ្លេចនឹក។

៨. នឹកឃើញតែស្រីនឹកឃើញតែស្រានឹកឃើញកាលណាភ្លេចល្ងាចភ្លេចព្រឹក
កុំថារឿងស្លាប់ដែលគួរចាប់ភ្លឹក សូម្បីបាយទឹកក៏មិនខ្ចីខ្វល់។

០៦ ។[09.] ចែត្រ.ព.ស.២៥៦២

សុក្រ .០៥ .មេសា .២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៥១ ខូចកេរ្តិ៍ឪ

បទ ពាក្យត្រាំម៉ី

១. លើកជើងដាក់ប្រុសខុសសីលធម៌ខ្មែរ ខូចកេរ្តិ៍ឪម៉ែខុសទំនៀមម្តាយ
លោកពោលអប់រំឱវាទទាំងឡាយបែរថាផ្សព្វផ្សាយចង់បានឡាយសែរ។

២. ចរឹតរមទម្យសុភាពរាបសារ នរណាទៅថាខុសសីលធម៌ខ្មែរ
ខុសប្រពៃណីថាស្តាយដូចឆ្កែ ដោយតាមវាលស្រែក្បែរមាត់សមុទ្រ។

៣. ដូចជាពោលជ្រុលឬក៏នៅស្ទើរ នៅតាមទង្វើឲ្យសមបំផុត
ចំពោះក្មេងពាលឌឺកាប់មិនមុត ពូកែប្រយុទ្ធយុទ្ធសាស្ត្រអន្ធពាល។

៤. មនុស្សតិរិច្ឆានព្រះបានសម្តែង តាមចិត្តចាត់ចែងគំនិតរោលរាល
រៀបរាប់មិនអស់ពាក្យពោលតិះដៀលក្មេងជនអន្ធពាលពោលស្តីមិនស្តាប់។

៥. ថោកទាបម្លឹងហើយនៅឡើយធ្វើហី យោបល់ពោលស្តីខែងរ៉ែងចំណាប់
មិនចេះឈឺចិត្តរឿងពិតឈឺចាប់ពាក្យដែលលោកប្រាប់តិចតួចប៉ុណ្ណោះ។

៦. ឈ្មោនីសច្រណែននិន្ទាពួកអ្នក តើចំណេញជាក់ប៉ុន្មានទានប្រោស

បានប៉ុន្មានបាត្របាយពួកស្រីប្រុស ខំប្រឹងយកទោសឲ្យអ្នកប្រមាថ។

៧. ទៅរៀនមួយថ្ងៃក៏ប្រាំដុល្លា រៀនធម៌ទេសនាក៏ចិត្តថ្លាស្អាត
បើមិនដឹងខ្យល់មិនស្គាល់ច្បាប់ខ្នាត មិនខំសង្វាតក៏មិនចេះដែរ។

៨. បើតាមសម្តីដូចក្មេងបាតផ្សារ ដូចគ្មានកិច្ចការធ្វើនៅស្រុកខ្មែរ
ចេះធម៌ជ្រាលជ្រៅនៅស្តាយដូចឆ្កែ គ្មានពូជឪម៉ែបារប្រៀនប្រដៅ។

៩. តាមតែសាច់ឈាមនាមកូនសេដ្ឋី តែចរិតស្រីគ្មានពូជពង្សផៅ
ពោលស្តីតិចតួចតែបែរជាក្តៅ ឱវាទប្រដៅឲ្យខ្លួនល្អសោះ។

១០. បើមិនស្គាល់ខុសទោសក្មេងព្រហើន ច្បាស់កើតកកើនវប្បធម៌សាបព្រួស
ម៉ែឪអាប់យសព្រោះកូនស្រីប្រុស បើដឹងកំហុសទើបជាបណ្ឌិត។

១១. សូមអធ្យាស្រ័យញោមប្រុសញោមស្រីដែលបានពោលស្តីថាកូនអ្នកពិត
ចង់ឲ្យគេល្អមិនដូចតាមចិត្ត សមតាមគំនិតចិត្តធម៌សប្បុរស។

០៦ ។[09.] ចែត្រ.ព.ស.២៥៦២

សុក្រ .០៥ .មេសា .២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៥២ ឈាមតែមួយ

បទ ពាក្យឆ្នាំមី

១. អ្នកមានលោហិតឈាមជ័រតែមួយ អ្នកកើតទុក្ខព្រួយរឿងរ៉ាវក្នុងលោក
អ្នកមានទឹកចិត្តជួយគិតលៃលក អ្នកខិតខំរកផ្គាប់ចិត្តតណ្ហា។

២. សង្គមគ្រួសារចិន្តាថ្នមថ្នាក់ បងប្អូនស្មោះស្ម័គ្រជ្រោមជ្រែងគ្រួសារ
វាចារៀបរាប់គាប់ចិត្តស្នេហា មនោសញ្ចេតនាញាតិរួមឈាមមួយ។

៣. ដួងចិត្តតែមួយគ្មានពីរចំណែក សម្រាប់បែងចែកចាត់ចែងទុក្ខព្រួយ
អ្នកស្លាប់បន្តក៏ជាជំនួយ សតិជួបជួយពញ្ញាក់ស្មារតី។

៤. បេះដួងបរិសុទ្ធមិនស្គុតបញ្ហា រឿងក្នុងលោកាឈ្លោះទាស់សម្តី
ព្រោះទ្រព្យសក្តិយសកេរ្តិ៍ឈ្មោះមន្ត្រី លក់កោះកេរ្តិ៍ដីមត៌កដូនតា។

០៦ ។[09.] ចែត្រ.ព.ស.២៥៦២

សុក្រ .០៥ .មេសា .២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៥៣ អាសូរគ្រូផង

បទ ពាក្យត្រាំម៉ី

១. អាសូរគ្រូផងនួនល្អងជាសិស្ស អ្នកកុំហ៊ានល្មើសលួចស្នេហ៍លោកគ្រូ
គ្រូលុយតិចណាស់អូនកុំតស៊ូ ចង់បានប្តីគ្រូរអ៊ូមិនឈប់។

២. បើបងជាគ្រូបងត្រូវតែស្តី បើបងជាប្តីបងត្រូវធ្វើម្លប់
ថ្នាក់ថ្នមទាំងថ្ងៃថ្នាក់ថ្នមទាំងយប់ ឲ្យអូនសំណព្វកប់ក្នុងបេះដូង។

៣. បើនៅជាសិស្សអូនកុំល្មើសអី បងជាគ្រូស្រីមើលកំហុសឆ្គង
បើនាងស្លៀកខ្លីមើលមិនទំនង ត្រូវគ្រូរ៉ាប់រងគេដៀលនិន្ទា។

៤. បើអ្នកលាបសក់ហាយឡាយក្រហម តែងខ្លួនមិនល្មមសមសិស្សរម្យនា
ខោចលើខោចក្រោមមិនខ្លាចរងារ ខុសសិស្សកម្ពុជាសុភាពរម្យទម្យ។

៥. បងជាគ្រូអូនជាកូនកសិករ បងជាគ្រូល្អលំអរសង្គម
ហាន:ជាគ្រូមិនសូវធំដុំ កូនសិស្សក្រមុំកុំសុំគ្រូស្នេហ៍។

៦. ឱ! ពេលវេលាជារឿងអភ័ព្វ គ្រូបង្រៀនជាប់នៅតាមស្រុកស្រែ
ឱ! សិស្សក្រមុំសុំចិត្តប្រួលប្រែ ដ្បិតតែប្រាក់ខែគ្រូសែសិបម៉ឺន។

៧. ទឹកហ្វឺតក្តារខៀនបង្រៀនឡើងសឹក ទៅទាំងថ្ងៃព្រឹកបង្រៀនយ៉ាងច្រើន
ឱ! សិស្សស្រីៗចេះតែកើតកើន ស៊ីត្រឹម១ម៉ឺនដុល្លាទេបង។

៨. បង្រៀនដប់ឆ្នាំចាំអូនឡើងស្កូវ ប្រាក់ខែឥឡូវដណ្តឹងនួនល្អង
គូព្រេងលោកគ្រូដប់ឆ្នាំកន្លង ទើបជួបស្នេហ៍ម្តងជ្បិតបងស្មោះត្រង់។

៤កើតជេស្ឋ ចរ ព.ស២៥៦២

សុក្រ ១៨ ឧសភា ២០១៨

និពន្ធ ភិក្ខុបញ្ញាហានោ

កំណាព្យ ៥៤ ចាស់ចង់ក្មេង

បទ ពាក្យប្រាំមួយ

១. ចិត្តនេះពិតប្លែកណាស់ ខ្លួនកាន់ចាស់ម្តេចចង់ក្មេង
ចាស់ហើយកុំចង់លេង ដូចជាក្មេងមិនទាន់ធំ។

២. ចាស់ហើយកុំជោរពេក ដើរ ឬ ដេកធ្វើឲ្យសម
រស់នៅក្នុងសង្គម ភាពឧត្តមភាពថ្លៃថ្នូរ។

៣. កុំសើចមិនខ្ចប់មាត់ កាន់ឈើច្រ័តកុំវាយគោ
កាន់សីលប្រាំជ្រងោ គេលឺសូរតែអាស្រូវ។

០៦ ។[09.] ចែត្រ.ព.ស.២៥៦២

សុក្រ .០៥ .មេសា .២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៥៥ ជនខូច ជនល្អ

បទ ពាក្យត្រាំមី

១. មនុស្សខូចដូចទឹកកន្លះប៉ោត មនុស្សឆោតដូចប៉ោតស្អាតទទេ
មនុស្សរឹងមានះចង់តែឈ្នះគេ មនុស្សចេះរិះរេគិតរកកុសល។

២. មនុស្សល្អដូចថ្មភ្នំធំមាំតាន់ មិនចេះប្រកាន់ដោយអាងហេតុផល
ដួងចិត្តពិតស្រលាញ់ដោយដំកល់ នៅក្នុងកុសលមគ្គផលនិព្វាន។

០៦ ។[09.] ចែត្រ.ព.ស.២៥៦២

សុក្រ .០៥ .មេសា .២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៥៦ សម្លឹងកោះត្រល់

បទ ពាក្យត្រាំមី

១. សម្លឹងកោះត្រល់អស់ខ្ទល់កន្លង ពាក្យស្នេហ៍អូនបងចងជាអក្ខរា
លើកំពូលភ្នំបូកគោស្នេហា សល់ត្រឹមចិន្តាដោយក្តីអាល័យ។

២. សម្លឹងកោះត្រល់នឹកដល់ក្តីទុក្ខ បងប្អូនជាប់គុកទារុណព្រៃផ្សៃ
មើលហើយស្រណោះនឹកគិតស្រមៃ ជីវិតសាបប្រៃកាឡៃមាសសុទ្ធ។

៣. សម្លឹងកោះត្រល់នឹកដល់ដីកោះ អាល័យអាឡោះជាទីបំផុត
សម្រស់ព្រៃភ្នំជំរុំបរិសុទ្ធ មើលឃើញតក់ស្លុតរន្ធត់ចិត្តណាស់។

៤. សម្លឹងកោះត្រល់នឹកដល់កេរខ្មែរ កោះកេរប្រួលប្រែសែនស្រណោះម្ចាស់
បានត្រឹមសម្លឹងដឹងថាប្រែផ្លាស់ ដីដែនកម្មក្រាស់ក្នុងដែនអភ័ព្វ។

០៦ ។[09.] ចែត្រ.ព.ស.២៥៦២

សុក្រ .០៥ .មេសា .២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៥៧ ម្លប់ឈើ

បទ ពាក្យត្រាំមី

១. ឈើត្រឹមមួយដើមទុកគ្រាន់ជ្រកម្លប់ នឿយហត់គ្រាន់ឈប់សម្រាកមួយគ្រា
កុំកាប់រំលំកុំបំផ្លាញវា ទុកឲ្យល្អជាបានផលផ្លែផ្កា។

២. តែដើមឈើខ្លះស្អុយគល់ដាច់ចុង រលួយដល់ក្នុងពិបាកនឹងថា
មិនចាប់អារម្មណ៍ខ្ពើមទាំងស្នេហា ចង់ចរយោគ្រាឲ្យហួសតែម្តង។

៣. រស់នៅត្រូវយល់ស្គាល់តួនាទី រស់ត្រូវសំភីជីវិតស្នេហ៍ស្នង
កុំប្រឹងហួសហេតុនាំទុក្ខសៅហ្មង ស្គាល់សុខទុក្ខផងដល់អ្នកដទៃ។

០៦ ។[09.] ចែត្រ.ព.ស.២៥៦២

សុក្រ .០៥ .មេសា .២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៥៨ កវី

បទ ពាក្យឆ្នាំមី

១.	សីលសាយសុះសព្វ	រ៉ាយរ៉ាប់រៀបរាប់	គន់គូរគិតគាប់
	បន្តបន្ទាប់	ឈ្ងុយឈ្ងោកឈ្ងុយឈ្ងប់	ព្រលឹមព្រលប់
		យប់យង់យន្តយូរ។	
២.	រួសរាយរក្សា	រាក់ទាក់ចរចារ	ចូលចិត្តគួសគួរ
	តាក់តែងរិះរក	ប្រឹងប្រែងសិក្ខស៊ូ	គំនិតគំនូរ
		ករិកវី។	
៣.	ព្រះសង្ឃព្រះសូត្រ	សីលសង្ឃស្លូតបូត	សិរីសួស្តី
	ព្រះព្រហ្មព្រះពរ	រុងរោចរង្សី	មានមន្តប្រពៃ
		សីលល្អទុនទាន។	

០៦ ។[09.] ចែត្រ.ព.ស.២៥៦២

សុក្រ .០៥ .មេសា .២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៥៩ ជីវិតរស់នៅ

បទ ពាក្យឆ្នាំមី

១. ជីវិតក្នុងកាយជីវិតក្នុងសាច់ ជីវិតប្តូរផ្តាច់ជីវិតសាច់ស
ជីវិតស្នេហាជីវិតភ័ព្វល្អ ជីវិតកំដរជីវិតក្រសុខ។

២. រស់នៅសុខទុក្ខរស់នៅវេទនា រស់នៅកំព្រារស់នៅជួបទុក្ខ
រស់នៅកំសត់រស់នៅអត់ពុក រស់នៅតាំងទុករស់នៅសុចរឹត។

០៦ ។[09.] ចែត្រ.ព.ស.២៥៦២

សុក្រ .០៥ .មេសា .២០១៩

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៦០ សិទ្ធនារី

បទ ពាក្យត្រាំបី

១. សិទ្ធិនារីជាសិទ្ធិស្ត្រី តែមុនធ្វើអ្វីគោរពបុរស
កុំចេញមាយាកុំបញ្ចេញដោះ បញ្ចេញកេរ្តឹ៍នោះទាស់ខុសពេកហើយ។

២. នារីជាម្តាយមាតាលោកិយ រៀបឬកពោលស្តីពាក្យពោលឆ្លងឆ្លើយ
ឲ្យស្គាល់ឋានៈពាក្យពិតមុនក្រោ រាចាចំលើយសមស្ត្រីភេទ។

៣. ស្ត្រីសព្វថ្ងៃគេលើកកំពស់ កុំធ្វើអាប់យសព្រោះគេសង្កេត
ខូចខ្លួនមុនការអាងថាចូលពេទ្យ ខ្លះជ្រុលកើតអេដស៍ដ្បិតស្រីចិត្តងាយ។

៤. មនុស្សស្រីជាជនអឋានៈ គ្មានយសគ្មានសក្តិថោកទាបទន់ជ្រាយ
ទើបភិក្ខុនីដាច់ពូជរលាយ ពួកប្រុសទាំងឡាយតែងចោមចាប់ចិត្ត។

៥. រំលោភបំពានគ្មានអាសូរស្រី ទើបភិក្ខុនីគួរឲ្យអាណិត
ទើបស្រីសព្វថ្ងៃមិនអាចប្រព្រឹត្ត កោរសក់ចូលជិតឧបសម្បទា។

៦. អស់ហើយគុណធម៌សត្វលោកទាំងឡាយអរហន្តខ្ចាត់ខ្ចាយសប្បាយពាលា
វង្វេងក្នុងភពជាប់ចិត្តការងារ រស់ខ្វះធម្មារងារពេកពន់។

៧. បួសសឹកនឹកណាស់សុខទុក្ខវេទនា រស់ដោយកំព្រាប្រាថ្នាកាមគុណ
ចង់នោះសព្វគ្រប់ភពភ័ព្វប្រពន្ធ ស្រីល្អសសុន្ទរ៍ប្រពន្ធប្រពៃ។

១៥កើត ជេស្ឋ ចរ ព.ស ២៥៦២

អង្គារ ២៩ ឧសភា ២០១៨

និពន្ធ ភិក្ខុបញ្ញាហានោ ហួន រតនាសូរ្យ ពេជ្រ

កំណាព្យ ៦១ ក្រពើចាញ់គភ៌

បទ ពាក្យត្រាំបី

១.	ក្រពើជាសត្វពាលយង់ខ្នង	ក្រពើនេះផងកុំយកអាសារ
	ក្រពើកលល្បិចកល់ឬស្យា	ក្រពើប្រាថ្នាបេះដូងគេ។
២.	ប្រពន្ធចាញ់គភ៌ឃ្លានចម្លែក	ប្រពន្ធល្អឯកគិតរិះរេ
	ប្រពន្ធប្រាប់ប្តីស្រីមាសមេ	ប្រពន្ធមាសស្នេហ៍ឃ្លានស៊ីស្វា។
៣.	ក្រពើចិញ្ចាវាចាប្រាប់	ក្រពើប្តីស្តាប់ហើយតបថា
	ក្រពើអូនស្រីប្តីយាត្រា	ក្រពើអូនណាកុំបារម្ភ។
៤.	ក្រកិច្ចក្រកល់សែនខ្ទល់ខ្ទាយ	ក្រស្វាស៊ីស្វាយឆ្លងត្រើយធំ
	ក្រស្វាមាឧមាំព្រះបរម	ក្រស្វាមាសមុំអាងត្របាក់។
៥.	ឃ្លានណាស់ចង់ផ្តាប់បេះដូងស្រី	ឃ្លានណាស់ពិសីស្រីវលក្ខណ៍
	ឃ្លានណាស់នូងល្អងបងព្រមស្ម័គ្រ	ឃ្លានណាស់ច្បាស់ជាក់ស្រីចាញ់គភ៌។
៦.	បេះដូងបងមួយជូនអូនបាន	បេះដូងកល្យាណស្រស់បវរ

បេះដូងស្វានោះច្បាស់ជាល្អ បេះដូងកំរទើបឃ្លានឆី។

៧. ដូងត្នោតត្រៀបត្រាផលាស្អេកស្អះ ដូងត្នោតច្រើនណាស់សំបូរព្រឹក្សព្រៃ
ដូងខ្នុរទុរេនស្វាយទុំខ្លី ដូងស្វាយចំណីសត្វទាំងឡាយ។

៨. ស្វាហក់ផ្លោះផ្លោតបញ្ឆោតថ្ម ស្វាប្រាជ្ញាល្អសែនសប្បាយ
ស្វាតែងឆ្លងត្រើយទៅឆីស្វាយ ស្វាមីទាំងឡាយផ្គាប់ចិត្តភរិយា។

៩. ក្រពើទេវទត្តក្លែងជាថ្ម ក្រពើធ្វើល្អប្រាកដជា
ក្រពើស្ងៀមស្ងាត់ព្រោះពុំងារ ក្រពើចិញ្ចាមានចំណង់។

១០. សត្វស្វាល្ងៀសល្ងៃឈ្លាសឆ្លាតណាស់សត្វស្វាឃើញច្បាស់ថ្មត្រូវត្រង់
សត្វ ឬ ដុំថ្មក៏សាកចង់ សត្វសួរថ្មថ្លង់បានមិនឆ្លើយ។

១១. បងថ្មៗម្តេចមិនស្តី បងថ្មហេតុអ្វីធ្វើកន្តើយ
បងថ្មខ្ទុំចង់លោតឆ្លងត្រើយ បងថ្មមិនឆ្លើយគទេអី។

១២. ក្រពើភ្លើៗមិនដឹងដប់ ក្រពើល្ងង់កប់ស្មានប្រក្រតី
ក្រពើថាថ្មចេះពោលស្តី ក្រពើខំភ័យឆ្លើយរហ័ស។

១៣. អឺអើ! បងស្វាទៅណាហ្ន៎! អឺអើ! អញថ្មក្រពើចាស់

អឺអើ! ស្វាដឹងយល់ជាក់ច្បាស់ អឺអើ! ផ្លោតផ្លាស់រហ័សក្រៃ។

១៤. ឆ្លងត្រើយបេះស្វាយទុំឆីឆ្អែត ឆ្លងត្រើយដើមហេតុថ្លើមថ្លាថ្លៃ
ឆ្លងត្រើយឆ្លងស្ទឹងចេញចាកព្រៃ ឆ្លងត្រើយវិលវៃតាមសន្យា។

១៥. ពោលប្រាប់ក្រពើកាលឆីស្រេច ពោលប្រាប់ដូចម្តេចគឺពោលថា
ពោលប្រាប់ក្រពើបើកមាត់ហា ពោលប្រាប់ឆាប់វ៉ាតាមសច្ចៈ។

១៦. ក្រពើហាមាត់ឲ្យច្រងាង ក្រពើអើបខាងអាងត្របាក់
ក្រពើហាមាត់បែរជាខ្វាក់ ក្រពើអប្បលក្ខណ៍ល្ងង់ដប់ជិត។

១៧. ជាតិជាបណ្ឌិតផុតទុក្ខទោស ជាតិជាពាលនោះតែងខាតពិត
ជាតិជាអ្នកប្រាជ្ញជាបណ្ឌិត ជាតិអ្នកពោលពិតឥតមុសា។

១៨. សច្ចៈស្មោះត្រង់នាំសុខសាន្ត សច្ចៈថ្កើងថ្កានល្អថ្លៃថ្លា
សច្ចៈនាំផុតក្តីមរណា សច្ចៈបងស្វាសុខលុះក្ស័យ។

១៥កើត ជេស្ឋ ចរ ព.ស ២៥៦២

អង្គារ ២៩ ឧសភា ២០១៨

និពន្ធ ភិក្ខុបញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៦២ ពេលអ្នកឃ្លាតទៅ

បទ ពាក្យឆ្នាំមី

១. ពេលអ្នកឃ្លាតទៅខ្ញុំនៅឯកា គ្មានពុកគ្មានប៉ាជាកូនកំព្រា
រស់នៅកំសត់អត់ឃ្លានវេទនា អ្នកម្តាយជរាខំចិញ្ចឹមកូន។

២. ថ្ងៃរះហើយលិចចោលទ្វីបលោកិយ ទុកកូនប្រុសស្រីរសាត់ដូចក្បួន
អាណិតអាសូរជីវិតរូបកូន ម៉ែខំក្រាបលូនគ្រប់ជណ្តើរផ្ទះ។

៣. អាណិតអ្វីម្ល៉េះជាតិកូនកំព្រា រស់នៅរងាររងទុក្ខកម្មក្រាស់
អត់សព្វអត់គ្រប់អត់ម្លប់តេជៈ ចង់មានខ្លាំងណាស់តែលោកឃ្លាតហើយ។

៤. គុណលោកគុណធំគុណសែនអានន្តពុកម៉ែមានគុណបង្ហាញកោះត្រើយ
ពុកជាទូកធំម៉ែអុំគ្មានល្ហើយ ឱស! ឱ! កូនអ្ហើយរំពៃនឹកអ្នក។

៥. ជាតិកូនកំព្រាតែងដង្ហោយហៅ មានម៉ែមានឪនៅថ្នមនៅថ្នាក់
លួងលោមប្រលែងទឹកភ្នែកត្រជាក់ ជាអ្នកស្មោះស្ម័គ្រស្រលាញ់កូនពិត។

៦. ពេលអ្នកឃ្លាតទៅខ្ញុំនៅតែនឹក រលឹមរលឹកនឹកព្រឹកល្ងាចល្ងិត

ពុកធ្លាប់និទានរឿងរ៉ាវជីវិត រឿងពិតប្រឌិតលិខិតវាចា។

៧. សូរសព្ទស្តាប់សៀងផ្ទៀងកំដរកាយចំណែកអ្នកម្តាយហត់នឿយយ៉ាងណា
ទឹកមុខញញឹមមកពីធ្វើការ រៀបរាប់ភាសាបេះដូងបរិសុទ្ធ។

៨. ម៉ែខ្ញុំពុកខ្ញុំៗយំនឹកគាត់ នឹករឿងកំសត់ជីវិតទុរគត
ជីវិតគ្រួសាររស់នៅអត់ធ្មត់ ឈ្លោះគ្នាបំផុតដូចចានក្នុងរាវ។

៩. ឱ! ជីវិតកូនរសាត់ដូចចក ប្រៀបជួបស្នេហ៍ខកព្រាត់ប្រាស់ដូចទាវ
មិនអាចជួបមុខៗជូរដូចភ្ញៀវ រឿងចានក្នុងរាវរណ្តំដួងចិត្ត។

១០. ផ្ទះឈើផ្ទះធំទ្រនុំកក់ក្តៅ រឿងទុក្ខសោកសៅជិតស្នាមជីវិត
២០ឆ្នាំចាំជាក់អ្នកចាររឿងពិត ចំណងលិខិតខ្ញុំចារមិនអស់។

១១. ពេលអ្នកឃ្លាតបាត់ស្ងាត់ស្ងៀមរៀមព្រួយពុកមានតែមួយឲ្យកូនស្រណោះ
អាណិតម៉ែស្រីរស់នៅមានឈ្មោះ កេរ្តិ៍មិនពិរោះជាស្ត្រីមេម៉ាយ។

១២. ហត់ណាស់នឿយណាស់ជីវិតឯកអង្គរស់ជាព្រះសង្ឃរិតតែឃ្លាតឆ្ងាយ
បារម្ភយប់ថ្ងៃញោមជាក់ជាម្តាយ ដល់កូនទាំងឡាយជាឈាមលោហិត។

១៣. ពេលដែលរូបកូនពេលមានគ្រួសារ ទើបកូនយល់ការរាក់ជ្រៅនោះពិត

ចំណីមួយម៉ាត់ក៏កូនតែងគិត ដល់កូនសួនស្និទ្ធម៉ែគិតដល់ចៅ។

១៤. ជាតិចាស់ជាតិខ្ទីជាតិមានខ្លឹមសារ កុលបុត្រធីតារក្សាពង្សផៅ

រៀបចំគ្រួសារឲ្យបានកក់ក្តៅ មុនអ្នកឃ្លាតទៅបរមលោកអើយ។

៦ ។៤ជេស្ឋ ចរ ព.ស២៥៦២

សុក្រ ១៨ ឧសភា ២០១៨

និពន្ធ ភិក្ខុបញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៦៣ នឹកអ្នក

បទ ពាក្យត្រាំមី

១. នឹកអ្នកដែលយល់ស្រលាញ់ថ្នមបី នឹកអ្នកបេតីស្រីដែលលោមលួង
នឹកអ្នកៗនឹកតែងបន់បួងសួង នឹកសំលេងជួងបបមសិក្សា។

២. នឹកដល់អ្នកឃ្លាតទាំងឃើញជ្រងោរ នឹកដល់ពុទ្ធោធម្មោសង្ឃារ
នឹកដល់ព្រះសង្ឃជាទីជ្រះថ្លា នឹកដល់ជូនតាប្រឹងប្រែងសាងជាតិ។

៣. នឹកដល់វាចាវប្បធម៌ប្រពៃ នឹកដល់សិរីទំនៀមផៅញាតិ
នឹកដល់រឿងល្អដែលចេះតែឃ្លាត នឹកដល់រសជាតិចងចាំជាប់ចិត្ត។

៤. នឹកបងនឹកប្អូននឹកកូនប្រពន្ធ នឹកកម្មទារុណនឹកគុណស្នាលស្និទ្ធ
នឹកក្តីស្នេហ៍ស្នងនឹកគុណបណ្ឌិត នឹកភាពសុចរិតប្រព្រឹត្តកុសល។

៦ ។៤ជេស្ឋ ចរ ព.ស២៥៦២

សុក្រ ១៨ ឧសភា ២០១៨

និពន្ធ ភិក្ខុបញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

អំណាញ ៦៤ ភ្ជំធោមនស្សុ

បទ ពាក្យត្រាំបី

១. រឿងនៅក្នុងលោកច្រើនសព្វបែបយ៉ាង សត្វដែលកសាងច្រើនអសង្ខ័យ
វិលក្នុងវដ្ត:ឧបនិស្សយ កិលេសចង្រៃតាក់តែងបញ្ហា។

២. សត្វលោកងុយងោករោគច្រើនអនេក ថ្ងៃនេះថ្ងៃស្អែកជាប់ដោយតណ្ហា
ចង់បានលាភយសកេរ្តឹ៍ឈ្មោះថ្លៃថ្លា បន់ព្រះប្រាថ្នារូបល្អសក្តិធំ។

៣. សម្បត្តិក្នុងលោកច្រើនអនេកក្រៃ សត្វមាននិស្សយស្គាល់រសបរម
ចេះស្កប់ចេះល្មមចេះព្រមស្គាល់ខ្ទុំ រស់ក្នុងសង្គមកាមភពលោភលន់។

៤. រឿងរ៉ាវតិះដៀលកើតឡើងបន្ត រឿងរ៉ាវអ្នកក្រក៏ជួបទុក្ខធ្ងន់
រឿងរ៉ាវអ្នកបួសរស់មានប្រពន្ធ រឿងរ៉ាវកាមគុណទោសធ្ងន់ក្រៃលែង។

៥. ធម៌មានសម្តែងតាក់តែល្អល្អះ ព្រះពុទ្ធបានត្រាស់គាថាសម្តែង
ការកើតជាមនុស្សសែនក្រក្រៃលែង ម្តេចចោលខ្លួនឯងក្នុងអបាយភូមិ។

៦ ។៤ជេស្ឋ ចរ ព.ស២៥៦២ .សុក្រ ១៨ ឧសភា ២០១៨

និពន្ធ ភិក្ខុបញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៦៥ រស់មួយមិនល្អ

បទ ពាក្យឆ្នាំមី

១. រស់ដើម្បីខឹងក្រោធចង្អៀតចង្អល់ រស់ដើម្បីខ្វល់កង្វល់លោកិយ
រស់ដើម្បីទុក្ខឥតត្រាប្រណី រស់ដើម្បីអ្វីរៀនសួរខ្លួនឯង?

២. មួយជាតិបានជួបមនុស្សមិនខឹងក្រោធមួយជាតិរស់នោតតាមកម្មតាក់តែង
មួយជាតិដើរតួគ្រប់រោងសម្តែង មួយជាតិកំប្លែងសើចប៉ុន្មានដង?

៣. មិនខឹងមួយជាតិអនាគាមី មិនខឹងជីវីជីវិតសុខផង
មិនខឹងមួយថ្ងៃសុខក្រៃកន្លង មិនខឹងប្អូនបងរៀនឲ្យអភ័យ។

៤. ល្អអាចធ្វើគ្រូគំរូជីវិត ល្អជាគំនិតជីវិតប្រពៃ
ល្អជាវិន័យសួស្តីសិរី ល្អញាតិប្រុសស្រីមេត្តាកុំខឹង។

៦ ។៤ជេស្ឋ ចរ ព.ស២៥៦២

សុក្រ ១៨ ឧសភា ២០១៨

និពន្ធ ភិក្ខុបញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៦៦ ទុក្ខព្រោះតែអ្នកដទៃ

បទ ពាក្យត្រាំម៉ី

១.	រស់នៅរាល់ថ្ងៃរស់ដើម្បីទ្រព្យ	រស់រកយសគាប់ទ្រព្យគាប់ចិន្តា
	រស់វង្វេងភពយប់ថ្ងៃសោកា	រស់ក្នុងសង្សារក្នុងវដ្តៈភ័យ ។
២.	កុសលសត្វលោកលោភមានតិចតួច	ភរភូតខាងលួចឆក់ឆាបស្នូចត្រី
	ក្លែមអួតជជែកសុរាមេរ័យ	ធឹកស្រាផែនដីមានរសជាតិជ្រៅ។
៣.	ងាកឆ្វេងបត់ស្តាំចាំក្បែរភ្លើងស្តុប	ដេកដើរឈរឈប់ផ្លាកហាងតាំងនៅ
	យីហោស្រាល្បីគ្រប់ច្រកល្ហកផ្លូវ	បច្ចុប្បន្នឥឡូវត្រូវពីរពាន់ផ្លាយ។
៤.	វង្វេងនឹងស្រាសង្ហារនឹងស្រី	ឆ្កួតនឹងភាពល្បីសីលធម៌ឃ្លាតឆ្ងាយ
	ងងឹត និង ខ្វាក់នាំគ្នាសប្បាយ	រីករាយក្អាកក្អាយទៅអបាយភូមិ។
៥.	ព្រោះតែយសសក្តិមាសប្រាក់ដុល្លា	ព្រោះតែរាជការសម័យសង្គម
	ព្រោះតែញាតិមិត្តផ្តាប់ចិត្តមាសមុំ	ព្រោះចង់ធ្វើធំលះធម៌សប្បុរស។

៦ ។៤ជេស្ឋ ចរ ព.ស២៥៦២

សុក្រ ១៨ ឧសភា ២០១៨

និពន្ធ ភិក្ខុបញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ៦៧ សុខក្នុងពោលធម៌

បទ ពាក្យត្រាំបី

១.	សុខា សទ្ធម្មទេសនា	សុខពោលវាចាធម៌ព្រះជិនស្រី
	បានសុខព្រោះសង្ឃមិនបែកពីរបី	សាមគ្គីសិរីព្រមព្រៀងតាមធម៌។
២.	ថ្ងៃនេះត្រូវចូលបន្ទំដួងចិត្ត	បីខែមែនពិតវស្សាបវរ
	សូមជួបព្រះគុណព្រះសង្ឃដែលល្អ	ចេះស្គាល់ខ្មៅសល្អអាក្រក់ដឹង។
៣.	ថ្ងៃចូលវស្សាមហាមេឃធ្លាក់ចុះ	រុក្ខជាតិខៀវស្រស់លូតលាស់ខំប្រឹង
	ស្រល់ស្រោងតូចធំព្រិចស្មៅវល្លឺថ្នឹង	ថ្ងៃនេះខ្ញុំនឹងចូលចាំវស្សា។
៤.	ក្នុងវត្តមហាវនវស្សាទីបី	គង់ក្នុងកុដិរៀនវិបស្សនា
	ទន្ទេញធម៌សូធ្យបរិត្តិនមស្ការ	ព្រមទាំងគាថាពិរោះរណ្តំ។
៥.	ទឹកជ្រោះហូរទៅកាត់ផែនផ្ទាំងថ្ម	រលកតៗថ្មដាច់ជាដុំ
	ដាក់ចិត្តរៀនសូត្រត្រូវតែខិតខំ	ទើបនាមសាកសមបព្វជិតសិក្សា។
៦.	រក្សាទ្វារបីដោយក្តីសុច្ចរឹត	តស៊ូប្រព្រឹត្តតាមការប្តេជ្ញា
	យ៉ាងហោចណាស់គង់ចេះមួយគាថា	ធម៌អន្ទិចាពិចារណ៍គ្រប់កាល។

កំណាព្យ ៦៨ ថ្ងៃលិចចាំស្តាប់

បទ ពាក្យឆ្មាំមី

១. ថ្ងៃលិចបាត់ទៀតលិចបាត់ទៅហើយ ឱ!មាសម្តាយអើយទន្ទឹងចាំស្តាប់
ពាក្យពេចន៍កូនពៅត្រូវរៀបរាប់ប្រាប់ ពាក្យពេចន៍សារសព្វធម្មសនិទាន។

២. ឱស!ឱ!មាតាខ្លោចផ្សារដួងចិត្ត តូចចិត្តអាណិតជីវិតខ្វះឃ្លាន
កូនមិនយល់ចិត្តដ្បិតក្រមិនមាន ឲ្យទទួលទានគាប់ចិត្តព្រះមេរ៍។

៣. សូមមុនថ្ងៃលិចកូនសាងកុសល រយពាន់ហេតុផលផ្អែមល្ហែមជាងគេ
កូននៅជួបមុខមិនចង់ស្តីទេ ចង់ស្តាប់មាសកូនសំណព្វពៅ។

សៅរ៍ ១រោច អស្សុជ ចរ ព.ស២៥៦២

សៅរ៍ ២៨ កក្តដា ២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៦៩ ពិរោះសាច់ធម៌

បទ ពាក្យត្រាំម៉ី

១.	ពិរោះនឹងសាច់ធម៌	ជ្រាបដល់ជំរឿាមសន្តាន
	បានស្តាប់មិត្តកល្យាណ	បានស្រោកស្រាន្តទុក្ខសៅហ្មង។
២.	ក្តីសោកក្តីក្តុកក្តួល	ក្តីរំជួលព្រោះអូនបង
	កើតទុក្ខព្រោះស្នេហ៍ស្នង	ចិត្តរឹតចងនាមភរិយា។
៣.	បានមកជាស្វាមី	ប្រពន្ធប្តីរស់ជុំគ្នា
	មានសុខទុក្ខវេទនា	គ្រប់វេលាកាលកិច្ចកល់។
៤.	ស្រលាញ់ខ្លាំងទុក្ខខ្លាំង	ដ្បិតមានខ្មាំងមារខ្វាយខ្វល់
	បង្កើតទុក្ខកង្វល់	វិលរចល់ក្នុងវដ្តៈ។
៥.	សត្រូវក្នុងលោកា	គ្មាននរណាគឺរាគៈ
	ទោសៈនិងមោហៈ	ដែលម្នាក់ៗមានគ្រប់រូប។

សៅរ៍ ១រោច អស្សុជ ចរ ព.ស២៥៦២ .សៅរ៍ ២៨ កក្តដា ២០១៨

និពន្ធ ភិក្ខុ បញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៧០ បច្ចក់សិរីសុមង្គោ

បទ ពាក្យឆ្នាំមី

១. មួយភ្លែតមួយឆ្នាំកន្លងផុតទៅ ត្រឹមតែសល់នៅរូបថតបន្សល់
កើតចាស់ឈឺស្លាប់បាបបុណ្យកុសលញោមជាតបានផ្តល់កើតកំណើតថ្មី។

២. សុមនោកូនប្រុសក្មួយប្រុសសំណព្វ សាច់ឈាមស្រស់គាប់ប្តូរភេទពីស្រី
មកកើតជាប្រុសឥតខុសទាស់អី មាឌម៉ាប់ចាប់បីបីគីឡូហ្គ្រ៉ា!

៣. ស្លាប់ទាំងកំសត់សល់ត្រឹមភក្តី មកកើតឋានថ្មីសិរីសាច់ស
មាឌថ្លោសមុខមាំសុខភាពបវរ មិនសូវមាត់កយំរកទារប៉ៅ។

៤. សុមនោនាមថ្មីឲ្យជួនឈ្មោះដើម ខ្ញុំនឹងនឹកឆ្គើមពោលរឿងញោមពៅ
ពៅជាតបានស្លាប់កាលពីឆ្នាំទៅ ក្នុងនាមចុងភៅបម្រើព្រះសង្ឃ។

៥. កាលថ្ងៃគាត់ស្លាប់ខ្ញុំយំរៀបរាប់ ទេសនាតជាប់ទុក្ខសោកឯកអង្គ
គាត់អង្គុយលើមជ្ឈសត្រូវត្រង់ ចុងមជ្ឈសកំប្លង់ហើយពោលវាចា។

៦. បពិត្រលោកម្ចាស់ជួយប្រាប់បងស្រី ២៥ខែថ្មីសូមប្រាប់បងថា
ខ្ញុំកើតជាថ្មីជាកូនប្រុសណា កាលនោះអាត្មាក៏គង់ចាំស្តាប់។

៧. លុះរាត្រីកាលកន្លងចូលព្រឹក ម៉ោងពីរលឹកឃើញញោមជាតស្លាប់
អង្គុយគល់ឈើមិនពោលវ៉ាយវ៉ាប់ ដល់ហែរខ្មោចស្រាប់ដល់បញ្ចុះសព។

៨. ដូចអើយសែនដូចពិតអើយសែនពិត ព្រៃឈើជុំជិតដូចកាលយល់សប្តិ
សួរអ្នកភូមិផងក៏បានរៀបរាប់ ឈើធំនោះជាប់មានគល់ធំមួយ។

៩. រយៈបួនខែកន្លងផុតទៅ បងស្រីខ្ញុំនៅដែលធ្លាប់មកជួយ
ដាំបាយធ្វើម្ហូបរួមគាត់ជាមួយ គាត់តែងហៅក្មួយមកពីមានជ័យ។

១០. គាត់ថាគាត់មានទំងន់បីខែ ហើយកូននោះដែរគឺជាកូនស្រី
លុះដល់ប្រាំខែនោះឈឺពោះភ័យ ទៅជួបពេទ្យល្បីពេទ្យថាកូនប្រុស។

១១. លុះដល់ជិតកើតនៅមួយសប្តាហ៍ យល់សប្តិកូនង៉ាឥតមានឲ្យខុស
ថ្ងៃសុក្រទីម្ភៃឆ្នាំនេះទានប្រោស ដោយក្តីសន្តោសប្រសូត្រសុខសាន្ត។

១២. ឥឡូវទីម្ភៃបីលៃបង្កក់ ជាទ្រព្យមរតកកូនប្រុសកល្យាណ
នាម ឈាន សុមនោ ចិត្តល្អថ្កើងថ្កាន ទ្រព្យធនលុយឡានវិឡាផ្ទះថ្ម។

១៣. បើកភ្នែកឃើញលាភ ដើរចេញរកចូល លុយកាក់ចំណូលលាភចូលបន្ត
គ្រួសារសុខសាន្តសុខភាពបវរ សុមនោចិត្តល្អត្រជាក់ត្រជុំ។
១៤. ជយោ!សិរី ជយោ!ពលៈ ជយោ!វណ្ណៈ ជ័យជោគឧត្តម
ជយោ!អាយុ សុខសាន្តមនោរម្យ សុមនោកូនខ្ញុំ ក្មួយខ្ញុំថ្កុំថ្កើង។

៨ កើត ស្រាពណ៍ ចរ ព.ស ២៥៦២

១៩ សីហា ២០១៨

និពន្ធ ភិក្ខុបញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៧១ ព្រះសង្ឃ

បទ ពាក្យស្រាំបី

១. សែនសំណាងល្អបងបានជួបស្រី មានកូនអត់ប្តីកោរសក់គ្មានសល់
បងមកជួបអូនស្វែងរកមគ្គផល ជួយស្រាយចំងល់កង្វល់ខ្វល់ខ្វាយ។

២. សែនសំណាងល្អបងបានជួបអូន មានចៅមានកូនជួបជុំសប្បាយ
ព្រលឹមរៀបចំតុបតែងរាងកាយស្រង់ទឹកស្រស់ស្រាយសប្បាយពាក្យពោល។

៣. ម្ចាស់អូនម្ចាស់បងស្រងស្រស់ត្រឹមត្រូវ មុខមិនក្រម៉ូវត្រូវទឹកខ្ចោល
ទោងតោងកុមារៗកូនតែងយោល តោះយើងចុះចូលបន្ទូលព្រះអង្គ។

៤. កុំលុះក្នុងស្និទពេញចិត្តពាក្យផ្អែម ស្រីស្រស់លាបក្រែមលាបម្សៅផូរផង់
សរសើរស្រស់ស្រីដូចច័ន្ទពេញវង់ អូននៅតែលង់ពាក្យលួងលោមថ្លៃ។

៥. មានកូនតូចធំកើតមិនចេះគ្រប់ មានកូនមិនឈប់ជួនយប់ជួនថ្ងៃ
មានកូនដប់ម្កែភ្លោះហួសនិស្ស័យ ដើម្បីចរណៃបងចេះតែប្រឹង។

៦. សម្លឹងមើលខ្ទះជំរះបាយក្តាំង កូនឃ្លានសាច់អាំងណាស្រស់ព្រលឹង
អូនអើយខំថែកូនចៅយើងហ្នឹង ដល់ធំមាំឆ្អឹងរឹងផ្តួសរស់សុខ។

កំណាព្យ ៧២ វិញ្ញាណស្នេហ៍ចាស់

បទ ពាក្យឆ្នាំមី

១. វិញ្ញាណស្នេហាវិញ្ញាណសច្ចា វិញ្ញាណចិន្តាវិញ្ញាណព្រលឹង
វិញ្ញាណចងចាំវិញ្ញាណបានដឹង វិញ្ញាណមួយហ្នឹងដឹងរឿងសោកសៅ។

២. សម្បថស្បថស្បែរថៃថួនពាន់ឆ្នាំ ចិត្តបងចងចាំនៅនឹកពាលពៅ
កប់ទុកម៉ឺនថ្ងៃអាល័យឆោមឆ្ងៅ កប់ទុកក្រអៅបេះដូងបរិសុទ្ធ។

៣.មនោកម្មបោកលេបស្រោបយកទុក្ខសោកលៃលកវិយោគទុក្ខសោកស្រយុត
ស្រយុង្គលុងខ្លួនគ្មានទីបំផុត ក្លាហានមុះមុតចាញ់សង្គ្រាមស្នេហ៍។

៤.សង្គ្រាមសមរភូមិច្បាំងមិនដែលចាញ់ចាញ់ក្តីស្រលាញ់ល្បិចកល់ប្រួលប្រែ
ម្តងខឹងម្តងស្អប់ស្រវឹងឡប់ឡែរ ស្រីមានពិសស្នេហ៍បង្អែរចិត្តស្មោះ។

៥. តាមតែតណ្ហាចិត្តកាចឬស្យា ចិត្តចង់ប្រហារមនុស្សលោកទាំងអស់
ដែលសម្លាប់នាងមានភក្តីស្មោះ ចំពោះបុរសប្តីល្ងង់មួយគ្រា។

៦. ទឹកថ្នាំមានពិសមនុស្សចិត្តឃោរឃៅ បាននាំយកទៅឲ្យស្រស់ពុំងារ
លួងលោមបញ្ឆោតចិត្តចងកម្មពៀរ អាណិតភរិយាដើមល្អប្រពៃ។

៧. ភ្លើងស្នេហ៍ឆាបឆេះភ្លើងស្នេហ៍រោលរាលញាតិផងតិះដៀលរឿងប្រពៃណី
ទុក្ខទំងន់ស្នេហ៍មិនអាចថែស្រី ជាប្រពន្ធប្តីស្មោះមួយនឹងមួយ។

៨ កើត ស្រាពណ៌ ចរ ព.ស ២៥៦២

១៩ សីហា ២០១៨

និពន្ធ ភិក្ខុបញ្ញាហានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៧៣ សុំទោសម្ចាស់ស្នេហ៍

បទ ពាក្យត្រាំបី

១. ម្នាក់ឯងនៅក្នុងហានវិមានសួគ៌ រឿងគួរមិនគួរសួរចោទប្រស្នា
រៀបឬកតែងតួសំនួរបញ្ញា រៀបរាប់រាចាសិក្សាជីវិត។

២. តស៊ូអំណត់ក្នុងការសិក្សា កាត់បង់តណ្ហារក្សារឿងពិត
ប្រវត្តិយូរលង់កាលកេរ្តឹ៍អតីត ផ្អែមល្ហែមជិតស្និទ្ធនៅសល់ត្រឹមធាតុ។

៣. ប្រុសៗសង្ហារកញ្ញាតោងស្អិត មកសុំស្នេហ៍ស្និទ្ធគ្រប់បែបគ្រប់ស្នៀត
ដើម្បីបានបងយកមកធ្វើញាតិ ក្រេបភ្លក់រសជាតិស្នេហ៍គ្រប់វេលា។

៤. សូម្បីអ្នកបួសក៏មិនលើកលែង ស្រីយកជាល្បែងតែងរៀបឬកពារ
លោកអង្គណាខ្សោយខ្វះពុទ្ធធម្មា ទោះបីឃ្លាតឃ្លាពីផ្នួសមិនថ្វី។

៥. អង្គឯងក៏បានមិនស្គមប្រាណគិត ហត់នឿយគំនិតគិតពីស្រស់ស្រី
កុំឲ្យកម្មពៀរតាមដៀលជេរស្តី ក្នុងនាមជាប្តីខ្វះភាពស្នេហា។

៦. ខ្វះសព្វខ្វះគ្រប់ខ្វះម្លប់កក់ក្តៅ ខ្វះស៊ីជំរៅលំនៅវីឡា
ខ្វះកាយសុច្ចរិតចិត្តពោលវាចា ខ្វះសព្វខ្លឹមសារសិក្ខាមនុស្សល្អ។

៧. អង្គឯងឯការរក្សាកិត្តិយស រក្សាកេរ្តិ៍ឈ្មោះរស់ក្រោមម្លប់ធម៌
បងសូមលាស្រីប្តីធ្លាប់កករ ភក្តីស្មោះសរទឹកចិត្តប្តីក្បត់។

៨. ចេញច្បាំងបានពានវិមានស្រីស្រស់ កាចឆ្នាស់អស់ទាស់ឲ្យអូនកំសត់
ទំងន់ស្នេហាឲ្យយើងប្រាស់ព្រាត់ សាងជាប្រវត្តិស្បថផ្សងសច្ចា។

៩. ឲ្យបានជួបបងចំណងស្នេហ៍ថ្មី ជាប្រពន្ធប្តីស្មោះស្ម័គ្រស្នេហា
គ្មានអ្នកទីបីដោយក្តីប្រាថ្នា អូនផ្សងសច្ចាជួបបងគ្រប់ជាតិ។

១០.ចំណែកបងវិញបានឃើញទុក្ខលោកដែលត្រូវសោយសោកវិយោគគ្រោតគ្រាត
ទ្វីបលោកធំណាស់បែរតូចចង្អៀតដោយសាររសជាតិតណ្ហាចាក់ស្រេះ។

១១. អវិជ្ជាបិទបាំងឃាត់ឃាំងទុកនៅ លោភៈបិទផ្លូវនិព្វានពិសេស
បើបងតាមអូនមានកូនដូច្នេះ ចំណងកិលេសរួមរឹតគុណទ្វេរ។

១២. ពីមុននៅល្ងង់តាំងផ្សងជួបអូន ព្រមទាំងជួបកូន! កូនៗមាសមេ
ឥឡូវបានបួសរស់រៀនរិះរេ លះបង់ក្តីស្នេហ៍ចាប់យកព្រះធម៌។

១៣. ឱរសជាតិស្នេហ៍អតីតជូរចត់ ភរិយាកំសត់ភក្តីស្មោះសរ
សូមអូនបានសុខរស់នៅដោយបវរ ជាតិនេះអូនល្អកូនចាហ្វាយខេត្ត។

១៤. ហានៈសក្តិយសអូនខ្ពស់ពេកពន់ អូនមានទ្រព្យធនល្មមស្កប់ស្កល់ឆ្អែត
ភ័ព្វបុណ្យអូនល្អខ្ពង់ខ្ពស់ត្រដែត កូនចាហ្វាយខេត្តកំពង់ស្តីអើយ។
១៥. បងជាអ្នកបួសរស់នៅក្នុងព្រៃ កាន់ធម៌វិន័យសូមផ្ញើរចម្លើយ
ឱស!ឱ!ភរិយាសំណព្វចិត្តអើយ កាត់ចិត្តឲ្យហើយកុំប្រាថ្នាបង។
១៦. បើមិត្តបានអានសូមច្រានសំណៅ កំណាព្យសោកសៅកប់ជ្រៅកន្លង
រាប់រយឆ្នាំខែនៅតែចាំចង ស្បថសច្ចាផ្សងជួបគ្នាគ្រប់ជាតិ។

អង្គារ៍ ២រោច ស្រាពណ៌ ព.ស ២៥៦២

២៨ សីហា ២០១៨

និព្វាន ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

បើអ្នកបានអានសូមមេត្តាផ្ញើរសារនេះជូនទៅគាត់ផង ដើម្បីឲ្យគាត់កាត់ចិត្តបំភ្លេចខ្ញុំចុះ។ បើអាត្មាបានជួបអ្នក អាត្មាសូមឲ្យអ្នកអភ័យទោសដល់អតីតប្តីក្បត់ម្នាក់នេះផង (លោកសេនាបតីធនញ្ជ័យប្រមុខរដ្ឋមហានរគ ហៅ សុរិយង្គពេជ្រ វិជ័យសង្គ្រាម)។

កំណាព្យ ៧៣ ថ្ងៃខួបកំណើតផ្ទួស

បទ ពាក្យត្រាំបី

១.	វិសាខបូជាជាថ្ងៃកំណើត	ដែលអាត្មាកើតសេចក្តីរលឹក
	អតីតកន្លងចងចិត្តដែលនឹក	ទៅតាំងពីព្រឹកលើភ្នំបាខែង។
២.	ឱ! ខេត្តសៀមរាបវិសុទ្ធិមគ្ត	នឹកមិត្តភក្តិម្នាក់ដែលជាមិត្តត្មែង
	កាលនៅគ្រហស្ថស្មោះស្ម័គ្រគម្តែង	នឹងស្តីថ្លាថ្លែងដំណើរយាត្រា។
៣.	កាលនោះរតនាសូរ្យពេជ្រ	នឹកឃើញជានិច្ចដោយក្តីជ្រះថ្លា
	ឃើញព្រៃឬស្សីដីច្រើនហិចតា	សូប់ស្ងាត់ម្លើះណាដោយធម៌អប់រំ។
៤.	មនុស្សច្រើនអ៊ូអរស្តាប់ធម៌ស្ងាត់ឈឹង	អ្នកដឹងទើបដឹងនៅក្នុងសង្គម
	សង្ឃបុត្តជិនស្រីរស់យ៉ាងសុខុម	ទើបបានរូបខ្ញុំសង្វេគសង្ខារ។
៥.	សុំព្រះអង្គគ្រូនាមសាន សប្បាយ	បំបួសរូបកាយដោយក្តីជ្រះថ្លា
	គុណព្រះឧបជ្ឈាយចៅអធិការ	សាមណេររតនាសូរ្យពេជ្រពិត។
៦.	ខិតខំរៀនសូត្រព្រះពុទ្ធវចនៈ	រៀនលះវដ្តៈរស់ដោយសុច្ចរឹត

អប់រំបន្ទុំដុសខាត់ជីវិត មួយវស្សាស្និទ្ធប្រាំខែកន្លង។

៧. សូមព្រះអង្គគ្រូឧបសម្បទា ត្រេកអរបព្វជ្ជាសទ្ធាម៉ត់ហ្មង
ស្តាប់សតិប្បដ្ឋានយល់សព្វចិត្តប៉ង បួសផ្នួសបំណងប្រាថ្នានិព្វាន។

៨. ទោះបីឈឺថ្កាត់ជាកម្លាំងកម្ម ឈឺជិតមួយឆ្នាំតស៊ូរស់រៀន
មិនឃ្លានតាមចង់ចំណង់ដែលឃ្លាន សន្តោសតាមមានរស់ក្នុងព្រៃស្ងប់។

៩. សាច់សារញាតិមិត្តទោះជិតបង្កើយពុំឆ្លងឆ្លើយឡើយដោយស្រលាញ់ស្អប់
តែខំសិក្សាពន្យល់ឲ្យគាប់ ញោមស្រីសំណព្វអង្គអរហន្តី។

១០. អស់ប្រាំមួយខែញោមម៉ែឈប់យំ ស្តាយថាកូនខ្ញុំទៅរស់ក្នុងព្រៃ
ធ្លាប់ឃើញសង្ហារស្អាត់ខាងចំណី សណ្ឋាគារល្បីឱ! លោកកូន៧។

១១. វស្សាទីបួនភាវៈភិក្ខុ អង្គបុត្តនិរទុក្ខបានសាងលំនៅ
កុដិវិហារទានក្នុងព្រៃយ៉ាងជ្រៅ ក្នុងកាលឥឡូវប្រាំឆ្នាំចាកផ្ទះ។

១២. សែនត្រេកអរក្រៃនិស្ស័យអ្នកបួស ហ៊ានលះបង់ខ្ពង់រស់រៀនហ៊ានលះ
កូនប្រពន្ធប្តីយសសក្តិតេជៈ ការយកចាញ់ឈ្នះគ្មានទីបញ្ចប់។

១៣. ឱ! គីរីរម្យភ្នំទឹកជ្រោះធ្លាក់ ទីឋានសមណៈសាកសមសព្វគ្រប់

ត្រជាក់សព្វកាលមានព្រៃជាម្លប់ ទឹកហូរឥតឈប់ក្បែរម្លប់ព្រៃស្រល់។

១៤. ឮតែសត្វទោចទួញយំឆ្លងឆ្លើយ រៃមិនកន្តើយឆ្លើយឆ្លងមិនខ្វល់

យប់ស្ងាត់ងងឹតភ្លើងហោះគួរឆ្ងល់ ឆោមឆើតនិមលអំពិលអំពែក។

១៥. ហោះហើរព្រោងព្រាតភ្លឺពេញអន្ធកា តែចាញ់ធម្មាជាព្រះធម៌ឯក

បំភ្លឺសត្វលោកលាលះទឹកភ្នែក អស់ភពថ្ងៃស្អែកបែកបាក់ញាតិមិត្ត។

១៦. វស្សាទីបួនចិត្តជាប់ស្នេហា ប្រាថ្នាសិក្សារស់អប់រំចិត្ត

កម្មដ្ឋានកសិណសុបិន្តនិមិត្ត ស្វែងរកភាពពិតដែលប៉ងប្រាថ្នា។

១៧. សូមអធ្យាស្រ័យរៀបរាប់វែងឆ្ងាយ សែនវែងអន្លាយរៀបរាប់ពិស្តារ

សូមបុណ្យកុសលមគ្គផលចេតនា ដល់ញាតិការគ្រប់ផៅសន្តាន។

១៨. សូមកុសលទានមានសាងពុទ្ធរូប សូមអ្នកសាធុគ្រប់រូបគ្រប់ប្រាណ

បានដល់ត្រើយសុខបរមសុខសាន្ត និព្វានកល្យាណឋានផុតវដ្ដៈ។

១៣កើត ចែត្រ ចរ ព.ស២៥៦០

សុក្រ ២៧ មេសា២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៧៤

បន្តវដ្តៈ

បន ពាក្យត្រាំមី

១.	ការងារវក់រីរ៉ាល់វក់រឹកវរ	ដូចទឹកកកររកធឹកមិនបាន
	ចាត់ចែងការងារធ្វើបែបស្មានៗ	ដូចជាចោលប្រាណក្នុងភពវេលា។
២.	កាលវែងពេលយូរតស៊ូធ្លាក់ថ្លុក	ឆ្លងកាត់ភក់ផុកស្ពុកប្រាណគ្រាំគ្រា
	កាយាទុក្ខសោកដួងចិត្តវេទនា	ចំណងកម្មពៀរបន្តវដ្តៈ។

១៣កើត ចែត្រ ចរ ព.ស២៥៦០

សុក្រ ២៧ មេសា២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

មនោនិវារណសូត្រទី៤

(បិដក២៩/៣៤)

យតោ យតោ មនោ និវារយេ ន ទុក្ខមេតិ នំ តតោ តតោ

ស សព្វតោ ទុក្ខា បមុច្ចតីតិ។

បុគ្គលគួរឃាត់ហាមចិត្ត ចាកអំពើអាក្រក់ ឬ ល្អណាៗទុក្ខរមែងមិនមក ដល់បុគ្គលនោះព្រោះអំពើនោះ។ បុគ្គលនោះ គួរហាមឃាត់ចិត្តសព្វអន្លើ បុគ្គលនោះរមែងរួចចាកទុក្ខទាំងពួង។

ន សព្វតោ មនោ និវារយេ មនោ យតត្តមាគតំ

យតោ យតោ ច បាបកំ តតោ តតោ មនោ និវារយេតិ។

បុគ្គលមិនគួរហាមឃាត់ចិត្តសព្វអន្លើ និង ចិត្តដែលដល់នូវសេចក្តីសង្រួមទេ លុះតែចិត្តអាក្រក់កើតឡើងក្នុងកាលណាៗ ទើបត្រូវបុគ្គលហាមឃាត់ចិត្តក្នុងកាលនោះ។

ចម្លងដោយ ភិក្ខុ បញ្ញាហានោ

កំណាព្យ ៧៥ ស្រែបុណ្យ

បទ ពាក្យត្រាំបី

១. ពេលមេយស្រទុំពពកចុះអ័ព្ទ ចង់រៀបរាប់ប្រាប់ញាតិញោមប្រុសស្រី
ពីកិច្ចព្រះសង្ឃទ្រទ្រង់វិន័យ ការងារគប្បីសម្តែងធម្មទាន។

២. ព្រះពុទ្ធវចនៈច្រើនក្រៃគគោក ព្រះសង្ឃលៃលកខិតខំប្រឹងរៀន
តាមពុទ្ធឱវាទព្រះអង្គទូន្មាន សទ្ធាបុណ្យទានព្រះសង្ឃប្រឹងប្រែង។

៣. បាតិមោក្ខបាឡីពីររយម្តៃប្លាយ ព្រះសង្ឃសប្បាយស្វាធ្យាយសម្តែង
ធ្វើឧបោសថគ្រប់ព្រះគម្តែង ព្រះពុទ្ធតាក់តែងច្បាប់អង្គសិក្ខា។

៤. ព្រះសង្ឃមិនហ៊ានបំពានល្មើសឡើយព្រះសង្ឃត្រង់ហើយពោលឥតមុសា
ព្រះសង្ឃបួសពិតកាត់បង់មោហាលោភលន់ទោសាកាត់ផ្តាច់កិលេស

៥. ព្រះសង្ឃសាមគ្គីរក្សាក្តីសុខ ព្រះសង្ឃនិរទុក្ខតណ្ហាចាក់ស្រេះ
ព្រះសង្ឃល្អណាស់ពេញដោយចំណេះព្រះសង្ឃពិសេសសម្រេចអរហត្ត។

៦. មគ្គផលសង្រួមព្រមធ្វើតាមព្រះ អត់ធ្មត់ស៊ូលះញាតិខំបដិបត្តិ
តាមធម៌វិន័យនៃព្រះបរិយត្តិ រស់នៅសូប់ស្ងាត់ផ្សាយមេត្តាចិត្ត។

៨. ពាក្យថាព្រះសង្ឃជាស្រែបុណ្យល្អ ព្រះសង្ឃទ្រង់ធម៌បវរពិសិដ្ឋ
បើកទ្វារទាំងបីប្រព្រឹត្តសុច្ចរិត កាយវាចាចិត្តឥតមានសៅហ្មង ។
៩. ព្រះសង្ឃគឺជាអ្នកសូមតុណ្ហី មិនពោលមិនស្តីសុំហួសកន្លង
ក្រៅពីញាតិខ្លួននាំត្រូវទោសផង ទុក្ខដប់ពីរកងលោកប្រឹងរួចផុត។
១០. ព្រះសង្ឃលជ្ជីខ្មាស់បាបខ្លាចបាប ព្រះសង្ឃព្រួសសាបកថាវិមុត្តិ
ព្រះសង្ឃមានគុណខ្ពង់ខ្ពស់បំផុត ជង្គង់អោនលុតបង្គំវន្ទា។
១១. ព្រះសង្ឃបរិសុទ្ធផុតស្រីល្បែងស្រា ព្រះសង្ឃអស្ចារ្យ សិក្សាធម្មា
បដិបត្តិម៉ត់ចត់គ្រប់ពេលវេលា ព្រះសង្ឃពិតជាស្រែបុណ្យក្រៃលែង។
១២. សូមថ្វាយបង្គំប្រណម្យអញ្ជលី ព្រះសង្ឃទាំងពីរគ្រប់ទីកន្លែង
ព្រះអរិយសង្ឃអស់ភ័យចម្បែង អាត្មាចារថ្លែងតែងសូមខន្តី។
១៣. ក្រែងភ្លាត់ពាក្យពេចន៍រំលេចខុសឆ្គង ក្រែងលើសលស់ផងសូមទានប្រណី
គុណរតនត្រ័យគុណកែវទាំងបី នាំជោគសិរីលុះអមតៈស្ថាន។
១៤. សូមថ្វាយបង្គំចម្រើនពរលា អភិវាទវន្ទារតនថ្កើងថ្កាន
ព្រះពុទ្ធព្រះសង្ឃព្រះធម៌កល្យាណ សូមឲ្យខ្ញុំបានឋានសន្តិបទ។

កំណាព្យ ៧៦

ក្ទំជោរ

បទ ពាក្យត្រាំមី

១.	អនិច្ចាសង្ខារមិនទៀងឡើយ	ឱស!ឱ!សែហ្វអើយត្រូវនាប់ឃ្មាតខ្មី
	កុំកាន់តែម្ទេសចិញ្ញុំនាខ្ទី	ត្រូវរៀនបាលីនមោ តស្ស ។
២.	ឆ្លាក់ល្ពៅឆ្លាក់ចិត្តរក្សាគុណធម៌	មិនជោរញាប់ញ័នឹងពាក្យសរសើរ
	ថាលោកចេះឆ្លាក់ក្បាច់បានគ្រាន់បើ	មិនមែនដំណើរព្រះអរិយ។

៧ កើត ចែត្រ រកា ២៥៦០

សុក្រ ២៣ មីនា ២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៧៧

រង់ចាំ...

បទ ពាក្យឆ្នាំមី

១. តឹងទ្រូងប៉ុណ្ណាចាំបាត់ៗ អ្នកមានវិបត្តិស្ងាត់ចាកលោកា
តឹងទ្រូងធុញថប់ដួងចិត្តខ្លោចផ្សារ រង់ចាំសង្សារអស់ច្រើនវដ្ដៈ។

២. រង់ចាំចាំគេចាំច្រើនខែថ្ងៃ រង់ចាំថ្លើមថ្លៃរាល់ថ្ងៃជឿជាក់
រង់ចាំដួងចិត្តជីវិតស្មោះស្ម័គ្រ រង់ចាំវលក្ខណ៍ក្នុងក្តីសុបិន។

៧ កើត ចែត្រ រកា ២៥៦០

សុក្រ ២៣ មីនា ២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៧៨

ស្រម៉ៃ

បន ពាក្យច្រាំមី

១. ស្រម៉ៃល្អៈខ្លះតូចខ្លះធំ បានច្នៃរៀបចំបូជារតនៈ
ជាថ្នាំសង្គ្រវត្រូវជាតិសមណៈ ព្រះសង្ឃសាវ័កទ្រង់ឆាន់ល្ងាចបាន។

២. ស្រម៉ៃទោះល្វីងក៏ជាឱសថ រសជាតិល្អផុតប្រសើរដល់ប្រាណ
ព្រះសង្ឃរស់សុខក្នុងទីកល្យាណ សុខសាន្តក្សេមក្សាន្តព្រោះមានឱសថ។

៧ កើត ចែត្រ រកា ២៥៦០

សុក្រ ២៣ មីនា ២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ

កំណាព្យ ៧៩ កុដិឈើក្នុងព្រៃ

បទ ពាក្យប្រាំមួយ

១. ជួយជ្រោមជួយជ្រែងជួយសែងជួយលី សមណៈសាមគ្គីសំភីរម្យទម
កុដិឈើកុដិថ្មកណ្តាលព្រៃភ្នំ គឺជាជំរុំជំរកកម្មដ្ឋាន។

២. ជួយលើកទឹកចិត្តកំរឹតកម្លាំង ជួយធ្វើសម្រាំងសម្រិតគ្រប់ស្ថាន
គ្រប់ផ្នែកគ្រប់ផ្នត់សង្កត់ឲ្យបាន ហត់នឿយប៉ុន្មានកាត់បង់ក្រោធខឹង។

៣. ជួយជាមតិជួយជាបច្ច័យ កាត់បង់អាល័យលុយកាក់គាប់ដឹង
មានច្រើនចាយច្រើនណាស្រស់ព្រលឹង បើដឹងអញ្ចឹងប្រើឲ្យបានការ។

៤. បូជាបច្ច័យស្រម័យតាមដាន ធ្វើលំនៅឋានមិនបានហ៊ឺហារ
មិនប្រើខុសខ្នង់ល្ងង់ព្រោះសង្សារ បុលខ្ចីជីវ៉ាជំពាក់ស្តេចមារ។

៥. មានស្តេចមច្ចុយមបាលលោកកិយ តែងតាមបំភ័យគ្រប់ពេលវេលា
កាលមុនក្មេងវ័យគ្រប់អង្គគ្រប់គ្នា ឥឡូវជរាចាស់ជាលំដាប់។

៦. ផ្ទះថ្មតូចធំធ្លុំពីខ្សាច់ថ្ម បូកឥដ្ឋបន្តច្រើនតាមគុណគាប់
សំណង់គ្រឹះមាំទើបសំណង់ជាប់ អ្នកត្រូវទម្លាប់ជាប់ជួយអាសារ។

៧. កាត់បង់ក្តីខ្ជិលជំរះកិលេស តណ្ហាចាក់ស្រេះបេះដោយកិច្ចការ
រួតរះរហ័សផ្លាស់ប្តូរឥរិយា ស្វាហាប់ឧស្សាហ៍ការងារសុច្ចរិត។

៨. រៀនធម៌វិន័យដើម្បីបដិបត្តិ ផ្តើមពីបរិយត្តិទើបអាចប្រព្រឹត្ត
រកឃើញបដិវេធសច្ចៈធម៌ពិត រៀនហើយចេះគិតចេះពិចារណ៍។

៩. កុំរៀនអាងអួតឆ្កួតនឹងវិជ្ជា ខ្ជិលធ្វើការងារធ្វើវិបស្សនា
កម្មដ្ឋានសុខស្ងប់កាត់ផ្តាច់កម្មពៀរ សុខទុក្ខវេទនាជាកម្លាំងកម្ម។

១០. ប៉ុន្មានថ្ងៃនេះហត់នឿយពេកក្រៃ រោយជើងរោយដៃចិត្តនៅចងចាំ
បាយទឹកចំនីលៃលកចំណាំ បរិភោគតាមកម្មតាមសម្ភាយបុណ្យ។

១១. បាយចត់ហត់កាយប្រើមិនស្តាយប្រាណ ខ្សាច់ឥដ្ឋប៉ុន្មាន២០០០ព្រះគុណ
ឡើងភ្នំចុះភ្នំស្ទើរយំទុកមុន ព្រោះចង់បានបុណ្យបូជាទៅចុះ។

១២. អរគុណលោកម្ចាស់អ្នកមានអាយុ សាធុ!សាធុ! អរគុណទានប្រោស
បានជួយខ្នះខ្នែងប្រឹងប្រែងដោយស្មោះតូចពិតមានឈ្មោះថាអ្នកក្លាហាន។

១៣. ដ្បិតតែកុដិនេះជាកុដិបុគ្គល ដោយការយោគយល់រួមចិត្តសន្តាន
ដ្បិតផ្លូវជ្រោះជ្រងមិនអាចចូលឡាន ទើបសុំកល្យាណមិត្តជួយសាមគ្គី។

អាទិត្យ ១៤ អស្សុជ ចរ ព.ស ២៥៦២

២៣ កញ្ញា ២០១៨

និពន្ធ ភិក្ខុ បញ្ញាឋានោ ហួន រតនាសូរ្យពេជ្រ